ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍វិភាគស៊ីជម្រៅទិន្នន័យពី
ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ២០២១-២០២២

# លទ្ធភាពមានកូន និងសុខភាពបន្តពូជ នៅកម្ពុជា



មករា ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងផែនការ
វិទ្យាស្ថានជាតិស្ថិតិ

Bloomberg Philanthropies
DATA FOR HEALTH INITIATIVE
Vital Strategies

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## របាយការណ៍វិភាគស៊ីជម្រៅទិន្នន័យពី
## ទិន្នន័យអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០២១-២០២២

# លទ្ធភាពមានកូន និងសុខភាពបន្តពូជ
# នៅកម្ពុជា

ខែមករា ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងផែនការ
វិទ្យាស្ថានជាតិស្ថិតិ

Bloomberg Philanthropies

DATA FOR HEALTH INITIATIVE

Vital Strategies

# តារាងមាតិកា


តារាងមាតិកា ..... i
អារម្ភកថា ..... iii
បញ្ជីតារាង ..... v
បញ្ជីរូប ..... vii
ផែនទី ..... ix
បញ្ជីអក្សរកាត់ ..... xi
សង្ខេប ..... ១
ជំពូក១. សេចក្តីផ្តើម ..... ៥
១.១. គម្រូវការសិក្សា ..... ៥
១.២. គោលបំណងអង្កេត ..... ៦
១.៣. ប្រភពទិន្នន័យ ..... ៦
១.៤. វិធីសាស្ត្រអង្កេត ..... ៧
១.៥. រចនាសម្ព័ន្ធរបាយការណ៍ ..... ៨
ជំពូក២.ចរិតលក្ខណៈសេដ្ឋកិច្ច សង្គមកិច្ចស្ត្រីវ័យបន្តពូជ ..... ៩
ជំពូក៣, ចរិតលក្ខណៈស្ត្រី និងលទ្ធភាពមានកូន ..... ១៥
៣.១. មេដ្យានអាយុរួមភេទដំបូង រៀបការដំបូង និងមានកូនដំបូង ..... ១៥
៣.២. លទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់ ..... ២០
៣.៣. អត្រាលទ្ធភាពមានកូនសរុប (TFR) ..... ២៣
៣.៤. លទ្ធភាពមានកូន និងលទ្ធភាពចង់បានចំនួនកូនជាមធ្យម ..... ២៧
៣.៦. លទ្ធភាពមានកូនវ័យជំទង់ ..... ៣៥
៣.៧. គម្លាតកំណើត ..... ៣៧
ជំពូក៤. ផែនការគ្រួសារ ..... ៤៣
៤.១. ការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតបច្ចុប្បន្ន ..... ៤៣
៤.២. ទំហំគ្រួសារចង់បាន ..... ៤៨

៤.៣. តម្រូវការសម្រាប់ផែនការគ្រួសារ ..... ៥១
**ជំពូកទី៥. ការថែទាំសុខភាពមាតា និងទារក** ..... ៥៦
៥.១. ការថែទាំសុខភាពមុនពេលសម្រាល ..... ៥៦
៥.២. ទីកន្លែងសម្រាល ..... ៦១
៥.៣. ការថែទាំសុខភាពក្រោយពេលសម្រាល ..... ៦៣
៥.៤. បណ្ដាញទំនាក់ទំនងសង្គម ..... ៧៤
៥.៥. លក្ខខណ្ឌការរស់នៅ ..... ៧៥
៥.៦. សមីការពហុទំនាក់ទំនង ..... ៧៧
**ឯកសារយោង** ..... ៨៣
**សន្ទានុក្រម** ..... ៨៤

# អារម្ភកថា

របាយការណ៍នេះសិក្សាអំពី "លទ្ធភាពមានកូននិងការថែទាំសុខភាពមាតានៅកម្ពុជា" ដោយប្រើប្រាស់ទិន្នន័យមានស្រាប់ពីការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២ (CDHS)។ របាយការណ៍នេះព្យាយាមសិក្សាពីទម្រង់នៃលទ្ធភាពមានកូន និងតម្រូវការសម្រាប់ការធ្វើផែនការគ្រួសារនៅកម្ពុជា។ ការវិភាគទិន្នន័យមានស្រាប់នេះ និងសិក្សាពីការប្រែប្រួលតាមអ័ក្សនៃវិសមភាព ដូចជាទីកន្លែងរស់នៅ រាជធានី ខេត្ត កម្រិតសិក្សាអប់រំ និងសន្ទស្សន៍ទ្រព្យសម្បត្តិ។ ការវិភាគនេះធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ (NIS) សហការជាមួយក្រសួងសុខាភិបាល (MoH) និងឧបត្ថម្ភគាំទ្រពីអង្គការវ៉ាយថលស្ត្រេតជីជី (Vital Strategies)។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន** អតីតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ដែលបានគាំទ្រការធ្វើអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ទាំងប្រាំសើរ ដែលជាប្រភពដល់ការបំផុសគំនិត និងលើកទឹកចិត្ត ទាំងក្រុមការងារថ្នាក់ជាតិ ថ្នាក់អន្តរជាតិ ព្រមទាំងអ្នកប្រើប្រាស់ទិន្នន័យ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម ប៊ិន ត្រាឈៃ** រដ្ឋមន្ត្រីក្រសួងផែនការដែលបានបន្តនិរន្តរភាពនិងជួយសម្របសម្រួលរបាយការណ៍វិភាគស៊ីជម្រៅនេះឱ្យបានទទួលជោគជ័យ។

ខ្ញុំសូមថ្លែងអំណរគុណផងដែរ ចំពោះមូលនិធិប្រជាជនរបស់អង្គការសហប្រជាជាតិ (UNFPA) ដែលបានឧបត្ថម្ភគាំទ្រទាំងផ្នែកធនធាន និងជំនាញបច្ចេកទេសដែលបានដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តការអង្កេតនេះ។ ឆ្លៀតក្នុងឱកាសនេះសូមថ្លែងអំណរគុណចំពោះភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក(USAID) ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអាល្លឺម៉ង់ (GIZ) ជំនួយអូស្ត្រាលី (Australian Aids) មូលនិធិសហប្រជាជាតិសម្រាប់កុមារ (UNICEF) កម្មវិធីស្បៀងអាហារពិភពលោក(WFP) និងដៃគូអភិវឌ្ឍន៍(DPs)ផ្សេងទៀត បានរួមចំណែកក្នុងការធ្វើអង្កេតនេះ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលបានគាំទ្រផ្នែកហិរញ្ញវត្ថុ តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការអនុវត្តការធ្វើអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២។

ក្នុងនាមវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ខ្ញុំសូមថ្លែងអំណរគុណនិងវាយតម្លៃខ្ពស់ចំពោះលោក **Luis Armando Ocaranza-Ordaz** ទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់ និងលោកវេជ្ជបណ្ឌិត **មាន រតនៈសម្បត្តិ** អ្នកសម្របសម្រួលប្រចាំប្រទេសកម្ពុជា តំណាងអង្គការវ៉ាយថលស្ត្រេតជីជី (Vital Strategies) សម្រាប់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដើម្បីផលិតរបាយការណ៍នេះដែលជាឯកសារយោងសម្រាប់អ្នកសិក្សាស្រាវជ្រាវផ្សេងទៀត។

ខ្ញុំសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តម សុក កុសល** ទីប្រឹក្សានិងជាអគ្គនាយករង **ឯកឧត្តម បួយ សុមេធា** ទីប្រឹក្សា និងជាប្រធាននាយកដ្ឋានសេវាព័ត៌មានស្ថិតិ លោកស្រី **ស្រ៊ិន សុខអូន** អគ្គនាយករង លោក **ហោ ចាន់ឡា** អនុប្រធាននាយកដ្ឋានស្ថិតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

លោក **ឡុក សុរិយា** អនុប្រធាននាយកដ្ឋានសេវាព័ត៌មានស្ថិតិ និងមន្ត្រីវិទ្យាស្ថានជាតិស្ថិតិផ្សេងទៀត ដែលបានចូលរួមយ៉ាងសកម្មក្នុងការសរសេររបាយការណ៍នេះ។

លទ្ធផលដែលរកឃើញពីរបាយការណ៍នេះ រំពឹងថានឹងជាជំនួយក្នុងការធ្វើសេចក្តីសម្រេចចិត្តដល់ក្រសួង ស្ថាប័នទីភ្នាក់ងារអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល អ្នកធ្វើគោលនយោបាយ អ្នកអនុវត្តន៍កម្មវិធី អ្នករៀបចំផែនការអភិវឌ្ឍន៍ និងអ្នកសិក្សាស្រាវជ្រាវដទៃទៀត។

យើងជឿជាក់ថារបាយការណ៍នេះនឹងផ្តល់ព័ត៌មានពេញលេញ ចំពោះបទអន្តរាគមន៍ កង្វល់នានា និងការធ្វើផែនការ ក្នុងវិស័យសុខាភិបាលនាពេលអនាគត។

**អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

**ទ្រី ឫទ្ធា**

# បញ្ជីតារាង

តារាង ២.១ ភាគរយស្រីអាយុ ១៥-៤៩ឆ្នាំ តាមចរិតលក្ខណៈអង្កេតកម្ពុជា ឆ្នាំ២០២១-២០២២..........១១
តារាង ៣.១.១ មេដ្យាមអាយុរួមភេទដំបូង រៀបការដំបូង និងមានកូនដំបូងក្នុងចំណោមស្ត្រីអាយុ ១៥-៤៩ឆ្នាំ តាមចរិតលក្ខណៈអង្កេតក ម្ពុជាឆ្នាំ២០២១-២០២២..................................១៩
តារាង ៣.២.១ អត្រាលទ្ធភាពមានកូនសរុបតាមអាយុជាក់លាក់ អត្រាលទ្ធភាពមានកូនទូទៅ អត្រាលទ្ធភាពមានកូនដុលសម្រាប់រយៈពេល ៣ឆ្នាំមុនអង្កេតតាមចរិតលក្ខណៈអង្កេតកម្ពុជា ឆ្នាំ២០២១-២០២២..........................................................................................២២
តារាង ៣.៤.១ អត្រាលទ្ធភាពមានកូន ចំនួនកូនមធ្យមចង់បាន និង ចំនួនកូនមានជាក់ស្តែង តាមចរិតលក្ខណៈអង្កេតកម្ពុជា ឆ្នាំ២០២១ -២០២២..........................................................៣០
តារាង៣.៥.១ ចំនួនកូនធ្លាប់កើត និងកូនកំពុងនៅរស់រាន កម្ពុជា ឆ្នាំ២០២១-២០២២..........................៣១
តារាង៣.៦.១ ភាគរយស្ត្រីអាយុ ១៥-១៩ឆ្នាំធ្លាប់មានផ្ទៃពោះ យោងតាមចរិតលក្ខណៈអង្កេត កម្ពុជា ឆ្នាំ២០២១-២០២២..........................................................................................៣៥
តារាង ៣.៧.១ ចន្លោះគម្លាតកំណើតនៃស្ត្រីអាយុ ១៥-៤៩ឆ្នាំ តាមចរិតលក្ខណៈអង្កេត កម្ពុជា ឆ្នាំ ២០២១-២០២២..........................................................................................៤០
តារាង ៤.១.១ លទ្ធភាពមានកូនសរុបតាមការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតបច្ចុប្បន្នក្នុងចំណោមស្ត្រីអាយុ១៥-៤៩ឆ្នាំ តាមចរិតលក្ខណៈអង្កេតកម្ពុជា ឆ្នាំ ២០២១-២០២២.....................៤៦
តារាង ៤.២.១ លទ្ធភាពមានកូនសរុប តាមចំនួនកូនចង់បានក្នុងចំណោមស្ត្រីអាយុ១៥-៤៩ឆ្នាំ តាមចរិតលក្ខណៈអង្កេតកម្ពុជា ឆ្នាំ២០២១- ២០២២.....................................................៤៩
តារាង ៤.៣.១ លទ្ធភាពមានកូនសរុបតាមតម្រូវការសម្រាប់ផែនការគ្រួសារក្នុងចំណោមស្ត្រីអាយុ ១៥-៤៩ឆ្នាំ តាមចរិតលក្ខណៈអង្កេតកម្ពុជា ឆ្នាំ ២០២១-២០២២..................................៥៤
តារាង៥.១.១ ការថែទាំសុខភាពមុនពេលសម្រាលសម្រាប់ស្ត្រីអាយុ១៥-៤៩ឆ្នាំតាមចរិតលក្ខណៈអង្កេតកម្ពុជា ឆ្នាំ២០២១-២០២២..........................................................................៥៨
តារាង៥.២.១ ការបែងចែកភាគរយនៃកូនកើតរស់និង ឬកូនស្លាប់កើតក្នុងរយៈពេល២ឆ្នាំមុនអង្កេត តាមទីកន្លែងសម្រាល និងភាគរយការសម្រាលតាមមូលដ្ឋានសុខាភិបាលតាមចរិតលក្ខណៈអង្កេតកម្ពុជា ឆ្នាំ២០២១-២០២២...........................................................៦១
តារាង ៥.៣.១ ពេលវេលាពិនិត្យសុខភាពក្រោយពេលសម្រាលលើកដំបូងសម្រាប់ម្តាយ..........................៦៥
តារាង៥.៣.២ ពេលវេលាពិនិត្យសុខភាពក្រោយពេលសម្រាលលើកដំបូងសម្រាប់ទារកទើបកើត.............៧០
តារាង ៥.៤.១ ក្នុងចំណោមស្ត្រីអាយុ ១៥-៤៩ឆ្នាំ ដែលទទួលបានការផ្សព្វផ្សាយវីធីសាស្រពន្យារកំណើតតាមមធ្យោបាយផ្សព្វផ្សាយសង្គម តាមចរិតលក្ខណៈអង្កេតកម្ពុជា ឆ្នាំ

២០២១-២០២២.........................................................................................៧៤
តារាង ៥.៥.១ លទ្ធភាពមានកូនសរុបតាមលក្ខខណ្ឌការរស់នៅរបស់ស្ត្រីអាយុ ១៥-៤៩ឆ្នាំ......................៧៥
តារាង៥.៦.១ ការកំណត់ ការថែទាំសុខភាពមុនពេលសម្រាលក្នុងចំណោមស្ត្រីអាយុ ១៥-១៩ឆ្នាំ តាមកើតរស់ចុងក្រោយរយៈពេល៣ឆ្នាំមុនអង្កេតកម្ពុជា ឆ្នាំ២០២១-២០២២..................៧៨
តារាង៥.៦.២ ការកំណត់នៃការមានជំនួយពីមន្ត្រីជំនាញកំឡុងពេលសម្រាលសម្រាប់ស្ត្រីអាយុ ១៥-៤៩ឆ្នាំ តាមកូនកើតរស់ចុងក្រោយរយៈពេល៣ឆ្នាំមុនអង្កេតកម្ពុជា ឆ្នាំ២០២១-២០២២.............៨០

## បញ្ជីរូប


រូប ២. ១ ការបែងចែកស្ថានភាពអាពាហ៍ពិពាហ៍តាមក្រុមអាយុ កម្ពុជា ឆ្នាំ២០២១-២០២២......................៩
រូប ២.២ ការបែងចែកស្ថាភាពអាពាហ៍ពិពាហ៍តាម សាសនា កម្ពុជា ឆ្នាំ២០២១-២០២២......................១០
រូប ២.៣ ការបែងចែកស្ថានភាពអាពាហ៍ពិពាហ៍តាមកម្រិតសិក្សាអប់រំ កម្ពុជា ឆ្នាំ២០២១-២០២២.........១១
រូប ២.៤ ការបែងចែកស្ថានភាពអាពាហ៍ពិពាហ៍តាមបញ្ចភាគទ្រព្យសម្បត្តិកម្ពុជាឆ្នាំ២០២១-២០២២.....១៤
រូប ៣.១ អាយុមេដ្យានពេលរួមភេទលើកដំបូង អាយុរៀបការលើកដំបូង និងអាយុមានកូនលើកដំបូង នៃស្ត្រីអាយុ ២៥- ៤៩ ឆ្នាំ តាមទីកន្លែងរស់នៅ កម្ពុជា ឆ្នាំ២០២១-២០២២..........................១៦
រូប៣.២.១ លទ្ធភាពមានកូនតាមអាយុជាក់លាក់សម្រាប់រយៈពេល៣ឆ្នាំមុនអង្កេតតាមទីកន្លែងរស់នៅ កម្ពុជាឆ្នាំ ២០២១-២០២២.......................................................................................២១
រូប ៣.២.២ ការបែងចែកអត្រាលទ្ធភាពមានកូនដុល និងអត្រាលទ្ធភាពមានកូនទូទៅ កម្ពុជា ឆ្នាំ២០០០ ទៅឆ្នាំ២០២១-២០២២.................................................................២៣
រូប ៣.៣.១ និន្នាការនៃអត្រាលទ្ធភាពមានកូនសរុបសម្រាប់រយៈពេល ៣ឆ្នាំមុនអង្កេត តាមទីកន្លែងរស់នៅកម្ពុជាឆ្នាំ២០២១-២០២២..................................................២៤
រូប ៣.៣.២ អត្រាលទ្ធភាពមានកូនសរុបសម្រាប់រយៈពេល ៣ឆ្នាំមុនអង្កេត តាមកម្រិតសិក្សាអប់រំ កម្ពុជា ឆ្នាំ២០២១-២០២២.................................................................................២៥
រូប ៣.៣.៣ អត្រាលទ្ធភាពមានកូនសរុបសម្រាប់រយៈពេល ៣ឆ្នាំមុនអង្កេត តាមបញ្ចភាគទ្រព្យសម្បត្តិ កម្ពុជាឆ្នាំ ២០០៥ ដល់ឆ្នាំ២០២១-២០២២.........................................................២៦
រូប ៣.៤.១ លទ្ធភាពមានកូន ចំនួនកូនមធ្យមចង់បាន និងលទ្ធភាពមានកូនជាមធ្យមជាក់ស្តែង តាមទីកន្លែងរស់នៅ កម្ពុជា ឆ្នាំ២០២១-២០២២..................................................២៨
រូប ៣.៤.២ លទ្ធភាពមានកូន ចំនួនកូនមធ្យមចង់បាន និងចំនួនកូនមានជាក់ស្តែង តាមបញ្ចភាគ ទ្រព្យសម្បត្តិ កម្ពុជាឆ្នាំ២០២១-២០២២...........................................................៣០
រូប ៣.៥.១ លទ្ធភាពមានកូនពេញមួយជីវិត (កូនធ្លាប់កើត និងកូនកំពុងនៅរស់រាន) តាមទីកន្លែង រស់នៅកម្ពុជាឆ្នាំ ២០២១-២០២២.................................................................៣៥
រូប ៣.៦.១ ភាគរយស្ត្រីអាយុ១៥-១៩ឆ្នាំធ្លាប់មានផ្ទៃពោះ កម្ពុជាឆ្នាំ២០០៥ដល់ឆ្នាំ២០២១-២០២២........៣៧
រូប ៣.៧.១ ភាគរយនៃចន្លោះគម្លាតកំណើតជាខែ កម្ពុជា ឆ្នាំ២០០៥ ដល់ ឆ្នាំ២០២១-២០២២................៣៨
រូប ៣.៧.២ ភាគរយនៃចន្លោះគម្លាតកំណើតតិចជាង២៤ខែ ៦០ខែឡើង និងមេដ្យានគម្លាកំណើត កម្ពុជា ឆ្នាំ២០០៥ ដល់ឆ្នាំ២០២១-២០២២..........................................................៤០
រូប៤.១ ភាគរយបច្ចុប្បន្នប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតតាមទីកន្លែងរស់នៅ កម្ពុជា ឆ្នាំ

២០២១-២០២២......................................................................................................៤៣
រូប ៤.២ អត្រាលទ្ធភាពមានកូននៃស្ត្រីបច្ចុប្បន្នប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតតាមទីកន្លែងរស់នៅ កម្ពុជា ឆ្នាំ២០២១-២០២២ ......................................................................................៤៤
រូប ៤.៣ អត្រាលទ្ធភាពមានកូនសរុប នៃទំហំគ្រួសារចង់បាន តាមទីកន្លែងរស់នៅ កម្ពុជា ឆ្នាំ២០២១-២០២២..........................................................................................................៤៨
រូប ៤.៤ ភាគរយនៃតម្រូវការសម្រាប់ផែនការគ្រួសារតាមទីកន្លែងរស់នៅកម្ពុជា ឆ្នាំ២០២១-២០២២......៥១
រូប ៤.៥ ភាគរយនៃតម្រូវការសម្រាប់ផែនការគ្រួសារតាមកម្រិតសិក្សាអប់រំ និងបញ្ចភាគទ្រព្យសម្បត្តិ កម្ពុជា ឆ្នាំ២០២១-២០២២..............................................................................................៥៣
រូប ៤.៥ ភាគរយតម្រូវការសម្រាប់ផែនការគ្រួសារតាមបញ្ចភាគទ្រព្យសម្បត្តិ កម្ពុជា ឆ្នាំ ២០២១-២០២២......................................................................................................៥៣

# ផែនទី


ផែនទី ១ ផែនទីព្រះរាជាណាចក្រកម្ពុជា....................x

ផែនទី៣.១ អាយុមេដ្យានពេលរួមភេទលើកដំបូងក្នុងចំណោមស្ត្រីអាយុ ២៥-៤៩ឆ្នាំតាមរាជធានីខេត្ត កម្ពុជាឆ្នាំ២០២១- ២០២២....................១៧

ផែនទី៣.២ អាយុមេដ្យានរៀបការលើកដំបូងក្នុងចំណោមស្ត្រីអាយុ ២៥-៤៩ឆ្នាំតាមរាជធានីខេត្ត កម្ពុជាឆ្នាំ២០២១-២០២២....................១៧

ផែនទី ៣.៣ អាយុមេដ្យានរៀបការលើកដំបូងក្នុងចំណោមស្ត្រីអាយុ ២៥-៤៩ឆ្នាំតាមរាជធានីខេត្ត កម្ពុជាឆ្នាំ២០២១- ២០២២....................១៨

ផែនទី ៣.៤ អត្រាលទ្ធភាពមានកូនសរុប សម្រាប់រយៈពេល៣ឆ្នាំមុនអង្កេតតាមរាជធានីខេត្ត កម្ពុជា ឆ្នាំ ២០២១-២០២២....................២៧

ផែនទី៣.៥ លទ្ធភាពមានកូន តាមចំនួនកូនចង់បានជាមធ្យមតាមរាជធានីខេត្ត កម្ពុជា ឆ្នាំ២០២១-២០២២....................២៩

ផែនទី ៣.៦ លទ្ធភាពមានកូនជាក់ស្តែងជាមធ្យម តាមរាជធានីខេត្ត កម្ពុជា ឆ្នាំ២០២១-២០២២....................២៩

ផែនទី ៣.៧ ភាគរយគម្លាតកំណើតតិចជាង២៤ខែ តាមរាជធានីខេត្ត កម្ពុជា ឆ្នាំ ២០២១-២០២២....................៣៩

ផែនទី៤.១ ភាគរយប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតបែបទំនើបតាមរាជធានីខេត្ត កម្ពុជាឆ្នាំ ២០២១-២០២២....................៤៥

ផែនទី ៤.២ ភាគរយនៃតម្រូវការមិនឆ្លើយតបសម្រាប់ផែនការគ្រួសារ តាមរាជធានីខេត្ត កម្ពុជា ឆ្នាំ ២០២១-២០២២....................៥២

ផែនទី៥.១ ភាគរយស្ត្រីទទួលបានពិនិត្យសុខភាពក្រោយពេលសម្រាលអំឡុងពេល២ថ្ងៃបន្ទាប់ពីសម្រាលតាមរាជធានីខេត្ត កម្ពុជា ឆ្នាំ២០២១-២០២២....................៦៨

ផែនទី ៥.២ ភាគរយទទួលបានការពិនិត្យសុខភាពក្រោយពេលសម្រាលបន្ទាប់សម្រាលបានរយៈពេល២ថ្ងៃ តាមរាជធានីខេត្ត កម្ពុជាឆ្នាំ២០២១-២០២២....................៧៣

# ផែនទី ១ ៖ ព្រះរាជាណាចក្រកម្ពុជា



# បញ្ជីអក្សរកាត់

| | |
|---|---|
| ANC | ការពិនិត្យសុខភាពមុនពេលសម្រាល |
| ARI | ការឆ្លងមេរោគផ្លូវដង្ហើមស្រួចស្រាវ |
| ASFR | លទ្ធភាពមានកូនតាមអាយុជាក់លាក់ |
| BCG | វ៉ាក់សាំងប្រភេទ BCG |
| BMI | សន្ទស្សន៍ម៉ាសរាងកាយ |
| CAPI | ការសម្ភាសន៍ដោយប្រើកម្មវិធីជំនួយដោយកុំព្យូទ័រ |
| CBR | អត្រាកំណើតដុល |
| CDHS | អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា |
| CPR | អត្រាប្រេវ៉ាឡង់ពន្យារកំណើត |
| CSDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា |
| GAR | អត្រាអ្នកចូលរួមសរុប |
| GFR | អត្រាលទ្ធភាពមានកូនទូទៅ |
| GRR | អត្រាបន្តពូជសរុប |
| JMP | កម្មវិធីត្រួតពិនិត្យតាមដានរួមសម្រាប់ការផ្គត់ផ្គង់ទឹក និងអនាម័យ |
| MoH | ក្រសួងសុខាភិបាល |
| MTCT | ការឆ្លងពីម្ដាយទៅកូន |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| PRMR | អត្រាមរណៈភាពមាតាពាក់ព័ន្ធនឹងការមានផ្ទៃពោះ |
| PSU | ឯកតាសំណាកគម្រូចម្បង |
| PNC | ការថែទាំសុខភាពក្រោយពេលសម្រាល |
| RGC | រាជរដ្ឋាភិបាលនៃកម្ពុជា |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SDM | វិធីសាស្ត្រថ្ងៃស្តង់ដារ |
| SE | គម្លាតស្តង់ដារ |
| SE/R | ទំនាក់ទំនងគម្លាតស្តង់ដារ |
| STI | ជំងឺឆ្លងតាមការរួមភេទ |
| TAR | អត្រារំលូតកូនសរុប |

| | |
|---|---|
| TFR | អត្រាលទ្ធភាពមានកូនសរុប |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក |
| WG | Washington Group ស្តីពីស្ថិតិពិការភាព |
| WHO | អង្គការសុខភាពពិភព |

# សង្ខេប

របាយការណ៍នេះផ្តល់នូវការវិភាគយ៉ាងទូលំទូលាយអំពីអត្រាលទ្ធភាពមានកូនសរុប(TFR) នៃស្ត្រីក្នុងវ័យបន្តពូជអាយុ(១៥-៤៩)ឆ្នាំ នៅកម្ពុជាដោយប្រើទិន្នន័យអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០២១-២០២២ (CDHS)។ របាយការណ៍នេះផ្តល់ព័ត៌មានអត្រាលទ្ធភាពមានកូនសរុប(TFR) ក្នុងចំណោមស្ត្រីក្នុងវ័យបន្តពូជ ក៏ដូចជាវិសមភាពរវាងអ្នកក្របំផុត និងអ្នកមានបំផុត ("គម្លាតបញ្ចភាគទ្រព្យសម្បត្តិ") តាមចរិតលក្ខណៈប្រជាសាស្ត្រ រួមទាំងទីកន្លែងរស់នៅ រាជធានី ខេត្ត និងកម្រិតសិក្សាអប់រំ។ លើសពីនេះទៀត របាយការណ៍នេះផ្តល់នូវការវិភាគអំពីការប្រែប្រួលសូចនាករសំខាន់ៗសម្រាប់ស្ត្រី ចាប់តាំងការចាប់ផ្តើមធ្វើអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាលើកដំបូងឆ្នាំ២០០០ (CHDS)។ ការប្រែប្រួលនូវសូចនាករលទ្ធភាពមានកូនសរុប (TFR) របស់ស្ត្រីក្នុងវ័យបន្តពូជ (១៥-៤៩)ឆ្នាំ ក្នុងរយៈពេលកន្លងមក ។

ដោយសារប្រទេសកម្ពុជាកំពុងធ្វើការកែលម្អនូវប្រព័ន្ធអត្រាកុលដ្ឋាន ជំរឿន និងអង្កេតបានក្លាយជាប្រភព ដ៏មានប្រយោជន៍សម្រាប់ការវិភាគទិន្នន័យនៅលើលទ្ធភាពមានកូនសរុប(TFR)។ ដូច្នេះជំរឿន និងអង្កេតបានក្លាយទៅជាប្រភពសំខាន់សម្រាប់ការប៉ាន់ប្រមាណប្រជាសាស្ត្រនៅកម្ពុជា ដូចនៅប្រទេសដ៏ទៃទៀតដែលមានប្រព័ន្ធអត្រាកុលដ្ឋាននៅខ្វះខាត។ ដូច្នេះបច្ចេកទេសប្រជាសាស្ត្រផ្សេងៗគ្នាចាំបាច់ត្រូវបានយកមកអនុវត្តន៍សម្រាប់ការប៉ាន់ប្រមាណលទ្ធភាពមានកូនពីទិន្នន័យដែលប្រមូលបាននៅក្នុងអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា(CDHS)។ ការប៉ាន់ប្រមាណនៃលទ្ធភាពមានកូនដោយផ្អែកលើទិន្នន័យ(CDHS) ២០២១-២០២២ គួរតែត្រូវបានបកស្រាយចង្អុលបង្ហាញអំពីនិន្នាការនៅក្នុងប៉ារ៉ាម៉ែត្រប្រជាសាស្ត្រទាំងនេះ និងជួរដែលតម្លៃនៃប៉ារ៉ាម៉ែត្រអាចលំអៀង។

- ភាគច្រើនស្ត្រីវ័យក្មេងអាយុ ១៥-១៩ឆ្នាំ មិនដែលបានរៀបការ(៨៨,២%)។ សមាមាត្រមិនដែលរៀបការបានធ្លាក់ចុះយ៉ាងតាមក្រុមអាយុ។ ភាគរយកើនឡើងតាមក្រុមអាយុរហូតដល់អាយុ៤០-៤៤ឆ្នាំ មាន ៨៦,៣% នៃស្ត្រីបានរៀបការបន្ទាប់ពីនោះភាគរយចាប់ផ្តើមធ្លាក់ចុះបន្តិចមកវិញ។ ភាគរយស្ត្រីមេម៉ាយកើនឡើងតាមអាយុដែលឈានដល់ភាគរយខ្ពស់ធៀបនឹងក្រុមអាយុចាស់។ ចំនួនពេលវេលាជាមធ្យមនៅលីវនៅទីប្រជុំជនមានខ្ពស់ជាងនៅតំបន់ជនបទ។
- មេដ្យានអាយុរៀបការដំបូងក្នុងចំណោមស្ត្រីអាយុ ១៥-៤៩ឆ្នាំ គឺ ២១,៥ឆ្នាំ កើនឡើងមួយឆ្នាំបើធៀបនឹង ២០,៥ឆ្នាំ ក្នុងឆ្នាំ២០១៤ ។
- មេដ្យានអាយុរួមភេទលើកដំបូងក្នុងចំណោមស្ត្រីក្រុមអាយុ ១៥-៤៩ឆ្នាំ នៅកម្ពុជាគឺ ២១,៤ឆ្នាំ។ មានភាពខុសប្លែកគ្នាយ៉ាងខ្លាំងនៃមេដ្យានអាយុរួមភេទលើកដំបូងក្នុងចំណោមស្ត្រីអាយុ២៥-៤៩ឆ្នាំ តាមទីកន្លែងរស់នៅ ស្ត្រីអាយុ១៥-៤៩ឆ្នាំ នៅជនបទចាប់ផ្តើមរួមភេទ ១,៣ឆ្នាំឆាប់ជាងស្ត្រីអាយុ១៥-៤៩ ឆ្នាំនៅទីប្រជុំជន។

- មេដ្យានអាយុចាប់ផ្តើមបង្កើតកូន គឺជាកត្តាកំណត់ដ៏សំខាន់នៃកម្រិតការមានកូន ក៏ដូចជាសុខភាពនិងសុខុមាលភាពរបស់ម្តាយ និងកូន។ នៅកម្ពុជាមេដ្យានអាយុមានកូនដំបូងក្នុងចំណោមស្ត្រីអាយុ១៥-៤៩ឆ្នាំ គឺ ២៣,៣ ឆ្នាំ។
- អត្រាលទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់នៅក្រុមអាយុ១៥-១៩ឆ្នាំ គឺ៤៨កំណើតក្នុង ១.០០០ស្ត្រី អត្រាខ្ពស់បំផុតគឺនៅក្នុងក្រុមអាយុ ២០-២៤ឆ្នាំ (១៥៤ កំណើតក្នុងស្ត្រី១.០០០នាក់) និងបានធ្លាក់ចុះបន្តបន្ទាប់មកត្រឹមតែ ៣កំណើតក្នុងចំណោមស្ត្រីក្រុមអាយុ៤៥-៤៩ឆ្នាំ ១.០០០នាក់។ ការធ្លាក់ចុះនៃ (ASFR)មានការកត់សម្គាល់ចាប់ពីឆ្នាំដំបូងបំផុតដល់ឆ្នាំការអង្កេតចុងក្រោយនេះ។ ទោះជាយ៉ាងណាក៏ដោយការធ្លាក់ចុះនៃ(ASFR)ក្នុងឆ្នាំ២០០០ និង ២០២១-២០២២ មានតិចតួចក្នុងចំណោមក្រុមអាយុក្មេង(១៥-២៤ឆ្នាំ)និងក្រុមអាយុចាស់(៣៥-៤៩ឆ្នាំ) ខណៈដែលការធ្លាក់ចុះយ៉ាងខ្លាំងត្រូវបានគេសង្កេតឃើញក្នុងចំណោមក្រុមមនុស្សវ័យកណ្តាល(២៥-៣៤ឆ្នាំ)។
- ការប៉ាន់ប្រមាណដែលទទួលបាន អាចសន្និដ្ឋានបានថាអត្រាលទ្ធភាពមានកូនសរុប(TFR)សម្រាប់ រយៈពេល៣ឆ្នាំមុនអង្កេតគឺ ២,៧ (២,៤ នៅទីប្រជុំជន និង ៣,០នៅជនបទ)។ រវាងឆ្នាំ២០០៥ និង ២០២១-២០២២ អត្រាលទ្ធភាពមានកូនសរុប(TFR) បានធ្លាក់ចុះស្ទើរតែម្នាក់(០,៧) (TFR ៣,៤ ក្នុងឆ្នាំ២០០៥ ដល់ ២,៧ ក្នុងឆ្នាំ២០២១-២០២២)។
- អត្រាលទ្ធភាពមានកូនសរុប (TFR) ធ្លាក់ចុះជាមួយនឹងការកើនឡើងនៃកម្រិតសិក្សាអប់រំ ពី ៣,៤ នាក់ក្នុងចំណោមស្ត្រីមិនបានចូលរៀន មក២,៤នាក់ក្នុងចំណោមស្ត្រីដែលទទួលបានកម្រិតសិក្សាអប់រំលើសពីមធ្យមសិក្សា។
- អត្រាលទ្ធភាពមានកូនសរុប(TFR)ក៏មានកម្រិតខុសគ្នាតាមទ្រព្យសម្បត្តិគ្រួសារផងដែរ។ ក្នុងចំណោម ស្ត្រីមានបញ្ចភាគទ្រព្យសម្បត្តិទាបបំផុត អត្រាលទ្ធភាពមានកូនសរុប (TFR) មាន ៣,៥នាក់ និងក្នុងចំណោមស្ត្រីមានបញ្ចភាគទ្រព្យសម្បត្តិខ្ពស់បំផុត (TFR) មាន ២,២នាក់ ។
- CBR បច្ចុប្បន្នគឺ ២០,២ ក្នុង ស្ត្រី ១.០០០នាក់សម្រាប់រយៈពេល ៥ឆ្នាំមុនពេលអង្កេត។ CBR និង GFR បានធ្លាក់ចុះយ៉ាងឆាប់រហ័សពី (២៧,៧ និង ១២៩,០) ក្នុងស្ត្រី ១.០០០នាក់ ក្នុង ឆ្នាំ២០០០ មកត្រឹម (២០,២ និង ៩៣,៧) ក្នុងស្ត្រី ១.០០០នាក់ ក្នុងឆ្នាំ២០២១-២០២២ ។
- អត្រាលទ្ធភាពមានកូនជាមធ្យមផ្អែកលើបំណងចង់បានកូនរបស់ស្ត្រីនៅកម្ពុជាគឺ ២.៨ ក្នុងស្ត្រីម្នាក់ បើធៀបនឹងអត្រាមានកូនសរុបពិតប្រាកដ២.៧ និងកូនមធ្យមដែលធ្លាប់បង្កើតមាន ៣.០ ក្នុងស្ត្រីម្នាក់នៅចុងបញ្ចប់នៃអាយុបន្តពូជ។ គម្លាតរវាងអត្រាមានកូនពិតប្រាកដ និងចង់បានគឺ ០.១ ក្នុងចំណោមស្ត្រីអាយុ១៥-៤៩ឆ្នាំនៅជនបទ ធៀបនឹង ០.២ក្នុងចំណោមស្ត្រីនៅទីប្រជុំជន ។
- ប្រាំបួនភាគរយនៃស្ត្រីអាយុ ១៥-១៩ឆ្នាំធ្លាប់មានផ្ទៃពោះ។ ភាគរយនៃស្ត្រី អាយុ១៥-១៩ឆ្នាំ ដែលធ្លាប់មានផ្ទៃពោះបានធ្លាក់ចុះចាប់តាំងពីឆ្នាំ២០១៤ ពី១២% មក ៩%។ ភាគរយស្ត្រី អាយុ១៥-៤៩ឆ្នាំដែលធ្លាប់មានផ្ទៃពោះមានភាពខុសគ្នាតាមកម្រិតសិក្សាអប់រំ។ ការមានផ្ទៃពោះក្នុងវ័យជំទង់ជាទូទៅមានភាគរយ

ទាបក្នុងគ្រួសារមានបញ្ញាភាគទ្រព្យសម្បត្តិខ្ពស់បំផុត (៤%នៃស្ត្រីដែលមានបញ្ញាភាគទ្រព្យសម្បត្តិខ្ពស់បំផុតបានចាប់ផ្តើមមានកូនបើធៀបនឹង១៦%មានបញ្ញាភាគទ្រព្យសម្បត្តិទាបបំផុត)។

- គម្លាតរវាងការមានកូនពិតប្រាកដ និងអត្រាចង់បានកូនគឺមានខ្ពស់ជាងក្នុងចំណោមស្ត្រីដែលមិនមចូលសាលារៀន (០,៣) ជាងស្ត្រីដែលមានកម្រិតសិក្សាអប់រំលើសពីមធ្យមសិក្សា (០,១)។ កម្រិតការចង់បានកូនបានធ្លាក់ចុះជាមួយនឹងការកើនឡើងនៃទ្រព្យសម្បត្តិ ក៏ដូចជាគម្លាតរវាងការមានកូនពិតប្រាកដ និងអត្រាចង់បានផងដែរ។
- គម្លាតកំណើតខ្លីប៉ះពាល់ជាអវិជ្ជមានដល់សុខភាពទាំងម្តាយ និងទារកនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (គោលដៅទី៣) មានគោលបំណងកាត់បន្ថយអត្រាមរណមាតា និងកុមារអាយុក្រោម៥ឆ្នាំនៅឆ្នាំ២០៣០។ មេដ្យានគម្លាតកំណើត រវាងកំណើតពីមុននៅកម្ពុជា គឺ ៥៤,១ ខែ។ ១១% នៃកំណើតបានកើតឡើងតិចជាង ២៤ខែបន្ទាប់ពីកំណើតមុន ១៦% កើតឡើងពី ២៤-៣៥ ខែបន្ទាប់ពីកំណើតមុន និង១៦% ផ្សេងទៀតកើតឡើង ៣៦-៤៧ខែ បន្ទាប់ពីកំណើតមុន។
- អត្រាប្រេវ៉ាឡង់នៃការពន្យារកំណើត (CPR) មាន ៦២% នៃស្ត្រី១៥-៤៩ ឆ្នាំ បច្ចុប្បន្នរៀបការរួច។ ស្ទើរតែពាក់កណ្តាល (៤៥%) នៃស្ត្រីបច្ចុប្បន្នរៀបការរួច ប្រើវិធីសាស្ត្រពន្យារកំណើតបែបទំនើប និង ១៧% ប្រើវិធីសាស្ត្របែបបុរាណ។ សម្រាប់ស្ត្រី ដែលបច្ចុប្បន្នកំពុងប្រើវិធីពន្យារកំណើតណាមួយមាន អត្រាលទ្ធភាពមានកូនសរុប(TFR)មានខ្ពស់(៤,៧នាក់ក្នុងស្ត្រីម្នាក់) បើប្រៀបធៀបទៅនឹងស្ត្រីដែលមិនទាន់ប្រើវិធីពន្យារកំណើត(២,០នាក់ក្នុងស្ត្រីម្នាក់)។ នេះបង្ហាញថាស្ត្រីចាប់ផ្តើមប្រើវិធីពន្យារកំណើតនៅពេលដែលពួកគាត់មានកូនច្រើន។
- ជាមធ្យម ស្ត្រីម្នាក់ចង់បានចំនួនកូន (២,៨នាក់)។ នេះក៏ជាការពិតផងដែរក្នុងចំណោមស្ត្រីបច្ចុប្បន្នរៀបការរួច(៣,០នាក់និង៣,១នាក់រៀងគ្នា)។ ស្ត្រីដែលមិនចង់មានកូនប៉ុន្តែមានចំនួនកូនពិតប្រាកដមានកូន ២,០នាក់ ។ ចំពោះស្ត្រីដែលចង់បានកូនមួយឬពីរនាក់ មានកូនជាក់ស្តែង ២,៥ នាក់។ ដោយឡែកស្ត្រីដែលចង់បានកូនពី ៣ទៅ៤នាក់ ក្នុងចំណោមស្ត្រីនោះមានកូនជាក់ស្តែង៣នាក់។ ចំណែកឯស្ត្រីដែលចង់មានកូនចាប់ពី៥នាក់ឡើង មានចំនួនកូនជាក់ស្តែង៣,៥នាក់។ ការចង់បានចំនួនកូនស្ត្រីនៅទីប្រជុំជនមានកម្រិតទាបជាងនៅជនបទ ។
- ស្ទើរតែបីភាគបួននៃស្ត្រីដែលបច្ចុប្បន្នរៀបការរួចអាយុ១៥-៤៩ឆ្នាំ មានតម្រូវការសម្រាប់ការធ្វើផែនការគ្រួសារ។ ១២ភាគរយ មានតម្រូវការមិនបានឆ្លើយតប និង៦២ភាគរយមានតម្រូវការឆ្លើយតបសម្រាប់ផែនការគ្រួសារ។ ហុកសិបពីរភាគរយនៃស្ត្រីបច្ចុប្បន្នរៀបការរួច បានប្រើវិធីពន្យារកំណើត ដូច្នេះស្ត្រីទាំងនោះមានតម្រូវការឆ្លើយតបសម្រាប់ផែនការគ្រួសារ។ តម្រូវការមិនឆ្លើយតបក្នុងការកំណត់គម្លាតកូនធ្លាក់ចុះតាមអាយុគឺពី១៤% ក្នុងចំណោមស្ត្រីបច្ចុប្បន្នរៀបការរួចអាយុ១៥-១៩ឆ្នាំ មក១% ក្នុងចំណោមស្ត្រីអាយុ៤៥-៤៩ឆ្នាំ។ទិន្នន័យបង្ហាញថាស្ត្រីដែលមានតម្រូវការមិនឆ្លើយតបសម្រាប់គ្រួសារមានកូនតិចជាងស្ត្រីដែលមានតម្រូវការបានឆ្លើយតបសម្រាប់ផែនការគ្រួសារ (២,៩នាក់ទល់នឹង៤,១នាក់រៀងគ្នា)។

- ការសម្រាលកូនតាមមូលដ្ឋានសុខាភិបាលបង្កើនឱកាសការសម្រាលដោយមន្ត្រីមានវិជ្ជាជីវៈ ក៏ដូចជាការបង្កើនលទ្ធភាពទទួលបានឧបករណ៍ និងការផ្គត់ផ្គង់ចាំបាច់របស់ម្តាយ។ សរុបមក ៩៨% នៃកូនកើតរស់ និងកូនស្លាប់កើត ក្នុងរយៈពេល២ឆ្នាំមុនអង្កេតបានសម្រាលនៅតាមមូលដ្ឋានសុខាភិបាល។ ចិតសិបប្រាំបីភាគរយនៃកូនកើតរស់ និងស្លាប់កើតបានសម្រាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ ខណៈដែលមានត្រឹមតែ១,៧%សម្រាលនៅផ្ទះ។ ទិន្នន័យបង្ហាញថាម្តាយដែលមិនបានចូលរៀនការសម្រាលនៅផ្ទះ និងតាមមូលដ្ឋានសុខាភិបាលផ្សេងទៀត បើធៀបនឹងអ្នកស្ត្រីទទួលបានកម្រិតសិក្សាអប់រំខ្ពស់ជាងមធ្យមសិក្សាគឺមិនមានទេ។ ភាគរយការសម្រាលតាមមូលដ្ឋានសុខាភិបាលសាធារណៈមានភាពខុសគ្នាតាមស្ថានភាពបញ្ចភាគទ្រព្យសម្បត្តិ ។
- ស្ត្រីចំនួន ៨៤% បានទទួលការថែទាំសុខភាពក្រោយសម្រាលដំបូងរយៈពេលពីរថ្ងៃបន្ទាប់ពីការសម្រាលដោយ ៥៩,៩% បានទទួលការថែទាំសុខភាពក្នុងរយៈពេល ៤ម៉ោងបន្ទាប់ពីសម្រាល ហើយមានតែ ៩% ប៉ុណ្ណោះដែលមិនបានទទួលការថែទាំសុខភាពក្រោយសម្រាល។ ទាំងទីប្រជុំជន និងជនបទភាគរយ នៃស្ត្រីបានទទួលការពិនិត្យសុខភាពដំបូងរយៈពេល៤ម៉ោងបន្ទាប់ពីការសម្រាលមានកម្រិតខ្ពស់។
- ប្រព័ន្ធផ្សព្វផ្សាយ និងការបោះពុម្ពផ្សាយមានសារៈសំខាន់ ព្រោះវាផ្តល់នូវការបង្ហាញដល់ស្ត្រីចំពោះប្រព័ន្ធផ្សព្វផ្សាយធំៗដែលអាចត្រូវបានប្រើដើម្បីផ្សព្វផ្សាយផែនការគ្រួសារ ព័ត៌មានសុខភាព និងផ្សេងទៀតដើម្បីកាត់បន្ថយលទ្ធភាពមានកូនសរុប (TFR) ។
- ដូចដែលបានរំពឹងទុកស្ត្រីគ្មានការងារធ្វើ អត្រាលទ្ធភាពមានកូនខ្ពស់ជាងស្ត្រីដែលមានការងារធ្វើណាមួយ និងស្ត្រីដែលមានទីកបរិភោគកែលម្អ កម្រិតលទ្ធភាពមានកូនមានទាប (មានករណីលើកលែងមួយចំនួន)។ លទ្ធភាពមានកូនរបស់ស្ត្រីក្នុងកម្លាំងពលកម្មមានទាបជាងស្ត្រីអសកម្មខាងសេដ្ឋកិច្ច។ ក្នុងចំណោមស្ត្រីសកម្មសេដ្ឋកិច្ច ការធ្វើការងារគ្រួសារមិនបានទទួលប្រាក់ឈ្នួល និង "ការងារផ្ទាល់ខ្លួន" បង្ហាញពីកម្រិតនៃលទ្ធភាពមានកូនខ្ពស់បំផុត។ ស្ត្រីរស់នៅក្នុងគ្រួសារដែល ស្ត្រីជាមេគ្រួសារលទ្ធភាពមានកូនខ្ពស់ជាង ស្ត្រីក្នុងគ្រួសារដែលបុរសជាមេគ្រួសារ។ ជាចុងក្រោយស្ត្រីរស់នៅក្នុងលំនៅដ្ឋានដែលមានភ្លើងអគ្គិសនី និងប្រើប្រាស់អ៊ីនធឺណិត អត្រាលទ្ធភាពមានកូនទាបជាងស្ត្រីរស់នៅក្នុងលំនៅដ្ឋានដែលមិនមានសេវាទាំងនេះ។
- ទីកន្លែងរស់នៅរបស់ស្ត្រី កម្រិតសិក្សាអប់រំរបស់ម្តាយ កម្រិតសិក្សាអប់រំរបស់ឪពុក គម្លាតកំណើត មូលដ្ឋានសុខាភិបាល និងបញ្ចភាគទ្រព្យសម្បត្តិ ដើរតួយ៉ាងសំខាន់សម្រាប់ការសម្រេចចិត្តរបស់ស្ត្រីដើម្បីស្វែងរកអ្នកផ្តល់ជំនាញសម្រាប់ពិនិត្យសុខភាពក្រោយពេលសម្រាល (ANC) ។ កម្រិតសិក្សាអប់រំរបស់ឪពុក គម្លាតកំណើត មូលដ្ឋានសុខាភិបាល និងបញ្ចភាគទ្រព្យសម្បត្តិ ដើរតួនាទីអវិជ្ជមានលើការទទួលបានអ្នកផ្តល់ជំនាញសម្រាប់ពិនិត្យសុខភាពក្រោយពេលសម្រាល (ANC) ។

# ជំពូក១

# សេចក្តីផ្តើម

លទ្ធភាពមានកូន សំដៅលើចំនួនកូនកើតរស់ដែលស្ត្រីម្នាក់មានក្នុងជីវិតរបស់គាត់ ។ មានភាពខុសគ្នានៃសមត្ថភាព ជីវសេរីរាង្គរបស់ស្ត្រីក្នុងការបន្តពូជ។ លទ្ធភាពមានកូនត្រូវបានកំណត់ដោយផ្ទាល់នៃកត្តាប្រជាសាស្ត្រមួយដែលហៅថាអថេរកម្រិតមធ្យម (អាយុនៅពេលរៀបការ ការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើត រយៈពេលនៃការបំបៅកូនដោយទឹកដោះម្តាយ។ល។)។ កត្តាទាំងនេះជះឥទ្ធិពលដោយកត្តាសង្គម វប្បធម៌ បរិស្ថាន សេដ្ឋកិច្ច និងកត្តាសុខភាពផ្សេងទៀត។

ទិន្នន័យនៃលទ្ធភាពមានកូនបច្ចុប្បន្នជាត្រូវបានប្រមូលដោយប្រព័ន្ធស្ថិតិអត្រាកុលដ្ឋាន តាមរយៈការចុះបញ្ជីកំណើត ។ បើទិន្នន័យមិនត្រូវបានប្រមូល ឬប្រមូលមិនពេញលេញ (ដូចនៅកម្ពុជា) ជំរឿនគឺជាប្រភពសំខាន់សម្រាប់គោលបំណងនេះ។ អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ ២០០០ ២០០៥ ២០១០ ២០១៤ និងឆ្នាំ ២០២១-២២ បានវាស់វែងអំពីលទ្ធភាពមានកូនបច្ចុប្បន្នតាមការប្រមូលទិន្នន័យលើកុមារដែលកើតក្នុងអំឡុងពេល៣៦ខែ មុនកាលបរិច្ឆេទអង្កេត (តាមក្រុមអាយុស្ត្រី)។ លទ្ធផលអង្កេតនេះអាចគណនាអត្រាលទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់ (ASFR) និងអត្រាលទ្ធភាពមានកូនសរុប (TFR)។

សុខភាពមាតាសំដៅលើសុខភាពរបស់ស្ត្រីអំឡុងពេលមានផ្ទៃពោះពេលសម្រាលកូន និងក្រោយពេលសម្រាល។ ដំណាក់កាលនីមួយៗជាបទពិសោធន៍វិជ្ជមាន ដែលធានាថាស្ត្រី និងទារកអាចសក្តានុពលពេញលេញចំពោះសុខភាព និងសុខុមាលភាពស្ត្រី និងទារក។ ការស្លាប់របស់មាតាភាគច្រើនគឺអាចបង្ការ បានដោយដោះស្រាយទាំសុខភាពដើម្បីការពារ ឬគ្រប់គ្រងផលវិបាក។ ស្ត្រីទាំងអស់ត្រូវទទួលបានការថែទាំសុខភាពដែលមានគុណភាពខ្ពស់ក្នុងអំឡុងពេលមានផ្ទៃពោះ និងក្រោយពេលសម្រាល។ សុខភាពមាតា និងទារកទើបនឹងកើត មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ។ មានសារៈសំខាន់ជាពិសេសដែលការសម្រាលកូនដោយអ្នកជំនាញវិជ្ជាជីវៈ សុខាភិបាល ព្រោះការគ្រប់គ្រង និងការព្យាបាលទាន់ពេលវេលាអាចធ្វើឱ្យមានភាពរស់រាន និងការស្លាប់សម្រាប់ម្តាយ និងទារកផងដែរ។

## ១.១. គម្រូវការសិក្សា

របាយការណ៍លទ្ធភាពមានកូន និងសុខភាពបន្តពូជនៅកម្ពុជាត្រូវបានរៀបចំឡើងដោយវិទ្យាស្ថានជាតិស្ថិតិ (NIS) ក្រសួងផែនការសហការជាមួយក្រសួងសុខាភិបាល ដោយបានផ្តល់ជំនួយបច្ចេកទេស និងជំនួយហិរញ្ញវត្ថុពីអង្គការ Vital Strategies។ លទ្ធភាពមានកូន និងសុខភាពបន្តពូជស្ត្រីនៅកម្ពុជាមានសារៈសំខាន់ណាស់សម្រាប់ផ្តល់ព័ត៌មានស្តីពីការថែទាំសុខភាពបន្តពូជ និងមាតានៅកម្ពុជា។ វាក៏ផ្តល់នូវបច្ចុប្បន្នភាព ការប៉ាន់ប្រមាណជាមូលដ្ឋានទាក់ទងនឹងលទ្ធភាពមានកូន សូចនាករថែទាំសុខភាពមាតា និងទារក និងការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើត ការរៀបចំផែនការគ្រួសារ និងបញ្ហាសុខភាពផ្សេងទៀត។

## ១.២. គោលបំណងអង្កេត

គោលបំណងសំខាន់នៃរបាយការណ៍វិភាគលើប្រធានបទស្តីពីលទ្ធភាពមានកូន និងសុខភាពបន្តពូជស្ត្រីនៅកម្ពុជាប្រើប្រាស់ទិន្នន័យសេរីទិន្នន័យអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា(CDHS) ឆ្នាំ២០០០ ២០០៥ ២០១០ ២០១៤ និងឆ្នាំ២០២១-២២ គឺដើម្បីកំណត់អំពីលទ្ធភាពមានកូន និងការថែទាំសុខភាពស្ត្រី។ លើសពីនេះទៀតបានផ្តល់ព័ត៌មានស្តីពីការផ្លាស់ប្តូររចនាសម្ព័ន្ធគ្រួសារ ទំនាក់ទំនង/កុមារ ដែលរងឥទ្ធិពលលើលទ្ធភាពមានកូន និងការថែទាំសុខភាព។ របាយការណ៍វិភាគស៊ីជម្រៅនេះមានគោលបំណងផ្តល់នូវព័ត៌មានសំខាន់ៗដូចខាងក្រោមដូចជា៖

- វិភាគអំពីលទ្ធភាពមានកូន និងភាពខុសគ្នាតាមចរិតលក្ខណៈអង្កេតរួមមាន ទីកន្លែងរស់នៅ រាជធានី ខេត្ត កម្រិតសិក្សាអប់រំ និងសន្ទស្សន៍បញ្ចភាគទ្រព្យសម្បត្តិ ។
- ផ្តល់នូវការប៉ាន់ស្មាននៃអត្រាកំណើតដុល(CBR)អត្រាលទ្ធភាពមានកូនទូទៅ (GFR) អត្រាលទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់ (ASFR) អត្រាលទ្ធភាពមានកូនសរុប (TFR) តាមកន្លែងរស់នៅ រាជធានី ខេត្ត កម្រិតសិក្សាអប់រំ និងសន្ទស្សន៍បញ្ចភាគទ្រព្យសម្បត្តិ។
- ផ្តល់ព័ត៌មានទាក់ទងនឹងការថែទាំសុខភាពមាតាតាមទីន្លែងរស់នៅរាជធានី ខេត្ត កម្រិតសិក្សាអប់រំ និងសន្ទស្សន៍បញ្ចភាគទ្រព្យសម្បត្តិ។

## ១.៣. ប្រភពទិន្នន័យ

ការអង្កេតប្រជាសាស្ត្រ និងសុខភាព(CDHS)ឆ្នាំ២០២១-២០២២ គឺត្រូវបានប្រមូលដោយវិទ្យាស្ថានជាតិ ស្ថិតិ (NIS) សហប្រតិបត្តិការជាមួយក្រសួងសុខាភិបាល (MOH) ។ ការប្រមូលទិន្នន័យនេះអនុវត្តន៍ពីថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២១ដល់ថ្ងៃទី១៥ ខែកុម្ភៈឆ្នាំ២០២២។ ថវិកាស្ទើរតែទាំងស្រុងគាំទ្រដោយរាជរដ្ឋាភិបាល កម្ពុជាតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ICF បានផ្តល់ជំនួយផ្នែកបច្ចេទេសតាមរយៈកម្មវិធី (DHS) ដែលផ្តល់មូនិធិដោយទីភ្នាក់ងារសហប្រជាជាតិសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងការគាំទ្រផ្នែក ហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសសម្រាប់ប្រជាជន និងអង្កេតសុខភាពតាមប្រទេសនានាក្នុងពិភពលោក។ ទីភ្នាក់ងារ និងអង្គការអន្តរជាតិផ្សេងទៀតបានសម្របសម្រួលដើម្បីសម្រេចជោគជ័យការអង្កេតនេះតាមរយៈការគាំទ្រជាហិរញ្ញវត្ថុ និងបច្ចេកទេសគឺមានទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអាល្លឺម៉ង់ (GIZ) ជំនួយអូស្ត្រាលី (Austalia Aids) អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន(UNFPA) មូលនិធិសហប្រជាជាតិសម្រាប់កុមារ (UNICEF) ជំនួយអូស្ត្រាលីតាមរយៈកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងកម្មវិធីស្បៀងអាហារពិភពលោក (WFP)។

ទិន្នន័យអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២ (CDHS) និងសេរីអង្កេត (CDHS) មុនៗគឺជាប្រភពយ៉ាងសំខាន់សម្រាប់ការវិភាគរបាយការណ៍នេះ។ ប្រភពទិន្ន័យផ្សេងទៀតដូចជាទិន្ន័យអង្កេត ដែល

មានស្រាប់ត្រូវបានយកមកប្រើប្រាស់ផងដែរ ។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២ (CDHS) គ្របដណ្តប់តំណាងថ្នាក់ជាតិដែលគ្របដណ្តប់សំណាកគំរូស្ត្រីចំនួន១៩,៤៩៦នាក់ មានអាយុ១៥-៤៩ឆ្នាំ។

## ១.៤. វិធីសាស្ត្រអង្កេត

ទិន្នន័យស្តីពីលទ្ធភាពមានកូនបានប្រមូលពីប្រភពជំរឿនប្រជាជន និងអង្កេតនានា។ ជាដំបូង រាល់ស្ត្រីវ័យបន្តពូជអាយុ (១៥-៤៩ឆ្នាំ) ត្រូវបានសួរអំពីចំនួនកូនដែលបានបង្កើត (កូនប្រុស និងកូនស្រី)ដែលរស់នៅជាមួយគាត់ ចំនួនកូនដែលរស់នៅកន្លែងផ្សេង និងចំនួនកូនដែលកើតតែក្រោយមកបានស្លាប់។ ទីពីរ ប្រវត្តិកំណើតគ្រប់ស្ត្រីត្រូវបានប្រមូលរួមមាន ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត អាយុ និងស្ថានភាពរស់រានមានជីវិតសម្រាប់កូននីមួយៗ។ សម្រាប់កូនដែលកំពុងរស់នៅ សំណួរត្រូវបានសួរអំពី តើគាត់កំពុងរស់នៅក្នុងគ្រួសារ ឬរស់នៅកន្លែងផ្សេង។ សម្រាប់កុមារដែលបានស្លាប់អាយុត្រូវបានកត់ត្រា។ ជាចុងបញ្ចប់ព័ត៌មានការមាន ផ្ទៃពោះនៅពេលអង្កេតត្រូវបានប្រមូល ។

ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២ ព័ត៌មានស្តីពីការចង់បានកូន ត្រូវបានសួរទាំងស្ត្រី និងបុរសជាបន្តបន្ទាប់រួមមាន ចង់បានកូនផ្សេងទៀតឬទេ រយៈពេលប៉ុន្មានដែលរង់ចាំឱ្យមានកូនម្នាក់ទៀត និងការសម្រេចចិត្តការចង់បានចំនួនកូន។ ទិន្នន័យបានមកពីអង្កេតប្រជាសាស្ត្រ និងសុខភាពចុងក្រោយគឺត្រូវបានប្រើប្រាស់។ ការគណនានូវសូចនាករណ៍គឺអនុវត្តន៍តាមការវាស់វែងម៉ូដែលបរិបទកម្ពុជា នៃច្បាប់ការធ្វើវិលូត និងការប៉ាន់ស្មានពីមុនៗសម្រាប់ថ្នាក់ក្រោមជាតិ និងតាមរាជធានី ខេត្ត អាយុ កម្រិតសិក្សាអប់រំ កន្លែងរស់នៅ និងស្ថានភាពបញ្ចាភាគទ្រព្យសម្បត្តិ ។

ការវាស់វែងអំពីលទ្ធភាពមានកូនត្រូវបានប្រើប្រាស់ជាអត្រាបន្តពូជជំនួសសរុប (GRR) អត្រាលទ្ធភាពមានកូនទូទៅ(GFR) អត្រាលទ្ធភាពមានកូនសរុប (TFR) និង អត្រាកំណើតដុល (CBR) ។ លទ្ធភាពមានកូនសរុប (TFR) ត្រូវបានគណនាដូចខាងក្រោម ៖

១. ចំនួនកំណើតរស់ក្នុងរយៈពេល 0-៣៦ខែចុងក្រោយ តាមក្រុមអាយុម្តាយ

២. ចំនួនស្ត្រី សរុបក្នុងឆ្នាំយោង ( Years of exposure) ក្នុងរយៈពេល 0-៣៦ ខែចុងក្រោយតាមក្រុមអាយុម្តាយ

៣. ចែកចំនួនកំណើតរស់នឹងចំនួនស្ត្រីតាមក្រុមអាយុនីមួយៗ និងគុណចំនួន ១០០ ដើម្បីទទួលបានអត្រាលទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់ (ASFRs)

៤. អត្រាលទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់(ASFRs)គុណនឹង៥(គម្លាតអាយុ៥ឆ្នាំនៃអាយុម្តាយ)

៥. បូកអត្រាលទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់ចែកចំនួន ១០០ យើងទទួលបានអត្រាលទ្ធមានកូនសរុប (TFR)។

ការវិភាគសមីការពហុទំនាក់ទំនង (Multinomial logistic regression)ត្រូវបានធ្វើផងដែរដើម្បីពិនិត្យ ពីទំនាក់ទំនងរវាងការចំណាយថែទាំសុខភាព និងចរិតលក្ខណៈស្ត្រី ។ អថេរឯករាជ្យត្រូវបានប្រើប្រាស់ជាតម្លៃពីរ (Dichotomic) វាស់វែងការពិនិត្យសុខភាពមុនពេលសម្រាល (ANC) (មិនបានទទួលការពិនិត្យ ឬតិចជាង៣ដង=0 និងច្រើនជាង ៤ដង=១) និងអ្នកផ្តល់សេវាជំនាញវិជ្ជាជីវៈនៅពេលសម្រាល (មិនបានផ្តល់សេវាដោយអ្នកជំនាញវិជ្ជាជីវៈ=0 និងទទួលបានសេវាជំនាញវិជ្ជាជីវៈនៅពេលសម្រាល=១)។ អថេរអាស្រ័យរួមមានអាយុម្តាយ ទីកន្លែងរស់នៅ កម្រិតអប់រំម្តាយ កម្រិតអប់រំឪពុក ស្ថានភាពការងារម្តាយ ចំនួនកូនចង់បាន លំដាប់កំណើត គម្លាតកំណើត អ្នកផ្តល់សេវាការពិនិត្យសុខភាពមុនពេលសម្រាល (ANC ) ការទទួលបានព័ត៌មានតាមមូលដ្ឋានសុខាភិបាល និងបញ្ចភាគទ្រព្យសម្បត្តិ។ ម៉ូដែលគណនាការប៉ាន់ស្មានចំនួនមេគុណ អថេរឯករាជ្យនិមួយៗពន្យល់ពីភាពខុសគ្នានៃអថេរអាស្រ័យ។ វិធីសាស្ត្រនេះមិនល្អឥតខ្ចោះទេហើយពាក់ព័ន្ធនឹងការសន្មត់សំខាន់ៗជាច្រើនដើម្បីជ្រើសរើសអថេរប៉ាន់ប្រមាណមេគុណតម្រែតម្រង់ និងពន្យល់ពីឥទ្ធិពលរបស់វាទៅលើលទ្ធផលនិងការបកស្រាយ។

## ១.៥. រចនាសម្ព័ន្ធរបាយការណ៍

របាយការណ៍នេះរួមមានការពិពណ៌នាពីចរិតលក្ខណៈសេដ្ឋកិច្ចសង្គមរបស់ស្ត្រីក្នុងវ័យបន្តពូជ ក្នុងជំពូកទី ២ ការពិពណ៌នាពីចរិតលក្ខណៈរបស់ស្ត្រី និងលទ្ធភាពមានកូនក្នុងជំពូកទី ៣ ការវិភាគសូចនាករស្តីពីផែនការគ្រួសារក្នុងជំពូកទី ៤ ការវិភាគនៃការប្រើប្រាស់សេវាថែទាំសុខភាពមាតាក្នុងជំពូកទី ៥ និងការសន្និដ្ឋាន។

# ជំពូក២

## ចរិតលក្ខណៈសេដ្ឋកិច្ច សង្គមកិច្ចស្រ្តីវ័យបន្តពូជ

ជំពូកនេះសិក្សាអំពីចរិកលក្ខណៈប្រជាសាស្រ្តសម្រាប់ស្រ្តីក្នុងវ័យបន្តពូជអាយុ(១៥-៤៩)ឆ្នាំ ពីអង្កេតប្រជាសាស្រ្តនិងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២ ដូចជាអាយុ ទីកន្លែងរស់នៅបច្ចុប្បន្ន សាសនា កម្រិតសិក្សាអប់រំ អក្ខរភាព ស្ថានភាពអាពាហ៍ពិពាហ៍ សន្ទស្សន៍ទ្រព្យសម្បត្តិគ្រួសារ។ សំណាកគំរូគ្របដណ្តប់ លើស្រ្តីក្នុងវ័យបន្តពូជអាយុ ១៥-៤៩ឆ្នាំ ចំនួន១៩,៤៩៦នាក់ ដែលក្នុងនោះស្រ្តីនៅលីវ ឬមិនទាន់រៀបការចំនួន ៤,៧៨៨នាក់ និងស្រ្តីបច្ចុប្បន្នរៀបការរួច ឬរស់នៅជាមួយដៃគូ ១៣,២៦៩នាក់ និងស្រ្តីមេម៉ាយ/លែងលះគ្នា/រស់នៅបែកគ្នា ចំនួន ១,៤៣៩នាក់។ ភាគរយស្រ្តីក្រុមអាយុ ៣០-៣៤ឆ្នាំមានក្នុងកម្រិតមួយខ្ពង់ និងក្រុមអាយុ ៤៥-៤៩ឆ្នាំ មានតែ ៥% ប៉ុណ្ណោះ។ ក្រុមស្រ្តីអាយុ២៥-២៩ឆ្នាំ មានចំនួន ៣ភាគ៤ បានរៀបការរួច ឬរស់នៅជាមួយដៃគូមានអត្រាខ្ពស់បំផុតគឺក្រុមស្រ្តីអាយុ ៤០-៤៤ឆ្នាំ គឺមាន៨៦,៣%។ ភាគរយស្រ្តីមេម៉ាយ/លែងលះគ្នាកើនឡើងតាមក្រុមអាយុ។

### រូប ២. ១: ការបែងចែកស្ថានភាពអាពាហ៍ពិពាហ៍តាមក្រុមអាយុ កម្ពុជា ឆ្នាំ ២០២១-២០២២




ស្រ្តីនៅទីប្រជុំជនចំណាយពេលវេលានៅលីវមានច្រើនជាងស្រ្តីនៅជនបទ។ ម្ភៃប្រាំពីរភាគរយនៃស្រ្តីអាយុ១៥-៤៩ ឆ្នាំនៅទីប្រជុំជន ទល់នឹង ២៣% នៃស្រ្តីនៅក្នុងក្រុមអាយុដូចគ្នានៅជនបទ។

សាសនាព្រះពុទ្ធជាសាសនាចម្បងនៅកម្ពុជា។ ច្រើនជាងហុកសិបភាគរយកាន់សាសនាព្រះពុទ្ធ ម៉ូស្លីម និង សាសនាគ្រិស្ត គឺជាស្ត្រីបច្ចុប្បន្នរៀបការរួច ឬកំពុងរស់នៅជាមួយគ្នា។ ម៉ូស្លីម សាសនាគ្រិស្ត មានភាគរយខ្ពស់ជាងស្ត្រីមេម៉ាយ/លែងលះគ្នា/ រស់នៅបែកបាក់គ្នា ៩% និង ៨% តាមលំដាប់រៀង។

### រូប ២.២ ការបែងចែកស្ថានភាពអាពាហ៍ពិពាហ៍តាម សាសនា កម្ពុជា ឆ្នាំ ២០២១-២០២២




ការសិក្សាអប់រំគឺជាកត្តាកំណត់ដ៏សំខាន់បំផុតនៃចំណេះដឹង និងចរិតលក្ខណៈបុគ្គល។ រាល់អ្នកផ្តល់ចម្លើយគឺត្រូវបានចាត់ទុកជាអក្ខរភាពប្រសិនបើគាត់អាចអានបានមួយឃ្លាឬផ្នែកណាមួយដែលបានបង្ហាញជូនគាត់។

តារាង ២.១ បង្ហាញថា ៨២%នៃស្ត្រីមិនបានចូលរៀនគឺបច្ចុប្បន្នបានរៀបការរួច ខណៈដែលមានតែ១% កំពុងរស់នៅជាមួយដៃគូ និង ៩% មេម៉ាយ/រស់នៅបែកគ្នា/លែងលះគ្នា។ ចំពោះស្ត្រីដែលបញ្ចប់កម្រិតបឋមសិក្សាមាន ៧៩% បច្ចុប្បន្នរៀបការរួច ច្រើនជាង១%កំពុងរស់នៅជាមួយដៃគូ និង៨% បច្ចុប្បន្នមេម៉ាយ /រស់នៅបែកបាក់គ្នា/លែងលះគ្នា។ ស្ត្រីមានកម្រិតសិក្សាអប់រំទាបមានសមាមាត្រខ្ពស់ជាមេម៉ាយ/រស់នៅបែកបាក់គ្នា/លែងលះគ្នា បើប្រៀបធៀបជាមួយស្ត្រីដែលបានទទួលការសិក្សាអប់រំកម្រិតមធ្យមសិក្សាឬខ្ពស់ជាង។

## រូប ២.៣ ការបែងចែកស្ថានភាពអាពាហ៍ពិពាហ៍តាមកម្រិតសិក្សាអប់រំ កម្ពុជា ឆ្នាំ ២០២១-២០២២




តារាង ២.១ ផ្តល់អំពីការបែងចែកស្ត្រីក្នុងវ័យបន្តពូជតាមស្ថានភាពអាពាហ៍ពិពាហ៍បច្ចុប្បន្ន និងតាមរាជធានីខេត្ត ។ រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តកណ្តាល និងខេត្តបាត់ដំបង មានសមមាត្រស្ត្រីខ្ពស់ដែលបានគ្រប ដណ្តប់សម្រាប់អង្កេតនេះ។

## តារាង ២.១ ការបែងចែកភាគរយស្ត្រីអាយុ ១៥-១៩ឆ្នាំ តាមចរិតលក្ខណៈអង្កេតកម្ពុជា ឆ្នាំ២០២១-២០២២

| ចរិតលក្ខណៈអង្កេត | ស្ថានភាពអាពាហ៍ពិពាហ៍បច្ចុប្បន្ន | | | | | |
|---|---|---|---|---|---|---|
| | នៅលីវ | រៀបការរួច | កំពុងរស់នៅជាមួយដៃគូ | មេម៉ាយ/លែងលះគ្នា/រស់នៅបែកបាក់គ្នា | សរុប | ចំនួន |
| **ក្រុមអាយុ** | | | | | | |
| ១៥–១៩ | ៨៨,១៧ | ១០,១៦ | ១,០៨ | ០,៥៩ | ១០០ | ២.៩៨១ |
| ២០–២៤ | ៤១,៩២ | ៥២,៣៣ | ១,១២ | ៤,៦២ | ១០០ | ២.៥៨៩ |
| ២៥–២៩ | ១៥,២១ | ៧៨,៣០ | ០,៩១ | ៥,៥៨ | ១០០ | ២.៩៨៦ |
| ៣០–៣៤ | ៦,៩៥ | ៨៥,១៧ | ១,៦៤ | ៦,២៤ | ១០០ | ៣.២៧២ |
| ៣៥–៣៩ | ៥,៩៣ | ៨៥,១៤ | ១,០៧ | ៧,៨៦ | ១០០ | ៣.៣៦៧ |
| ៤០–៤៤ | ៤,១០ | ៨៦,២៧ | ០,៨០ | ៨,៨៣ | ១០០ | ២.៥៩៨ |
| ៤៥–៤៩ | ៥,០៥ | ៨១,០១ | ១,៤១ | ១២,៥៣ | ១០០ | ១.៧០៤ |
| **តំបន់** | | | | | | |
| ទីប្រជុំជន | ២៧,៣៣ | ៦៤,១៨ | ១,៤១ | ៧,០៨ | ១០០ | ៨.២៣៩ |

| ចរិតលក្ខណៈអង្កេត | ស្ថានភាពអាពាហ៍ពិពាហ៍បច្ចុប្បន្ន | | | | | |
|---|---|---|---|---|---|---|
| | នៅលីវ | រៀបការរួច | កំពុងរស់នៅជាមួយដៃគូ | មេម៉ាយ/លែងលះគ្នា/រស់នៅបែកបាក់គ្នា | សរុប | ចំនួន |
| ជនបទ | ២២,៥៣ | ៧០,៩០ | ០,៩៥ | ៥,៦២ | ១០០ | ១១.២៥ |
| **រាជធានី ខេត្ត** | | | | | | |
| បន្ទាយមានជ័យ | ២៩,២៦ | ៦៤,៦៩ | ០,៤៧ | ៥,៥៨ | ១០០ | ៧៦៣ |
| បាត់ដំបង | ២៦,២៩ | ៦៦,៤០ | ១,៣៩ | ៥,៩១ | ១០០ | ១.៣៤៧ |
| កំពង់ចាម | ២១,២១ | ៧២,៦២ | ០,២៣ | ៥,៩៣ | ១០០ | ១.១៦៣ |
| កំពង់ឆ្នាំង | ២៥,៣២ | ៦៧,២៥ | ០,៣០ | ៧,១៣ | ១០០ | ៦៧៥ |
| កំពង់ស្ពឺ | ២៥,២៦ | ៦៧,៤២ | ១,០៣ | ៦,២៩ | ១០០ | ១.២២៦ |
| កំពង់ធំ | ២១,៥៤ | ៧៥,០៣ | ០,៥៧ | ២,៨៧ | ១០០ | ៨១៩ |
| កំពត | ២៥,២៣ | ៦៨,២៣ | ០,៤៩ | ៦,០៦ | ១០០ | ៧៨១ |
| កណ្តាល | ២៥,៧២ | ៦៦,៤៦ | ០,៤៦ | ៧,៣៦ | ១០០ | ១.៤៤៥ |
| កោះកុង | ២៤,១៦ | ៦៧,៧៨ | ១,៩៥ | ៦,១១ | ១០០ | ១៤០ |
| ក្រចេះ | ១៩,៨០ | ៦៩,៧០ | ៣,២៦ | ៧,២៤ | ១០០ | ៤៤៣ |
| មណ្ឌលគីរី | ២៣,០៣ | ៧១,៧៨ | ០,៦៥ | ៤,៥៤ | ១០០ | ១១៥ |
| ភ្នំពេញ | ២៩,៥៨ | ៦០,៨១ | ២,៣០ | ៧,៣១ | ១០០ | ៣.១៦០ |
| ព្រះវិហារ | ១៩,៨៥ | ៧០,៩១ | ៤,០៧ | ៥,១៦ | ១០០ | ៣៣២ |
| ព្រៃវែង | ២១,៦៦ | ៧១,៧០ | ០,៦៨ | ៥,៩៧ | ១០០ | ១.២៣៣ |
| ពោធិ៍សាត់ | ២២,៤៩ | ៧៤,៧១ | ០,៣៥ | ២,៤៥ | ១០០ | ៤៣២ |
| រតនគីរី | ១៨,៦៧ | ៧៧,៦៨ | ០,៩៦ | ២,៧០ | ១០០ | ២៩៣ |
| សៀមរាប | ២០,៥៧ | ៧១,៩៧ | ០,១៨ | ៧,២៨ | ១០០ | ១.៥៤៨ |
| ព្រះសីហនុ | ២៣,២៧ | ៦៦,៦៧ | ៣,៥៨ | ៦,៤៨ | ១០០ | ២៤៣ |
| ស្ទឹងត្រែង | ១៩,៣៩ | ៧៣,៨៩ | ១,៣៦ | ៥,៣៦ | ១០០ | ១៩៥ |
| ស្វាយរៀង | ២០,៦០ | ៧២,៧៤ | ០,៣៦ | ៦,៣០ | ១០០ | ៧៣៥ |
| តាកែវ | ២៨,៤៤ | ៦៤,០៧ | ១,៤២ | ៦,០៧ | ១០០ | ១.១៦២ |
| ឧត្តរមានជ័យ | ២១,៩៧ | ៧២,០៣ | ១,២៤ | ៤,៧៦ | ១០០ | ២៤២ |
| កែប | ២៣,៧៨ | ៦៩,០២ | ០,៦៧ | ៦,៥៣ | ១០០ | ៥៧ |
| ប៉ៃលិន | ២០,៨០ | ៧១,១៩ | ២,៨៤ | ៥,១៧ | ១០០ | ៩៦ |
| ត្បូងឃ្មុំ | ២២,២៤ | ៦៩,៣១ | ១,៤០ | ៧,០៥ | ១០០ | ៨៥១ |
| **សាសនា** | | | | | | |
| ព្រះពុទ្ធ | ២៤,៥៣ | ៦៨,១៤ | ១,១៥ | ៦,១៨ | ១០០ | ១៨.៩៨០ |
| មូស្លីម | ២២,៨៦ | ៦៧,៨៦ | ០,០៧ | ៩,២១ | ១០០ | ៣៤២ |

| ចរិតលក្ខណៈអង្កេត | ស្ថានភាពអាពាហ៍ពិពាហ៍បច្ចុប្បន្ន | | | | | |
|---|---|---|---|---|---|---|
| | នៅលីវ | រៀបការរួច | កំពុងរស់នៅជាមួយដៃគូ | មេម៉ាយ/លែងលះគ្នា/រស់នៅបែកបាក់គ្នា | សរុប | ចំនួន |
| សាសនាគ្រិស្ត | ២៩,១៩ | ៦១,០៤ | ១,៥៨ | ៨,១៩ | ១០០ | ១៣៥ |
| មិនមានសាសនា | ៣៤,៧៥ | ៥៥,៨០ | ៧,៩២ | ១,៥៣ | ១០០ | ៣៨ |
| សាសនាផ្សេងទៀត | ៧៩,១៩ | ២០,៨១ | ០,០០ | ០,០០ | ១០០ | ២ |
| **កម្រិតសិក្សាអប់រំ** | | | | | | |
| មិនបានចូលរៀន | ៧,៤៧ | ៨២,២២ | ១,៣៧ | ៨,៩៥ | ១០០ | ២.២៦៥ |
| បឋមសិក្សា | ១១,៨៨ | ៧៩,២៧ | ១,២១ | ៧,៦៤ | ១០០ | ៧.៥៥៤ |
| មធ្យមសិក្សា | ៣៧,១៧ | ៥៧,២០ | ១,០៥ | ៤,៥៨ | ១០០ | ៨.២៧៨ |
| ខ្ពស់ជាងមធ្យមសិក្សា | ៤៦,០៦ | ៤៨,៩១ | ១,០១ | ៤,០២ | ១០០ | ១.៣៩៩ |
| **សន្ទស្សន៍បញ្ញាភាគទហទ្រព្យសម្បត្តិ** | | | | | | |
| ទាបបំផុត | ១៨,៧៧ | ៧៣,២២ | ១,៤០ | ៦,៦១ | ១០០ | ៣.៣៩៣ |
| ទាប | ២៤,៥២ | ៦៨,១៩ | ០,៩៧ | ៦,៣២ | ១០០ | ៣.៥២៩ |
| កណ្ដាល | ២៤,៤៥ | ៦៨,៥៤ | ០,៧៥ | ៦,២៦ | ១០០ | ៣.៨៣១ |
| ខ្ពស់ | ២៤,៦៦ | ៦៧,០២ | ១,៤៦ | ៦,៨៦ | ១០០ | ៤.២៦៦ |
| ខ្ពស់បំផុត | ២៨,៩៦ | ៦៤,៦៤ | ១,១២ | ៥,២៨ | ១០០ | ៤.៤៧៧ |
| **សរុប** | **២៤,៥៦** | **៦៨,០៦** | **១,១៤** | **៦,២៤** | **១០០** | **១៩.៤៩៦** |

បញ្ញាភាគទ្រព្យសម្បត្តិត្រូវបានត្រូវបានគណនាដោយផ្អែកលើចំនួន និងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន រាប់បញ្ចូលទូរទស្សន៍ កង់ ឬរថយន្ត និងលក្ខណៈនៃលំនៅដ្ឋាន ដូចជាប្រភពទឹកសម្រាប់ផឹក បង្គន់អនាម័យ និងសម្ភារៈជញ្ជាំង ដំបូល កម្រាល។ ពិន្ទុទាំងនេះបានមកពីការវិភាគសមាសធាតុសំខាន់ៗ។ បញ្ញាភាគទ្រព្យសម្បត្តិ គ្រួសារកម្រិតជាតិ ត្រូវបានចងក្រងដោយកំណត់ពិន្ទុគ្រួសារទៅចំណាត់ថ្នាក់ជម្មតានីមួយៗនៃចំនួនសមាជិកក្នុងគ្រួសារ ឬពិន្ទុរបស់គាត់ ហើយបន្ទាប់មកបែងចែកជាប្រាំប្រភេទស្មើគ្នាដែលប្រភេទនីមួយៗមាន២០% នៃចំនួនប្រជាជន។ ស្ត្រីក្នុងវ័យបន្តពូជមានទំនោររស់នៅក្នុងគ្រួសារដែលមានជីវភាពធូរធារជាងគ្រួសារកម្ពុជា ជាមធ្យមបន្តិច ដូចដែលបានបង្ហាញឱ្យឃើញដោយសមាមាត្រស្ត្រីខ្ពស់នៅក្នុងគ្រួសារដែលមានទ្រព្យសម្បត្តិខ្ពស់ជាងជៀប នឹងគ្រួសារក្រីក្រតាមរយៈការអង្កេត ។

### រូប ២.៤ ការបែងចែកស្ថានភាពអាពាហ៍ពិពាហ៍តាមបញ្ចភាគទ្រព្យសម្បត្តិ កម្ពុជា ឆ្នាំ ២០២១-២០២២



# ជំពូក៣

# ចរិតលក្ខណៈស្ត្រី និងលទ្ធភាពមានកូន

ជំពូកនេះផ្ដល់នូវនិន្នាការនៃអត្រាលទ្ធភាពមានកូនសរុប មេធ្យាអាយុរៀបការដំបូង លទ្ធផលនៃការមានផ្ទៃពោះ ការមានផ្ទៃពោះក្នុងវ័យជំទង់ គម្លាតកំណើត បំណងប្រាថ្នាចង់បានកូន និងចំណូលចិត្តក្នុងការមានកូនប្រុស ។ ការប៉ាន់ស្មានពីអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ២០២១-២០២២ បានបង្ហាញនៅក្នុងជំពូកនេះ ដែលបង្ហាញទិន្នន័យសម្រាប់សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDG) នៅកម្រិតជាតិ និងកម្រិតក្រោមជាតិ។ ជំពូកនេះក៏ពិនិត្យមើលកម្រិតលទ្ធភាពមានកូនបច្ចុប្បន្ន ភាពខុសគ្នានៃលទ្ធភាពមានកូន ការមានកូនបន្តបន្ទាប់គ្នា គម្លាតកំណើត មេធ្យាអាយុមានកូនដំបូង និងការមានផ្ទៃពោះក្នុងវ័យជំទង់ បង្ហាញនៅក្នុងជំពូកនេះគឺផ្អែកលើព័ត៌មានដែលទទួលបានពីកម្រងសំណួរអង្កេតស្ត្រី អាយុ១៥-៤៩ឆ្នាំ។

## ៣.១. មេធ្យាអាយុរួមភេទដំបូង រៀបការដំបូង និងមានកូនដំបូង

នៅកម្ពុជាមេធ្យាអាយុរួមភេទដំបូងក្នុងចំណោមស្ត្រីអាយុ១៥-៤៩ឆ្នាំ គឺមានអាយុ២១,៤ឆ្នាំ។ មានភាពខុសគ្នាគួរឱ្យកត់សម្គាល់នៃមេធ្យាអាយុរួមភេទដំបូងក្នុងចំណោមស្ត្រីអាយុ២៥-៤៩ឆ្នាំតាមទីកន្លែងរស់នៅ។ ស្ត្រីក្រុមអាយុ ១៥-៤៩ឆ្នាំនៅជនបទ មានមេធ្យាអាយុរួមភេទដំបូងឆាប់ជាង ១,៣ឆ្នាំ ធៀបស្ត្រីក្នុងក្រុមអាយុដូចគ្នារស់នៅទីប្រជុំជន។ មេធ្យាអាយុរួមភេទដំបូងមានភាពខុសគ្នាគួរឱ្យកត់សម្គាល់តាមកម្រិតអប់រំរបស់ស្ត្រីពោលគឺស្ត្រីមិនបានចូលរៀនមានមេធ្យាអាយុរួមភេទដំបូងឆាប់ជាងស្ត្រីបានទទួលកម្រិតសិក្សាអប់រំខ្ពស់ជាងមធ្យមសិក្សា (២០,២ឆ្នាំ ទល់នឹង ២៤,៣ឆ្នាំ)។

មេធ្យាអាយុមធ្យមរៀបការដំបូងក្នុងចំណោមស្ត្រីអាយុ ១៥-៤៩ ឆ្នាំនៅកម្ពុជាគឺ ២១,៥ ឆ្នាំ។ មាននិន្នាការស្រដៀងគ្នាតាមទីកន្លែងរស់នៅ និងរាជធានី ខេត្ត មេធ្យាអាយុរួមភេទដំបូងមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ក្នុងចំណោមស្ត្រីរៀបការអាយុ (២២,៣ឆ្នាំ) រស់នៅទីប្រជុំជនយឺតជាងស្ត្រីជនបទ (២០,៩ឆ្នាំ) និងមេធ្យាអាយុរៀបការដំបូងទាបជាងគេមាននៅខេត្តរតនគីរី (១៨,៨ឆ្នាំ) និងរាជធានីភ្នំពេញមានមេធ្យាអាយុរៀបការដំបូងខ្ពស់បំផុត(២៣ឆ្នាំ)។

អាយុដែលចាប់ផ្ដើមបង្កើតកូនដំបូង គឺជាកត្តាកំណត់ដ៏សំខាន់នៃកម្រិតនៃលទ្ធភាពមានកូនទូទៅ ក៏ដូចជាសុខភាព និងសុខុមាលភាពរបស់ម្ដាយ និងកូន។ នៅកម្ពុជាមេធ្យាអាយុមានកូនដំបូងក្នុងចំណោមស្ត្រីអាយុ ២៥-៤៩ ឆ្នាំ គឺមានអាយុ ២៣,៣ ឆ្នាំ។ នេះមានន័យថាពាក់កណ្ដាលនៃស្ត្រីអាយុ២៥-៤៩ ឆ្នាំមានកូនដំបូងមុនក្រុមអាយុអាយុនេះ។ ស្ត្រីនៅទីប្រជុំជនអាយុ២៥-៤៩ឆ្នាំ អាយុមេធ្យាមានកូនដំបូងយឺតជាង១,៤ឆ្នាំ ធៀបនឹងជនបទ (២៤,១ឆ្នាំ ធៀបនឹង ២២,៧ឆ្នាំ)។ រាជធានីភ្នំពេញមានមេធ្យាខ្ពស់ជាងគេ (២៤,៧ឆ្នាំ)។

### រូប ៣.១ មេធ្យានអាយុរួមភេទដំបូង រៀបការដំបូង និងមានកូនដំបូង តាមអាយុ ២៥-៤៩ឆ្នាំ តាមទីកន្លែងរស់នៅ កម្ពុជា ឆ្នាំ២០២១-២០២២




មេធ្យានអាយុរួមភេទដំបូងគឺមានភាពខុសគ្នាតាមរាជធានី ខេត្ត នៅកម្ពុជា។ ការរួមភេទលើកដំបូងឆាប់ក្នុងចំណោមស្ត្រីអាយុ១៥-៤៩ឆ្នាំ មាននៅខេត្តរតនគីរី ខេត្តមណ្ឌលគីរី និងខេត្តស្ទឹងត្រែង និងមេធ្យានអាយុរួមភេទលើកដំបូងមានយឺតមាននៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់។ មេធ្យានអាយុ រួមភេទលើកដំបូងមានឆាប់បំផុតក្នុងចំណោមស្ត្រីគឺនៅខេត្តរតនគីរី (១៨,២ឆ្នាំ) និងយឺតបំផុតនៅរាជធានីភ្នំពេញ (២២,៦ឆ្នាំ) ។ មេធ្យានអាយុពេលរៀបការលើកដំបូង និងមេធ្យានអាយុមានកូនដំបូងក្នុងចំណោមស្ត្រីអាយុ ១៥-៤៩ឆ្នាំ ត្រូវបានរកឃើញមានខ្ពស់បំផុតនៅរាជធានីភ្នំពេញ (២៣,០ឆ្នាំ និង ២៤,៧ឆ្នាំ) ខេត្តកណ្តាល (២២,១ឆ្នាំ និង ២៣,៥ឆ្នាំ) និងពោធិ៍សាត់ (២២,១ឆ្នាំ និង ២៤,០ឆ្នាំ)។ មេធ្យានអាយុទាបបំផុតរៀបការលើកដំបូង និងមេធ្យានអាយុទាបបំផុតមានកូនដំបូងបានរកឃើញមាននៅខេត្តរតនគីរី (១៨,៨ឆ្នាំ និង ២០,៦ឆ្នាំ) ខេត្តមណ្ឌលគីរី (១៩,៦ឆ្នាំ និង ២១,២ឆ្នាំ) និងខេត្តស្ទឹងត្រែង (១៩,៦ឆ្នាំ និង ២១,៧ឆ្នាំ)។

## ផែនទី ៣.១ មេដ្យានអាយុ រួមភេទដំបូងក្នុងចំណោមស្ត្រីអាយុ ១៥-៤៩ឆ្នាំ តាមរាជធានីខេត្ត កម្ពុជា ឆ្នាំ ២០២១- ២០២២




## ផែនទី ៣.២ មេដ្យានអាយុរៀបការដំបូងក្នុងចំណោមស្ត្រីអាយុ ២៥-៤៩ឆ្នាំតាមរាជធានី ខេត្ត កម្ពុជា ឆ្នាំ២០២១- ២០២២



## ផែនទី ៣.៣ មេដ្យានអាយុមានកូនដំបូងក្នុងចំណោមស្ត្រីអាយុ ២៥-៤៩ឆ្នាំតាមរាជធានី ខេត្ត កម្ពុជា ឆ្នាំ២០២១- ២០២២




ក្នុងចំណោមស្ត្រីដែលមិនបានចូលរៀន មេដ្យានអាយុរួមភេទដំបូងឆាប់ជាងស្ត្រីមានកម្រិតសិក្សាអប់រំខ្ពស់ជាងមធ្យមសិក្សា (២០,២ ឆ្នាំទល់នឹង ២៣,៨ ឆ្នាំ)។ ទម្រង់នេះកើតមានឡើងផងដែរសម្រាប់មេដ្យានអាយុរៀបការដំបូង និងមេដ្យានអាយុមានកូនដំបូង។ ស្ត្រីអាយុ១៥-៤៩ ឆ្នាំមានកម្រិតសិក្សាអប់រំខ្ពស់ជាងមធ្យមសិក្សាមានកូនដំបូងយឺតជាងស្ត្រីដែលមិនបានចូលរៀន។

ស្ត្រីដែលមានបញ្ចភាគទ្រព្យសម្បត្តិទាបបំផុតមានមេដ្យានអាយុរួមភេទដំបូង រៀបការដំបូង និងមានកូនដំបូង (២០,៥ឆ្នាំ ២០,៧ឆ្នាំ និង២២,៥ឆ្នាំ តាមលំដាប់រៀង) ឆាប់ជាងស្ត្រីដែលមានបញ្ចភាគទ្រព្យសម្បត្តិខ្ពស់បំផុត (២២,៥ឆ្នាំ ២២,៥ឆ្នាំ និង ២៤,៣ ឆ្នាំ តាមលំដាប់រៀង)។

## តារាង ៣.១.១ មេដ្យានអាយុរួមភេទដំបូង រៀបការដំបូង និងមានកូនដំបូងក្នុងចំណោមស្ត្រីអាយុ ២៥-៤៩ ឆ្នាំ តាមចរិតលក្ខណៈអង្កេត កម្ពុជា ឆ្នាំ២០២១-២០២២

| ចរិតលក្ខណៈអង្កេត | មេដ្យានអាយុរួមភេទដំបូង | មេដ្យានអាយុរៀបការ ដំបូង | មេដ្យានអាយុមានកូន ដំបូង |
|---|---|---|---|
| **តំបន់** | | | |
| ទីប្រជុំជន | ២២,២ | ២២,៣ | ២៤,១ |
| ជនបទ | ២០,៩ | ២០,៩ | ២២,៧ |
| **រាជធានី ខេត្ត** | | | |
| បន្ទាយមានជ័យ | ២១,៥ | ២១,១ | ២២,៩ |
| បាត់ដំបង | ២២,០ | ២១,២ | ២៣,០ |
| កំពង់ចាម | ២១,៥ | ២១,៤ | ២៣,៣ |
| កំពង់ឆ្នាំង | ២១,៧ | ២១,៦ | ២៣,៤ |
| កំពង់ស្ពឺ | ២១,៣ | ២១,៤ | ២៣,១ |
| កំពង់ធំ | ២០,៦ | ២០,៩ | ២២,៧ |
| កំពត | ២០,២ | ២០,៥ | ២២,០ |
| កណ្ដាល | ២១,៥ | ២២,១ | ២៣,៥ |
| កោះកុង | ២០,៧ | ២០,៤ | ២២,៣ |
| ក្រចេះ | ២១,២ | ២០,៦ | ២២,៧ |
| មណ្ឌលគីរី | ១៩,៧ | ១៩,៦ | ២១,២ |
| ភ្នំពេញ | ២២,៦ | ២៣,០ | ២៤,៧ |
| ព្រះវិហារ | ២០,២ | ២០,១ | ២១,៨ |
| ព្រៃវែង | ២១,៦ | ២១,៣ | ២៣,២ |
| ពោធិសាត់ | ២២,៤ | ២២,១ | ២៤,០ |
| រតនគីរី | ១៨,២ | ១៨,៨ | ២០,៦ |
| សៀមរាប | ២១,២ | ២១,៣ | ២៣,៤ |
| ព្រះសីហនុ | ២១,៨ | ២១,៦ | ២៣,១ |
| ស្ទឹងត្រែង | ១៩,៩ | ១៩,៦ | ២១,៧ |
| ស្វាយរៀង | ២១,៧ | ២១,២ | ២៣,០ |
| តាកែវ | ២១,៤ | ២១,៧ | ២៣,៥ |

| ចរិតលក្ខណៈអង្កេត | មេដ្យានអាយុរួមភេទដំបូង | មេដ្យានអាយុរៀបការដំបូង | មេដ្យានអាយុមានកូនដំបូង |
|---|---|---|---|
| ឧត្តរមានជ័យ | ២០,១ | ២០,៣ | ២២,០ |
| កែប | ២១,១ | ២១,០ | ២២,៤ |
| ប៉ៃលិន | ២០,៩ | ២០,៥ | ២២,៥ |
| ត្បូងឃ្មុំ | ២០,៦ | ២០,៨ | ២២,៥ |
| **កម្រិតសិក្សាអប់រំ** | | | |
| មិនបានចូលរៀន | ២០,២ | ២០,២ | ២២,០ |
| បឋមសិក្សា | ២០,៨ | ២១,០ | ២២,៨ |
| មធ្យមសិក្សា | ២១,៨ | ២១,៨ | ២៣,៥ |
| ខ្ពស់ជាងមធ្យមសិក្សា | ២៣,៨ | ២៤,៣ | ២៣,៧ |
| **សន្ទស្សន៍បញ្ចភាគទ្រព្យសម្បត្តិ** | | | |
| ទាបបំផុត | ២០,៥ | ២០,៧ | ២២,៥ |
| ទាប | ២១,១ | ២១,១ | ២២,៩ |
| កណ្ដាល | ២១,២ | ២១,២ | ២៣,០ |
| ខ្ពស់ | ២១,៥ | ២១,៦ | ២៣,៣ |
| ខ្ពស់បំផុត | ២២,៥ | ២២,៥ | ២៤,៣ |
| **សរុប** | ២១,៤ | ២១,៥ | ២៣,៣ |

## ៣.២. លទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់

អត្រាលទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់ (ASFR) អត្រាលទ្ធភាពមានកូនសរុប (TFR) និងអត្រាកំណើតដុល (CBR) អត្រាលទ្ធភាពមានកូនទូទៅ (GFR) តាមទីកន្លែងរស់នៅ កម្រិតសិក្សាអប់រំ និងបញ្ចភាគទ្រព្យសម្បត្តិ បានបង្ហាញក្នុងតារាង ៣.២។ មានភាពស៊ីគ្នារវាងអត្រាលទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់ នៅទីប្រជុំជន និងជនបទបង្ហាញក្នុងតារាង ៣.២.១។

មានភាពខុសគ្នាខ្ពស់បំផុតក្នុងក្រុមអាយុ២០-២៤ឆ្នាំ។ អត្រាលទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់ជាទូទៅ ក្នុងចំណោមស្ត្រីនៅទីប្រជុំជនទាបជាងស្ត្រីជនបទ។

ជាមធ្យមស្ត្រីនៅជនបទមានកូនច្រើនជាង៤៦នាក់ ធៀបនឹងស្ត្រីនៅទីប្រជុំជន (១៧៤ នាក់ទល់នឹង១២៨នាក់។ អត្រាលទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់ក្នុងក្រុមអាយុ១៥-១៩ គឺមាន ៤៨នាក់ ក្នុងចំណោមស្ត្រី១.០០០ នាក់ អត្រាខ្ពស់បំផុតគឺមាននៅក្នុងក្រុមអាយុ ២០-២៤ឆ្នាំ(១៥៤នាក់ក្នុងចំណោមស្ត្រី ១.០០០នាក់)។ អត្រាលទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់បានធ្លាក់ចុះតាមការកើនឡើងកម្រិតសិក្សាអប់រំរបស់ ម្តាយដោយ ចាប់ពី ១៨១នាក់ ក្នុងចំណោមស្ត្រីក្រុមអាយុ ២០-២៤ឆ្នាំ ដែលមិនបានចូលរៀន មកត្រឹមតែ ៥៦នាក់ក្នុងចំណោមស្ត្រីមានកម្រិតសិក្សាអប់រំខ្ពស់ជាងមធ្យមសិក្សា។ មានភាពស្រដៀងគ្នានេះដែរកើតមានផងដែរក្នុងចំណោមស្ត្រីដែលមានបញ្ចភាគទ្រព្យសម្បត្តិទាបបំផុត និងខ្ពស់បំផុត ។

**រូប ៣.២.១ អត្រាលទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់រយៈពេល៣ឆ្នាំមុនអង្កេត តាមទីកន្លែងរស់នៅ កម្ពុជា ឆ្នាំ២០២១-២០២២**




រូបភាព ៣.២.១ បង្ហាញពីការធ្លាក់ចុះនៃអត្រាលទ្ធភាពមានកូនជាបន្តបន្ទាប់ ។ ការធ្លាក់ចុះនៃអត្រាលទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់(ASFR) ពីឆ្នាំ២០០០ ដល់ ឆ្នាំ២០២១-២០២២ ក្នុងចំណោមក្រុមអាយុ វ័យក្មេង(១៥-២៤ឆ្នាំ) និងក្រុមអាយុចាស់(៣៥-៤៩ឆ្នាំ) ខណៈពេលដែលការថយចុះយ៉ាងខ្លាំង សង្កេតឃើញមានក្នុងចំណោមក្រុមអាយុវ័យកណ្តាល(២៥-៣៤ឆ្នាំ)។ អត្រាលទ្ធភាពមានកូនគឺមានខ្ពស់បំផុតក្នុងចំណោមស្ត្រីក្រុមអាយុ២០-២៩ឆ្នាំ បន្ទាប់ពីអាយុ ២៩ឆ្នាំ លទ្ធភាពបង្កើតកូនបានចាប់ផ្តើមមាននិន្នាការធ្លាក់ចុះ ។

## តារាង ៣.២.១ អត្រាលទ្ធភាពមានកូនសរុប តាមអាយុជាក់លាក់ អត្រាលទ្ធភាពមានកូនទូទៅ អត្រាកំណើតដុល សម្រាប់រយៈពេល ៣ឆ្នាំមុនអង្កេត តាមចរិតលក្ខណៈអង្កេត កម្ពុជា ឆ្នាំ២០២១ -២០២២

| ចរិតលក្ខណៈអង្កេត | អត្រាលទ្ធភាពមានកូនតាមក្រុមអាយុជាក់លាក់ | | | | | | | សូចនាករលទ្ធភាពមានកូនផ្សេងទៀត | | |
|---|---|---|---|---|---|---|---|---|---|---|
| | ១៥–១៩ | ២០–២៤ | ២៥–២៩ | ៣០–៣៤ | ៣៥–៣៩ | ៤០–៤៤ | ៤៥–៤៩ | កូនសរុប | កូនដុល | កូនទូទៅ |
| ២០០០ | ៥១ | ១៩១ | ២០៣ | ១៦៥ | ១១៨ | ៥៥ | ៥ | ៤,០ | ២៧,៧ | ១២៩,០ |
| ២០០៥ | ៤៧ | ១៧៥ | ១៨០ | ១៤២ | ៩១ | ៤១ | ៥ | ២,៨ | ២៥,៦ | ១១១,០ |
| ២០១០ | ៤៦ | ១៧៣ | ១៦៧ | ១២១ | ៧១ | ២៨ | ៤ | ៣,០ | ២៤,២ | ១០៤,០ |
| ២០១៤ | ៥៧ | ១៦២ | ១៥២ | ១០២ | ៥១ | ១៧ | ៤ | ២,៧ | ២២,០ | ៩៨,០ |
| ២០២១-២០២២ | ៤៨ | ១៥៤ | ១៤៩ | ១១០ | ៦១ | ២៤ | ៣ | ២,៧ | ២០,២ | ៩៣,៧ |
| **តំបន់** | | | | | | | | | | |
| ទីប្រជុំជន | ៣៩ | ១២៨ | ១២៧ | ១០៧ | ៥៧ | ២៣ | ៣ | ២,៤ | ២០,៥ | ៨៥,០ |
| ជនបទ | ៥៥ | ១៧៤ | ១៦៦ | ១១២ | ៦៤ | ២៤ | ៣ | ៣,០ | ២០,១ | ១០០,៣ |
| **កម្រិតសិក្សាអប់រំ** | | | | | | | | | | |
| មិនបានចូលរៀន | ១១៧ | ១៨១ | ១៦០ | ១១២ | ៦៥ | ៣៤ | ៨ | ៣,៤ | ៨,០ | ៨៦,៩ |
| បឋមសិក្សា | ៩៧ | ១៧៧ | ១៥៩ | ១០៩ | ៦៥ | ២០ | ១ | ៣,១ | ១៨,៤ | ១២២,៤ |
| មធ្យមសិក្សា | ៣៨ | ១៦៧ | ១៤៣ | ១០៩ | ៤៧ | ២០ | ២ | ២,៦ | ៣២,៨ | ៩៤,៦ |
| ខ្ពស់ជាងមធ្យមសិក្សា | ១ | ៥៦ | ១៣៧ | ១១១ | ៧៩ | ៩៩ | ០ | ២,៤ | ៣៨,៦ | ៥៧៦,៣ |
| **សន្ទស្សន៍បញ្ញាគទ្រព្យសម្បត្តិ** | | | | | | | | | | |
| ទាបបំផុត | ៨៤ | ១៩៨ | ១៦៣ | ១១៧ | ៨២ | ៣៨ | ៨ | ៣,៥ | ២២,០ | ១១៥,១ |
| ទាប | ៥៦ | ១៥៨ | ១៨៦ | ១២១ | ៦៦ | ២០ | ២ | ៣,០ | ១៩,៦ | ២១៣,៥ |
| កណ្តាល | ៤៧ | ១៥៦ | ១៤៥ | ៩៧ | ៦១ | ២៥ | ៤ | ២,៧ | ១៨,៨ | ៨៩,៨ |
| ខ្ពស់ | ៣៣ | ១៤៩ | ១៤៦ | ១១៦ | ៦២ | ១៥ | ១ | ២,៦ | ២១,២ | ១៦៩,៤ |
| ខ្ពស់បំផុត | ២៧ | ១២៤ | ១២០ | ១០១ | ៤០ | ២៣ | ៥ | ២,២ | ១៩,៦ | ៧៨,០ |

*កំណត់សម្គាល់: សញ្ញាផ្កាយបង្ហាញថាតួលេខមួយគឺផ្អែកលើករណីដែលមិនប្រើមេគុណតិចជាង ២៥ និងត្រូវបានលុបចោល ។*

អត្រាកំណើតដុលបច្ចុប្បន្នមាន ២០,២នាក់ ក្នុងចំណោមប្រជាជន ១.០០០នាក់ និងអត្រាលទ្ធភាពមានកូនទូទៅគឺ ៩៣,៧នាក់ ក្នុង១.០០០ ស្ត្រីអាយុ១៥-៤៥ឆ្នាំ សម្រាប់រយៈពេលប្រាំឆ្នាំមុនអង្កេត។ អត្រាលទ្ធភាពមានកូនទូទៅ(GFR) មានការប្រែប្រួលផងដែរទៅតាមតំបន់ទីប្រជុំជន និងជនបទ ជាមធ្យមអត្រាលទ្ធភាពមានកូនទូទៅ(GFR) នៅជនបទ គឺមាន ១០០,៣នាក់ក្នុងចំណោមស្ត្រី ១.០០០នាក់ អត្រានេះមានខ្ពស់នៅទីប្រជុំជន (៨៥នាក់ ក្នុង១.០០០ស្ត្រី)។ មិនមានភាពខុសគ្នាគួរឱ្យកត់សម្គាល់រវាង អត្រាកំណើតដុល (CBR)នៅជនបទ (២០,១នាក់ក្នុងចំណោម ១.០០០ស្ត្រី) និងនៅទីប្រជុំជន (២០,៥ ក្នុង១.០០០ស្ត្រី)។ អត្រាកំណើតដុល

(CBR) និងអត្រាលទ្ធភាពមានកូនទូទៅ (GFR) បានធ្លាក់ចុះយ៉ាងខ្លាំងពី (២៧,៧ និង ១២៩,០) ក្នុងចំណោម១.០០០ស្ត្រី មកត្រឹម (២០,២ និង ៩៣,៧) ក្នុងចំណោមស្ត្រី ១.០០០នាក់ ក្នុងឆ្នាំ២០២១-២០២២ ។

**រូប ៣.២.២ ការបែងចែកអត្រាកំណើតដុល និងអត្រាលទ្ធភាពមានកូនទូទៅ កម្ពុជា ឆ្នាំ២០០០ ទៅ ឆ្នាំ២០២១-២០២២**




## ៣.៣. អត្រាលទ្ធភាពមានកូនសរុប (TFR)

អត្រាលទ្ធភាពមានកូនសរុប (TFR) ជាចំនួនកូនកើតរស់មធ្យមសម្រាប់ស្ត្រីម្នាក់មានពេលនាងបញ្ចប់វ័យបន្តពូជ ប្រសិនបើនាងត្រូវឆ្លងកាត់បង្កើតកូនដោយអនុលោមតាមអត្រានៃការមានកូនតាមក្រុមអាយុជាក់លាក់នៃឆ្នាំដែលបានផ្តល់ឱ្យ។

ការធ្លាក់ចុះនៃលទ្ធភាពមានកូនបាននឹងបន្តកើតឡើងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ លើសពីនេះទៅទៀតវាគឺជាបាតុភូតដែលកំពុងបើកឱកាសការងារ និងការអប់រំថ្មីទាំងស្រុងសម្រាប់ស្ត្រីវ័យក្មេង។ អត្រាលទ្ធភាពមានកូនបច្ចុប្បន្ននៅកម្ពុជា ឆ្នាំ២០២១-២០២២ មានចំនួន២,៧ កំណើតក្នុងស្ត្រីម្នាក់។ ចន្លោះឆ្នាំ២០០៥ និង ២០២១-២០២២ អត្រាលទ្ធភាពមានកូនសរុប (TFR) បានធ្លាក់ចុះស្ទើរតែមួយកុមារ (០,៧)។ អត្រាលទ្ធភាពមានកូនសរុប(TFR) ក្នុងចំណោមស្ត្រីនៅតំបន់ជនបទបានធ្លាក់ចុះពី ៣,៥នាក់ក្នុងឆ្នាំ២០០៥ មក៣,០ ក្នុងឆ្នាំ២០២១-២០២២ ខណៈពេលដែលនៅទីប្រជុំជន មានការថយចុះស្រដៀងគ្នាពី ២,៨នាក់ ក្នុងឆ្នាំ២០០៥ មក ២,៤នាក់ នៅឆ្នាំ២០២១-២០២២ ។

## រូប ៣.៣.១ និន្នាការនៃអត្រាលទ្ធភាពមានកូនសរុបសម្រាប់រយៈពេល ៣ឆ្នាំមុនអង្កេត តាមទីកន្លែងរស់នៅ កម្ពុជា ឆ្នាំ២០២១-២០២២




អត្រាលទ្ធភាពមានកូនសរុប (TFR) មានភាពខុសគ្នាខ្លាំងតាមកម្រិតសិក្សាអប់រំនៅកម្ពុជា អត្រាលទ្ធភាពមានកូនសរុប(TFR) ដោយមានគម្លាតពី ៣,៤ ក្នុងចំណោមស្ត្រីមិនបានចូលរៀន មកត្រឹម ២,៤នាក់ ក្នុងចំណោមស្ត្រីដែលបានបញ្ចប់ការសិក្សាអប់រំកម្រិតមធ្យមសិក្សា និងខ្ពស់ជាង។

## រូប ៣.៣.២ អត្រាលទ្ធភាពមានកូនសរុបសម្រាប់រយៈពេល ៣ឆ្នាំមុនអង្កេត តាមកម្រិតសិក្សាអប់រំ កម្ពុជា ឆ្នាំ២០២១-២០២២




អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២ អត្រាលទ្ធភាពមានកូនសរុប (TFR) បានធ្លាក់ចុះតាមការកើនឡើងនៃបញ្ចភាគទ្រព្យសម្បត្តិ។ អត្រាលទ្ធភាពមានកូនសរុប(TFR)មាន៣,៥នាក់ ក្នុងចំណោមស្ត្រីដែលមានបញ្ចភាគទ្រព្យសម្បត្តិទាបបំផុត និងមានតែ ២,២នាក់ ក្នុងចំណោមស្ត្រីដែលមាន បញ្ចភាគទ្រព្យសម្បត្តិខ្ពស់បំផុត។ ស្ត្រីដែលមានបញ្ចភាគទ្រព្យសម្បត្តិទាបបំផុតមានអត្រាលទ្ធភាពមានកូនសរុបធ្លាក់ចុះខ្លាំងបំផុតតាំងពីឆ្នាំ២០១៤ និងមានតែមួយមុខងារដែលមានការធ្លាក់ចុះថេរតាំងពី ឆ្នាំ២០០៥។

## រូប ៣.៣.៣ អត្រាលទ្ធភាពមានកូនសរុបសម្រាប់រយៈពេល ៣ឆ្នាំមុនអង្កេត តាមបញ្ចភាគទ្រព្យសម្បត្តិ កម្ពុជាឆ្នាំ ២០០៥ ដល់ឆ្នាំ២០២១-២០២២




អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២២ អត្រាលទ្ធភាពមានកូនសរុប (TFR) បានប៉ាន់ស្មានថាមាន ២,៧នាក់ ក្នុងចំណោមស្ត្រីម្នាក់ តែក៏មានដូចសូចនាករផ្សេងទៀតដែរ ដែលមានភាពខុសគ្នាខ្លាំងផងដែរតាមរាជធានី ខេត្ត។ ប្រាំបីរាជធានី ខេត្ត (តារាង ៣.៤.១) អត្រាលទ្ធភាពមានកូនសរុបមានខ្ពស់ មានចាប់ពី ៣,០ ឬខ្ពស់ជាងនេះ។ ខេត្តស្ទឹងត្រែងអត្រាលទ្ធភាពមានកូនសរុប (TFR) ៣,៤ មានខ្ពស់ជាងគេបំផុត ដែលមាន ២៦ភាគរយ ខ្ពស់ជាងមធ្យមនៅកម្រិតជាតិ។ ប្រាំពីររាជធានីខេត្តលទ្ធភាពមានកូនសរុប (TFR) មានអត្រាទាបជាងកម្រិតថ្នាក់ជាតិ រាជធានីភ្នំពេញ និងខេត្តកែប លទ្ធភាពមានកូនសរុប(TFR) ទាបបំផុតគឺ ២,៣។

## ផែនទី ៣.៤ អត្រាលទ្ធភាពមានកូនសរុប សម្រាប់រយៈពេលបីឆ្នាំមុនអង្កេតតាមរាជធានីខេត្ត កម្ពុជា ឆ្នាំ២០២១-២០២២




## ៣.៤. លទ្ធភាពមានកូន និងលទ្ធភាពចង់បានចំនួនកូនជាមធ្យម

អត្រាចង់បានចំនួនកូនជាមធ្យម បង្ហាញពីកម្រិតលទ្ធភាពមានកូន ដែលអាចជាលទ្ធផលប្រសិនបើគ្រប់កំណើតមិនចង់បានត្រូវបានការពារ។ នៅកម្ពុជាចំណង់ចង់បានកូនជាមធ្យមចំនួន២,៨នាក់ក្នុងចំណោមស្ត្រីម្នាក់ បើធៀបនឹងអត្រាលទ្ធភាពបង្កើតកូនសរុប(TFR) ជាក់ស្តែងមាន២,៧នាក់ និងមានជាមធ្យមមាន៣,០នាក់ក្នុងចំណោមស្ត្រីបញ្ចប់វ័យបន្តពូជ។ អត្រាគម្លាតរវាងលទ្ធភាពមានកូនជាក់ស្តែង និងការចង់បានកូនក្នុងចំណោមស្ត្រីអាយុ ១៥-៤៩ឆ្នាំមានអត្រា ០,១នាក់ នៅជនបទ បើធៀបនឹងទីប្រជុំជនមាន ០,២នាក់។

## រូប ៣.៤.១ លទ្ធភាពមានកូន ចំនួនកូនមធ្យមចង់បាន និងលទ្ធភាពមានកូនមធ្យមជាក់ស្តែងតាមកន្លែងរស់នៅ កម្ពុជា ឆ្នាំ២០២១-២០២២




កម្រិតសិក្សាអប់រំក៏មានសារៈសំខាន់ផងដែរសម្រាប់ចំណេះដឹង និងការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើត និងមានសម្ថភាពប្រសើរអប់រំស្ត្រីដើម្បីកាត់បន្ថយគម្លាតកំណើត និងចំនួនកូនចង់បាន និងកូនជាក់ស្តែង។

អត្រាលទ្ធភាពមានកូនសរុប(TFR) សម្រាប់ស្ត្រីមិនបានចូលរៀនមាន(៣,១)បើធៀបនឹងស្ត្រីមានកម្រិតសិក្សាអប់រំខ្ពស់ជាងមធ្យមសិក្សាមានតែ ២,៥ប៉ុណ្ណោះ។ គម្លាតរវាងអត្រាលទ្ធភាពមានកូនជាក់ស្តែង និងចំនួនកូនដែលចង់បានក្នុងចំណោមស្ត្រីដែលមិនបានចូលរៀនមានអត្រា (០,៣) ខ្ពស់ជាងស្ត្រីមានកម្រិតសិក្សាអប់រំខ្ពស់ជាងមធ្យមសិក្សា(០,១)។

នៅកម្ពុជាមានតែខេត្តកំពង់ធំមួយប៉ុណ្ណោះដែលអត្រាលទ្ធភាពចង់បានចំនួនកូនជាមធ្យមទាបជាងកម្រិតជំនួស (២,០)។ គម្លាតនៃអត្រាមានកូនពិតប្រាកដ និងចំនួនកូនចង់បានមាន០,៥ឬច្រើនជាងមាន ខេត្តកំពង់ធំ (១,២) ព្រៃវែង (០,៥) និងរតនគិរី (០,៥)។

## ផែនទី ៣.៥ អត្រាលទ្ធភាពមានកូននៃចំនួនកូនចង់បានជាមធ្យម តាមរាជធានី ខេត្ត កម្ពុជា ឆ្នាំ២០២១ - ២០២២




## ផែនទី ៣.៦ អត្រាលទ្ធភាពមានកូនជាក់ស្តែងជាមធ្យម តាមរាជធានី ខេត្ត កម្ពុជា ឆ្នាំ២០២១-២០២២



កម្រិតនៃការចង់បានកូនបានធ្លាក់ចុះជាមួយនឹងការកើនឡើងនៃបញ្ចាភាគទ្រព្យសម្បត្តិ ក៏ដូចជាគម្លាតរវាងការមានកូនជាក់ស្តែង និងការចង់បានកូនផងដែរ។ អត្រានៃការចង់បានកូន ២,៩នាក់ ក្នុងចំណោមស្ត្រីដែលមានបញ្ចាភាគទ្រព្យសម្បត្តិទាបបំផុត និង២,៦នាក់ ក្នុងចំណោមស្ត្រីដែលមានបញ្ចាភាគទ្រព្យសម្បត្តិខ្ពស់បំផុត។ គម្លាតរវាងការមានកូនជាក់ស្តែង និងការចង់បានកូនគឺមាន ០,៤នាក់ សម្រាប់ស្ត្រីមានបញ្ចាភាគទ្រព្យសម្បត្តិទាបបំផុត និងស្ត្រីមានបញ្ចាភាគទ្រព្យសម្បត្តិខ្ពស់បំផុត។

### រូប ៣.៤.២ អត្រាលទ្ធភាពមានកូន ចំនួនកូនមធ្យមចង់បាន និងចំនួនកូនមានជាក់ស្តែង តាមបញ្ចាភាគទ្រព្យសម្បត្តិ កម្ពុជា ឆ្នាំ២០២១-២០២២




### តារាង ៣.៤.១ អត្រាលទ្ធភាពមានកូន ចំនួនកូនចង់បានមធ្យម និងចំនួនកូនមានជាក់ស្តែង តាមចរិតលក្ខណៈអង្កេត កម្ពុជា ឆ្នាំ ២០២១-២០២២

| ចរិតលក្ខណៈអង្កេត | អត្រាលទ្ធភាពមានកូនសរុប | ចំនួនកូនមធ្យមចង់បាន | ចំនួនកូនមធ្យមមានជាក់ស្តែង |
|---|---|---|---|
| **តំបន់** | | | |
| ទីប្រជុំជន | ២,៤ | ២,៦ | ២,៧ |
| ជនបទ | ៣,០ | ២,៩ | ៣,១ |
| **រាជធានី ខេត្ត** | | | |
| បន្ទាយមានជ័យ | ២,៦ | ២,៨ | ២,៩ |

| ចរិតលក្ខណៈអង្កេត | អត្រាលទ្ធភាពមានកូនសរុប | ចំនួនកូនមធ្យមចង់បាន | ចំនួនកូនមធ្យមមានជាក់ស្តែង |
|---|---|---|---|
| បាត់ដំបង | ២,៩ | ៣,០ | ៣,៣ |
| កំពង់ចាម | ៣,០ | ៣,២ | ៣,១ |
| កំពង់ឆ្នាំង | ២,៨ | ២,៩ | ៣,៧ |
| កំពង់ស្ពឺ | ២,៥ | ២,៦ | ៣,២ |
| កំពង់ធំ | ៣,២ | ២,០ | ២,៩ |
| កំពត | ២,៥ | ២,៨ | ២,៩ |
| កណ្ដាល | ២,៩ | ២,៧ | ២,៨ |
| កោះកុង | ២,៩ | ២,៩ | ៣,៦ |
| ក្រចេះ | ៣,៣ | ៣,០ | ៣,០ |
| មណ្ឌលគីរី | ៣,១ | ៣,៣ | ៤,៤ |
| ភ្នំពេញ | ២,៣ | ២,៦ | ២,៤ |
| ព្រះវិហារ | ៣,០ | ៣,២ | ៣,៧ |
| ព្រៃវែង | ៣,៣ | ២,៨ | ២,៨ |
| ពោធិ៍សាត់ | ២,៩ | ២,៨ | ២,៩ |
| រតនគីរី | ២,៩ | ៣,៤ | ៤,២ |
| សៀមរាប | ២,៦ | ២,៨ | ៣,០ |
| ព្រះសីហនុ | ២,៦ | ៣,០ | ៣,១ |
| ស្ទឹងត្រែង | ៣,៤ | ៣,១ | ៣,៨ |
| ស្វាយរៀង | ៣,០ | ២,៧ | ២,៨ |
| តាកែវ | ២,៧ | ២,៦ | ២,៨ |
| ឧត្តរមានជ័យ | ២,៥ | ២,៦ | ៣,៣ |
| កែប | ២,៣ | ២,៧ | ៣,០ |
| ប៉ៃលិន | ២,៨ | ២,៨ | ៣,៣ |
| ត្បូងឃ្មុំ | ២,៩ | ២,៨ | ២,៧ |
| **កម្រិតសិក្សាអប់រំ** | | | |
| មិនបានចូលរៀន | ៣,៤ | ៣,១ | ៣,៣ |
| បឋមសិក្សា | ៣,១ | ២,៩ | ៣,០ |
| មធ្យមសិក្សា | ២,៦ | ២,៦ | ២,៧ |
| ខ្ពស់ជាងមធ្យមសិក្សា | ២,៤ | ២,៥ | (២,១) |
| **សន្ទស្សន៍បញ្ចភាគទ្រព្យសម្បត្តិ** | | | |
| ទាបបំផុត | ៣,៥ | ២,៩ | ៣,៤ |
| ទាប | ៣,០ | ២,៨ | ៣,០ |

| ចរិតលក្ខណៈអង្កេត | អត្រាលទ្ធភាពមានកូនសរុប | ចំនួនកូនមធ្យមចង់បាន | ចំនួនកូនមធ្យមមានជាក់ស្ដែង |
|---|---|---|---|
| កណ្ដាល | ២,៧ | ២,៨ | ៣,១ |
| ខ្ពស់ | ២,៦ | ២,៧ | ២,៨ |
| ខ្ពស់បំផុត | ២,២ | ២,៦ | ២,៥ |
| **សរុប** | ២,៧ | ២,៨ | ៣,០ |

## ៣.៥ លទ្ធភាពមានកូនពេញមួយជីវិត (ចំនួនកូនកើតរស់ និងកូនកំពុងនៅរស់រានមានជីវិត)

អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២ បានប្រមូលព័ត៌មានស្ដីអំពីចំនួនកូនកើតរស់ និង ចំនួនកូនដែលកំពុងបន្តនៅរស់រានក្នុងចំណោមស្ត្រីអាយុ ១៥-៤៩ឆ្នាំ។ តារាង ៣.៥.១ បង្ហាញការបែងចែកភាគរយស្ត្រីអាយុ១៥-៤៩ឆ្នាំ យោងតាមលំដាប់កំណើតកូន(ចំនួនកូនកើតរស់) ចំនួនមធ្យមកូនកើតរស់ និងចំនួនមធ្យមកូននៅរស់រានមានជិវិត។ តារាងបានបង្ហាញព័ត៌មានស្ដីពីការបញ្ចប់ការមានកូនសម្រាប់ស្ត្រីអាយុ ១៥-៤៩ឆ្នាំ មានកូនជាមធ្យម ១,៧នាក់ ពេញមួយជីវិតរបស់គាត់។ ក្នុងនោះមានកូនចំនួន ១,៦ នាក់នៅរស់រាននៅពេលអង្កេត។ ប្រហែល ៣៥,០% នៃស្ត្រីអាយុ ២៥-២៩ឆ្នាំ មានកូន ២ នាក់នៅពេលធ្វើអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២។ ស្ត្រីក្នុងក្រុមអាយុដូចគ្នានេះដែរ (២៥-២៩)ឆ្នាំ មានកូនជាមធ្យមចំនួន១,៣ នាក់ និងមានចំនួនជាមធ្យម ១,៣នាក់កំពុងនៅរស់រានក្នុងចំណោមស្ត្រីម្នាក់។

ស្ត្រីបច្ចុប្បន្នរៀបការរួចអាយុ ១៥-៤៩ឆ្នាំ មានកូនជាមធ្យម ២,៣ នាក់ និង ២,២នាក់កំពុងរស់នៅពេលធ្វើអង្កេត ។ ក្រុមស្ត្រីអាយុបញ្ចប់វ័យបន្តពូជ (៤៥-៤៩)ឆ្នាំ បច្ចុប្បន្នរៀបការរួច មានកូនជាមធ្យម ៣,៤នាក់ និងមាន ៣,១ នាក់នៅរស់រានពេលធ្វើអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០២១-២០២២ (តារាង៣.៥.១)។

## តារាង ៣.៥.១ ចំនួនកូនកើតរស់ និងកូនកំពុងនៅរស់រាន កម្ពុជាឆ្នាំ ២០២១-២០២២

ការបែងចែកភាគរយនៃគ្រប់ស្ត្រី និងស្ត្រីបច្ចុប្បន្នរៀបការរួចអាយុ១៥-៤៩ឆ្នាំ តាមចំនួនកូនដែលធ្លាប់បង្កើត ចំនួនមធ្យមកូនកើតរស់ ចំនួនកូនមធ្យមនៅរស់រាន យោងតាមតាមក្រុមអាយុ កម្ពុជា ឆ្នាំ២០២១-២០២២

| អាយុ | លំដាប់កំណើតកូន | | | | | | | ស្ត្រី | ចំនួនមធ្យមកូនកើតរស់ | ចំនួនមធ្យមកូននៅរស់រាន |
|---|---|---|---|---|---|---|---|---|---|---|
| | ០ | ១ | ២ | ៣ | ៤ | ៥+ | សរុប | | | |
| **គ្រប់ស្ត្រី** | | | | | | | | | | |
| **សរុប** | **២៩,៨** | **១៧,១** | **២៦,៣** | **១៦,០** | **៦,៣** | **៤,៥** | **១០០** | **១៩.៤៩៦** | **១,៧** | **១,៦** |
| ១៥-១៩ | ៩៣,៤ | ៥,៩ | ០,៧ | ០,០ | ០,០ | ០,០ | ១០០ | ២.៩៨១ | ០,១ | ០,១ |
| ២០-២៤ | ៥៤,១ | ៣៣,៧ | ១០,៦ | ១,៦ | ០,១ | ០,០ | ១០០ | ២.៥៨៩ | ០,៦ | ០,៦ |
| ២៥-២៩ | ២៣,៣ | ៣២,០ | ៣៥,០ | ៨,១ | ១,៤ | ០,២ | ១០០ | ២.៩៨៦ | ១,៣ | ១,៣ |
| ៣០-៣៤ | ១១,០ | ១៨,៤ | ៤៥,១ | ១៩,៩ | ៤,៤ | ១,៣ | ១០០ | ៣.២៧២ | ១,៩ | ១,៩ |
| ៣៥-៣៩ | ៧,៩ | ១០,៩ | ៣៦,០ | ៣០,៣ | ៩,៤ | ៥,៤ | ១០០ | ៣.៣៦៧ | ២,៤ | ២,៣ |
| ៤០-៤៤ | ៦,៧ | ៨,១ | ២៨,០ | ២៩,៤ | ១៦,០ | ១១,៧ | ១០០ | ២.៥៩៨ | ២,៨ | ២,៧ |
| ៤៥-៤៩ | ៧,៤ | ៨,៩ | ២១,៧ | ២៣,៤ | ១៧,៩ | ២០,៦ | ១០០ | ១.៧០៤ | ៣,១ | ២,៩ |
| **ស្ត្រីរៀបការរួច** | | | | | | | | | | |
| **សរុប** | **៦,៩** | **២១,២** | **៣៥,៤** | **២១,៨** | **៨,៥** | **៦,១** | **១០០** | **១៣.៤៩២** | **២,៣** | **២,២** |
| ១៥-១៩ | ៤៤,៤ | ៤៩,៦ | ៦,១ | ០,០ | ០,០ | ០,០ | ១០០ | ៣៣៥ | ០,៦ | ០,៦ |
| ២០-២៤ | ២០,៨ | ៥៧,៣ | ១៨,៨ | ២,៩ | ០,១ | ០,០ | ១០០ | ១.៣៨៤ | ១,០ | ១,០ |
| ២៥-២៩ | ៩,៣ | ៣៦,១ | ៤២,៧ | ៩,៩ | ១,៧ | ០,២ | ១០០ | ២.៣៦៥ | ១,៦ | ១,៦ |
| ៣០-៣៤ | ៤,៤ | ១៨,៤ | ៤៨,៨ | ២២,១ | ៤,៩ | ១,៤ | ១០០ | ២.៨៤០ | ២,១ | ២,១ |

ការបែងចែកភាគរយនៃគ្រប់ស្ត្រី និងស្ត្រីបច្ចុប្បន្នរៀបការរួចអាយុ១៥-៤៩ឆ្នាំ តាមចំនួនកូនដែលធ្លាប់បង្កើត ចំនួនមធ្យមកូនកើតរស់ ចំនួនកូនមធ្យមនៅរស់រាន យោង តាមតាមក្រុមអាយុ កម្ពុជា ឆ្នាំ២០២១-២០២២

| អាយុ | លំដាប់កំណើតកូន | | | | | | | ស្ត្រី | ចំនួនមធ្យមកូនកើតរស់ | ចំនួនមធ្យមកូននៅរស់រាន |
|---|---|---|---|---|---|---|---|---|---|---|
| | ០ | ១ | ២ | ៣ | ៤ | ៥+ | សរុប | | | |
| ៣៥-៣៩ | ១,៩ | ៩,៥ | ៣៩,២ | ៣៣,១ | ១០,២ | ៦,២ | ១០០ | ២.៩០២ | ២,៦ | ២,៥ |
| ៤០-៤៤ | ២,៦ | ៦,៥ | ២៩,០ | ៣១,៩ | ១៧,៦ | ១២,៥ | ១០០ | ២.២៦២ | ៣,០ | ២,៩ |
| ៤៥-៤៩ | ២,៩ | ៧,៥ | ២១,៨ | ២៥,៦ | ១៩,៦ | ២២,៦ | ១០០ | ១.៤០៤ | ៣,៤ | ៣,១ |
| **ទីប្រជុំជន** | | | | | | | | | | |
| **គ្រប់ស្ត្រី** | | | | | | | | | | |
| **សរុប** | **៣៣,២** | **១៨,១** | **២៦,១** | **១៤,៦** | **៤,៩** | **៣,១** | **១០០** | **៨.២៣៩** | **១,៥** | **១,៥** |
| ១៥-១៩ | ៩៤,៨ | ៤,៤ | ០,៨ | ០,០ | ០,០ | ០,០ | ១០០ | ១.១៤៤ | ០,១ | ០,១ |
| ២០-២៤ | ៦៥,៩ | ២៥,៣ | ៧,៥ | ១,៣ | ០,០ | ០,០ | ១០០ | ១.១២៨ | ០,៤ | ០,៤ |
| ២៥-២៩ | ៣១,៧ | ៣៤,៨ | ២៧,០ | ៥,៥ | ០,៨ | ០,១ | ១០០ | ១.៣៧៥ | ១,១ | ១,១ |
| ៣០-៣៤ | ១៥,២ | ២១,៧ | ៤៣,៦ | ១៦,១ | ២,៥ | ០,៩ | ១០០ | ១.៤៨០ | ១,៧ | ១,៧ |
| ៣៥-៣៩ | ៩,១ | ១២,៧ | ៣៦,៩ | ២៩,៦ | ៧,៦ | ៤,១ | ១០០ | ១.៤៧៣ | ២,៣ | ២,២ |
| ៤០-៤៤ | ៦,០ | ៩,៦ | ៣១,១ | ២៩,២ | ១៥,០ | ៩,២ | ១០០ | ១.០១៤ | ២,៧ | ២,៦ |
| ៤៥-៤៩ | ៧,៨ | ១១,៥ | ២៨,៦ | ២៣,៥ | ១៥,២ | ១៣,៤ | ១០០ | ៦២៥ | ២,៨ | ២,៦ |
| **ស្ត្រីរៀបការរួច** | | | | | | | | | | |
| **សរុប** | **៨,០៦** | **២៣,២៩** | **៣៦,៦៨** | **២១,០៣** | **៦,៨០** | **៤,១៤** | **១០០** | **៥.៤០៤** | **២,១** | **២,០** |
| ១៥-១៩ | ៥០,០២ | ៤១,៥៥ | ៨,៤៣ | - | - | - | ១០០ | ១០៩ | ០,៦ | ០,៦ |
| ២០-២៤ | ២៥,៨៧ | ៥៣,៥៦ | ១៧,៥១ | ៣,០៥ | - | - | ១០០ | ៤៧៣ | ១,០ | ១,០ |
| ២៥-២៩ | ១២,៦៧ | ៤២,០១ | ៣៦,៣៨ | ៧,៦០ | ១,១៣ | ០,២០ | ១០០ | ៩៨៦ | ១,៤ | ១,៤ |

| ការបែងចែកភាគរយនៃគ្រប់ស្ត្រី និងស្ត្រីបច្ចុប្បន្នរៀបការរួចអាយុ១៥-៤៩ឆ្នាំ តាមចំនួនកូនដែលធ្លាប់បង្កើត ចំនួនមធ្យមកូនកើតរស់ ចំនួនកូនមធ្យមនៅរស់រាន យោងតាមតាមក្រុមអាយុ កម្ពុជា ឆ្នាំ២០២១-២០២២ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| អាយុ | លំដាប់កំណើតកូន | | | | | | | ស្ត្រី | ចំនួនមធ្យមកូនកើតរស់ | ចំនួនមធ្យមកូននៅរស់រាន |
| | ០ | ១ | ២ | ៣ | ៤ | ៥+ | សរុប | | | |
| ៣០-៣៤ | ៦,៣១ | ២៣,១០ | ៤៨,៣១ | ១៨,៥១ | ២,៨៦ | ០,៩២ | ១០០ | ១.២៤៩ | ១,៩ | ១,៩ |
| ៣៥-៣៩ | ១,៦១ | ១១,០២ | ៤១,៣០ | ៣៣,៦៧ | ៧,៩៤ | ៤,៤៦ | ១០០ | ១.២១៥ | ២,៥ | ២,៥ |
| ៤០-៤៤ | ១,៨២ | ៨,៤០ | ៣១,៨០ | ៣២,៣៧ | ១៦,៣០ | ៩,៣១ | ១០០ | ៨៧៣ | ២,៨ | ២,៧ |
| ៤៥-៤៩ | ៣,៨៥ | ១០,០៦ | ២៩,៧៦ | ២៤,៩៤ | ១៦,៣៨ | ១៥,០១ | ១០០ | ៤៩៩ | ២,៩ | ២,៨ |
| **ជនបទ** | | | | | | | | | | |
| **គ្រប់ស្ត្រី** | | | | | | | | | | |
| **សរុប** | **២៧,៣** | **១៦,៤** | **២៦,៤** | **១៧,០** | **៧,៣** | **៥,៧** | **១០០** | **១១.២៥៧** | **១,៨** | **១,៧** |
| ១៥-១៩ | ៩២,៥ | ៦,៨ | ០,៦ | ០,០ | ០,០ | ០,០ | ១០០ | ១.៨៣៧ | ០,១ | ០,១ |
| ២០-២៤ | ៤៤,៩ | ៤០,១ | ១៣,១ | ១,៨ | ០,១ | ០,០ | ១០០ | ១.៤៦១ | ០,៧ | ០,៧ |
| ២៥-២៩ | ១៦,២ | ២៩,៧ | ៤១,៩ | ១០,២ | ១,៨ | ០,២ | ១០០ | ១.៦១០ | ១,៥ | ១,៥ |
| ៣០-៣៤ | ៧,៦ | ១៥,៦ | ៤៦,៣ | ២៣,០ | ៦,០ | ១,៥ | ១០០ | ១.៧៩២ | ២,១ | ២,០ |
| ៣៥-៣៩ | ៦,៩ | ៩,៤ | ៣៥,៣ | ៣០,៨ | ១០,៨ | ៦,៨ | ១០០ | ១.៨៩៤ | ២,៥ | ២,៤ |
| ៤០-៤៤ | ៧,២ | ៧,២ | ២៦,០ | ២៩,៦ | ១៦,៧ | ១៣,៣ | ១០០ | ១.៥៨៤ | ២,៩ | ២,៧ |
| ៤៥-៤៩ | ៧,២ | ៧,៥ | ១៧,៧ | ២៣,៤ | ១៩,៥ | ២៤,៨ | ១០០ | ១.០៧៨ | ៣,៤ | ៣,១ |
| **ស្ត្រីរៀបការរួច** | | | | | | | | | | |
| **សរុប** | **៦,២** | **១៩,៩** | **៣៤,៦** | **២២,៣** | **៩,៧** | **៧,៤** | **១០០** | **៨.០៨៨** | **២,៤** | **២,៣** |
| ១៥-១៩ | ៤១,៦ | ៥៣,៤ | ៤,៩ | - | - | - | ១០០ | ២២៦ | ០,៦ | ០,៦ |
| ២០-២៤ | ១៨,២ | ៥៩,៣ | ១៩,៥ | ២,៨ | ០,២ | - | ១០០ | ៩១១ | ១,១ | ១,១ |

| ការបែងចែកភាគរយនៃគ្រប់ស្ត្រី និងស្ត្រីបច្ចុប្បន្នរៀបការរួចអាយុ១៥-៤៩ឆ្នាំ តាមចំនួនកូនដែលធ្លាប់បង្កើត ចំនួនមធ្យមកូនកើតរស់ ចំនួនកូនមធ្យមនៅរស់រាន យោងតាមតាមក្រុមអាយុ កម្ពុជា ឆ្នាំ២០២១-២០២២ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| អាយុ | លំដាប់កំណើតកូន | | | | | | | ស្ត្រី | ចំនួនមធ្យមកូនកើតរស់ | ចំនួនមធ្យមកូននៅរស់រាន |
| | ០ | ១ | ២ | ៣ | ៤ | ៥+ | សរុប | | | |
| ២៥-២៩ | ៦,៩ | ៣១,៩ | ៤៧,២ | ១១,៦ | ២,១ | ០,៣ | ១០០ | ១.៣៧៩ | ១,៧ | ១,៧ |
| ៣០-៣៤ | ២,៩ | ១៤,៨ | ៤៩,១ | ២៥,០ | ៦,៦ | ១,៧ | ១០០ | ១.៥៩១ | ២,២ | ២,២ |
| ៣៥-៣៩ | ២,១ | ៨,៤ | ៣៧,៧ | ៣២,៦ | ១១,៨ | ៧,៤ | ១០០ | ១.៦៨៨ | ២,៧ | ២,៦ |
| ៤០-៤៤ | ៣,១ | ៥,៣ | ២៧,៣ | ៣១,៦ | ១៨,៤ | ១៤,៤ | ១០០ | ១.៣៨៩ | ៣,១ | ២,៩ |
| ៤៥-៤៩ | ២,៣ | ៦,១ | ១៧,៤ | ២៦,០ | ២១,៣ | ២៦,៩ | ១០០ | ៩០៥ | ៣,៦ | ៣,៣ |

តារាង ៣.៥.១ បង្ហាញចំនួនមធ្យមកូនកើតរស់ និងកំពុងរស់រានតាមក្រុមអាយុស្ត្រីនៅទីប្រជុំជនមាន ១.៥នាក់ តិចជាងចំនួនមធ្យមបើធៀបនឹងទីប្រជុំជនដែលកូនកើតរស់ មាន ១,៨ និងចំនួនកូនមធ្យមនៅរស់រានមាន ១,៧ ។ ក្នុងចំណោមស្ត្រីរៀបការរួចនៅទីប្រជុំជនមានចំនួនកូនជាមធ្យម ២,១នាក់ និង ជាមធ្យមមានកូននៅរស់រាន ២,០នាក់ ដែលខុសគ្នា ០,១នាក់ ខណៈពេលនៅជនបទ ចំនួនកូនកើតមាន ២,៤នាក់ និងជាមធ្យមមាន ២,៣នាក់កំពុងនៅរស់រាន។

រូប ៣.៥.១ លទ្ធភាពមានកូនពេញមួយជីវិត ( កូនធ្លាប់កើត និងកូនកំពុងនៅរស់រាន ) តាមទីកន្លែងរស់នៅ កម្ពុជា ឆ្នាំ២០២១-២០២២




## ៣.៦. លទ្ធភាពមានកូនវ័យជំទង់

ការមានផ្ទៃពោះនៅវ័យជំទង់គឺជាក្ដីកង្វល់សុខភាពដ៏ចម្បងដែលមានទំនាក់ទំនងជាមួយ នឹងអត្រាមរណភាពខ្ពស់ទាំងម្ដាយ និងកូន។ ការមានកូនក្នុងវ័យជំទង់ ត្រូវបានគេដឹងថាមានផលអាក្រក់ក្នុងសង្គម ជាពិសេសទាក់ទងនឹងការទទួលបានការអប់រំ ដោយសារស្ត្រីដែលក្លាយជាម្ដាយក្នុងវ័យជំទង់អាចត្រូវបោះបង់ការសិក្សា។ ប្រាំបួនភាគរយនៃស្ត្រីក្នុងក្រុមអាយុ១៥-១៩ឆ្នាំធ្លាប់មានផ្ទៃពោះ។

តារាង៣.៦.១ ភាគរយស្ត្រីអាយុ១៥-១៩ឆ្នាំធ្លាប់មានផ្ទៃពោះតាមចរិតលក្ខណៈអង្កេត កម្ពុជាឆ្នាំ ២០២១-២០២២

| ចរិតលក្ខណៈអង្កេត | ធ្លាប់មានផ្ទៃពោះ | | | |
|---|---|---|---|---|
| | ២០០៥ | ២០១០ | ២០១៤ | ២០២១-២០២២ |
| **អាយុ** | | | | |
| ១៥ | ០,០ | ០,៤ | ០,៦ | ១,២ |
| ១៦ | ២,១ | ១,៦ | ៣,៨ | ២,៧ |
| ១៧ | ៦,១ | ៦,៨ | ៧,៩ | ៦,៤ |

| ចរិតលក្ខណៈអង្កេត | ធ្លាប់មានផ្ទៃពោះ | | | |
|---|---|---|---|---|
| | ២០០៥ | ២០១០ | ២០១៤ | ២០២១-២០២២ |
| ១៨ | ១២,២ | ១០,៦ | ១៨,៤ | ១៤,០ |
| ១៩ | ២២,៧ | ២៥,៥ | ៣១,៣ | ៣០,២ |
| **តំបន់** | | | | |
| ទីប្រជុំជន | ៦,០ | ៤,៨ | ៦,២ | ៨,៣ |
| ជនបទ | ៨,៣ | ៩,១ | ១៣,៣ | ១០,០ |
| **កម្រិតសិក្សាអប់រំ** | | | | |
| មិនបានចូលរៀន | ២១,៤ | ១៧,០ | ៣៧,១ | ៣៥,២ |
| បឋមសិក្សា | ៩,០ | ១២,៧ | ១៨,៤ | ២០,៦ |
| មធ្យមសិក្សា | ៤,១ | ៥,៦ | ៨,១ | ៦,៥ |
| **សន្ទស្សន៍បញ្ញាភាគទ្រព្យសម្បត្តិ** | | | | |
| ទាបបំផុត | ១១,២ | ១៣,៣ | ១៨,១ | ១៦,១ |
| ទាប | ៩,៥ | ១០,៩ | ១៤,៩ | ៩,០ |
| កណ្តាល | ៧,៩ | ៩,១ | ១៣,៨ | ៩,៥ |
| ខ្ពស់ | ៧,៦ | ៦,៥ | ៨,៦ | ៨,៦ |
| ខ្ពស់បំផុត | ៥,៤ | ៤,០ | ៧,១ | ៤,២ |
| **សរុប** | **៧,៨** | **៨,២** | **១២,០** | **៩,២** |

ភាគរយស្ត្រីក្នុងក្រុមអាយុ ១៥-១៩ឆ្នាំ ដែលធ្លាប់មានផ្ទៃពោះកើនឡើងតាមអាយុដោយចាប់ពី ១%ក្នុងចំណោមស្ត្រីអាយុ១៥ឆ្នាំ ទៅ ៣០%ក្នុងចំណោមស្ត្រីអាយុ ១៩ឆ្នាំ។ ភាគរយនៃស្ត្រីអាយុ ១៥-១៩ឆ្នាំ ធ្លាប់មានផ្ទៃពោះបានធ្លាក់ចុះតាមការកើនឡើងកម្រិតសិក្សាអប់រំដោយចាប់ពី ៣៥% ក្នុងចំណោមស្ត្រីអាយុ ១៥-១៩ឆ្នាំ មិនបានចូលរៀនមកតិចជាង ១% ក្នុងចំណោមស្ត្រីទទួលបានការសិក្សាអប់រំកម្រិតមធ្យមសិក្សា ឬខ្ពស់ជាង។ ការមានផ្ទៃពោះក្នុងវ័យជំទង់ជាទូទៅមានទាបក្នុងចំណោមគ្រួសារដែលមានបញ្ញាភាគទ្រព្យសម្បត្តិខ្ពស់បំផុតគឺ ៤% ក្នុងចំណោមស្ត្រីអាយុ ១៥-១៩ឆ្នាំ ដែលស្ថិតនៅក្នុងគ្រួសារដែលមានបញ្ញាភាគទ្រព្យសម្បត្តិខ្ពស់បំផុតធៀបនឹង១៦% នៃស្ត្រីដែលមានស្ថានភាពទ្រព្យសម្បត្តិទាបបំផុត។

ភាគរយស្ត្រីក្នុងក្រុមអាយុ១៥-១៩ឆ្នាំ ដែលធ្លាប់មានផ្ទៃពោះបានកើនឡើងពី ៧,៨%ក្នុងឆ្នាំ ២០០៥ទៅ ១២,០% ក្នុងឆ្នាំ ២០២១៤ និងបានធ្លាក់ចុះមកត្រឹមតែ ៩%ក្នុងឆ្នាំ២០២១-២០២២ មានការប្រែប្រួលមិនដូចគ្នាតាមអាយុជាក់លាក់ទេ ភាគរយស្ត្រីអាយុ១៥ឆ្នាំ ធ្លាប់មានផ្ទៃពោះបានធ្លាក់ចុះទ្វេដងពី ឆ្នាំ២០១៤ មកឆ្នាំ២០២១-២០២២ (១,២ និង០,៦%) ខណៈដែលស្ត្រីអាយុ១៨ឆ្នាំបានធ្លាក់ចុះច្រើនផងដែរ (១៤ ទល់នឹង ១៨,៤%)។

## រូប ៣.៦.១ ភាគរយស្រ្តីអាយុ ១៥-១៩ឆ្នាំ ធ្លាប់មានផ្ទៃពោះ កម្ពុជា ឆ្នាំ២០០៥ ដល់ ឆ្នាំ២០២១-២០២២




## ៣.៧. គម្លាតកំណើត

គម្លាតកំណើតខ្លី (SBI) មានផលប៉ះពាល់អវិជ្ជមានដល់សុខភាពទាំងម្តាយ និងកូនក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ទី ៣ មានគោលបំណងកាត់បន្ថយអត្រាមរណភាពមាតា និងកុមារអាយុក្រោមប្រាំឆ្នាំនៅឆ្នាំ២០៣០។ ឧប្បត្តិហេតុនៃការស្លាប់ទាំងនេះត្រូវបានផ្សារភ្ជាប់យ៉ាងខ្លាំងជាមួយនឹងគម្លាតកំណើតខ្លី។ ការកំណត់កត្តាដែលទាក់ទងនឹងគម្លាតកំណើតខ្លី (SBI) គឺមានសារៈសំខាន់សម្រាប់ការធ្វើអន្តរាគមន៍កម្មវិធីសមស្រប ដើម្បីកាត់បន្ថយការកើតឡើងនៃ SBI និងផលវិបាកមិនល្អ។

លទ្ធផលអង្កេតប្រជាសាស្រ្ត និងសុខភាពកម្ពុជា ឆ្នាំ២០២១-២២ បង្ហាញថាគម្លាតកំណើតមធ្យមរវាងកំណើតនៅកម្ពុជាមានចំនួន ៥៤,១ ខែ។ មេដ្យានគម្លាតកំណើតបានកើនឡើងពី ៣៦,៨ខែ ក្នុងឆ្នាំ២០០៥ ទៅ ៤០,០ខែក្នុងឆ្នាំ២០១០ ៤៣,៨ខែ ក្នុងឆ្នាំ២០១៤ និង ៥៤,១ខែក្នុងឆ្នាំ ២០២១-២២។ តាមវិភាគលទ្ធផលស៊េរីទិន្នន័យអង្កេតប្រជាសាស្រ្តសុខភាពបង្ហាញថាសមមាត្រគម្លាតកំណើតមានតិចជាង២៤ខែ និងបានធ្លាក់ចុះពី ១៨,២%ក្នុងឆ្នាំ២០០៥ មកត្រឹម ១០,៨% និង គម្លាតកំណើតវែង ៦០ខែឡើងបានកើនឡើងយ៉ាងខ្លាំងពី ២០,៩ នៅឆ្នាំ២០០៥ ទៅ ៤៣,៣% នៅឆ្នាំ ២០២១-២០២២។

រូប ៣.៧.១ ភាគរយគម្លាតកំណើតតិតជាខែ កម្ពុជាឆ្នាំ២០០៥ ដល់ឆ្នាំ២០២១- ២០២២




ទោះបីជាថ្នាក់ក្រោមជាតិបង្ហាញពីគម្លាតកំណើតជាមធ្យមល្អបំផុតក៏ដោយក៏បណ្តារាជធានី ខេត្តនីមួយៗមានភាពខុសគ្នានូវគម្លាតកំណើតផងដែរ។ លទ្ធផលបង្ហាញថាតាមបណ្តារាជធានី ខេត្តភាគច្រើនមានភាគរយខ្ពស់នៃគម្លាតកំណើតរយៈពេលខ្លី។ រាជធានីភ្នំពេញមានគម្លាតកំណើតរយៈពេលខ្លី ១៣,១% ខេត្តបន្ទាយមានជ័យ ១៣,៣% ខេត្តកំពង់ឆ្នាំង ១៤,១% ខេត្តកំពង់ចាម ១៤,៧% និងនៅខេត្តកែបត្រូវបានប៉ាន់ស្មាន ១៥,០%។

ផែនទី ៣.៧ ភាគរយគម្លាតកំណើតតិចជាង២៤ខែ តាមរាជធានី ខេត្ត កម្ពុជាឆ្នាំ២០២១-២០២២




មេដ្យាន និងសមាមាត្រនៃគម្លាតកំណើតរយៈវែង (៦០ខែនិងច្រើនជាង) បានធ្លាក់ចុះជាមួយនឹងការកើនឡើងកម្រិតអប់រំម្ដាយពី ៥៨,៧ខែ ឬ ៤៨,៥% នៃម្ដាយមិនបានចូលរៀនមក៤០,៨ខែ ឬ ២២,៤% ដែលម្ដាយទទួលបានកម្រិតសិក្សាអប់រំខ្ពស់ជាងមធ្យមសិក្សា។ ស្ត្រីមានបញ្ចភាគទ្រព្យសម្បត្តិខ្ពស់មានគម្លាតកំណើតយូរ។ គម្លាតកំណើតជាមធ្យមក្នុងចំណោមស្ត្រីមានបញ្ចភាគទ្រព្យសម្បត្តិខ្ពស់បំផុតគឺយូរជាង២ខែ ធៀបនឹងក្នុងចំណោមស្ត្រីមានបញ្ចភាគទ្រព្យសម្បត្តិទាបបំផុត (៥៣,៥ខែទល់នឹង ៥១,៦ ខែ)។

រូប ៣.៧.២ ភាគរយគម្លាតកំណើតតិចជាង២៤ខែ ៦០ខែឡើង និងមេដ្យានគម្លាតកំណើត កម្ពុជា ឆ្នាំ ២០០៥ ដល់ឆ្នាំ ២០២១-២០២២




## តារាង ៣.៧.១ គម្លាតកំណើតនៃស្ត្រីអាយុ ១៥-៤៩ឆ្នាំ តាមចរិតលក្ខណៈអង្កេត កម្ពុជាឆ្នាំ ២០២១-២០២២

| ចរិតលក្ខណៈអង្កេត | គម្លាតកំណើត | | | | | | មេដ្យាន គម្លាត កំណើត |
|---|---|---|---|---|---|---|---|
| | សរុប | <២៤ | ២៤-៣៥ | ៣៦-៤៧ | ៤៧-៥៦ | ៦០+ | |
| ២០០៥ | ១០០ | ១៨,២ | ២៩,៦ | ១៩,៤ | ១២,០ | ២០,៩ | ៣៦,៨ |
| ២០១០ | ១០០ | ១៦,១ | ២៦,៣ | ១៩,៤ | ១២,៨ | ២៥,៤ | ៤០,០ |
| ២០១៤ | ១០០ | ១៣,៣ | ២៦,០ | ១៩,៦ | ១៤,០ | ២៩,៥ | ៤៣,៨ |
| ២០២១-២០២២ | ១០០ | ១០,៨ | ១៦,១ | ១៥,៥ | ១៤,៣ | ៤៣,២ | ៥៤,១ |
| **តំបន់** | | | | | | | |
| ទីប្រជុំជន | ១០០ | ១២,៦ | ១៥,៦ | ១៥,២ | ១២,៨ | ៤៣,៨ | ៥៣,៧ |
| ជនបទ | ១០០ | ៩,៧ | ១៦,៤ | ១៥,៧ | ១៥,៣ | ៤២,៨ | ៥៤,៦ |
| **រាជធានី ខេត្ត** | | | | | | | |
| បន្ទាយមានជ័យ | ១០០ | ១៣,៣ | ១១,៧ | ១៥,៣ | ១៣,៩ | ៤៥,៨ | ៥៧,១ |
| បាត់ដំបង | ១០០ | ៩,៩ | ១៤,៩ | ១៧,៧ | ១៨,៥ | ៣៩,០ | ៥២,៣ |

| ចរិតលក្ខណៈអង្កេត | គម្លាតកំណើត | | | | | | មេដ្យាន គម្លាត កំណើត |
|---|---|---|---|---|---|---|---|
| | សរុប | <២៤ | ២៤-៣៥ | ៣៦-៤៧ | ៤៧-៥៦ | ៦០+ | |
| កំពង់ចាម | ១០០ | ១៤,៧ | ១២,៩ | ១២,៧ | ១៥,០ | ៤៤,៧ | ៥៦,៨ |
| កំពង់ឆ្នាំង | ១០០ | ១៤,១ | ២២,០ | ១៥,០ | ១៣,១ | ៣៥,៨ | ៤៦,៩ |
| កំពង់ស្ពឺ | ១០០ | ៩,៦ | ១១,៧ | ១៣,១ | ១៤,២ | ៥១,៤ | ៦១,៦ |
| កំពង់ធំ | ១០០ | ១១,៥ | ១៦,៤ | ១២,៨ | ១៦,៥ | ៤២,៨ | ៥៣,៧ |
| កំពត | ១០០ | ១១,៣ | ១៤,៤ | ១៤,៨ | ១៤,៩ | ៤៤,៧ | ៥៦,១ |
| កណ្ដាល | ១០០ | ១០,៦ | ១៧,៦ | ១៩,១ | ១២,០ | ៤០,៧ | ៥២,១ |
| កោះកុង | ១០០ | ៩,២ | ២០,២ | ១៣,៤ | ១៦,៧ | ៤០,៦ | ៥៣,៣ |
| ក្រចេះ | ១០០ | ៥,៥ | ២៣,៦ | ១៧,៦ | ១២,៩ | ៤០,៤ | ៥១,២ |
| មណ្ឌលគីរី | ១០០ | ១០,៥ | ១២,៣ | ១៤,៧ | ២០,១ | ៤២,៣ | ៥៥,៤ |
| ភ្នំពេញ | ១០០ | ១៣,១ | ១៧,១ | ១១,៧ | ១៣,៣ | ៤៤,៨ | ៥៣,៨ |
| ព្រះវិហារ | ១០០ | ១២,៩ | ១៥,៩ | ១៦,៧ | ១៨,០ | ៣៦,៦ | ៥១,៥ |
| ព្រៃវែង | ១០០ | ៦,៥ | ១៧,៨ | ១៨,០ | ១៤,២ | ៤៣,៦ | ៥៤,៦ |
| ពោធិ៍សាត់ | ១០០ | ៧,១ | ១៧,១ | ២៥,៨ | ១២,៧ | ៣៧,៤ | ៤៨,១ |
| រតនគីរី | ១០០ | ៨,៩ | ១៤,១ | ១៦,៧ | ១៥,៣ | ៤៥,០ | ៥៧,៨ |
| សៀមរាប | ១០០ | ១២,៤ | ១៧,៦ | ១៤,៣ | ១៤,៣ | ៤១,៣ | ៥០,៩ |
| ព្រះសីហនុ | ១០០ | ១០,៧ | ២២,៤ | ១១,៨ | ១២,៥ | ៤២,៧ | ៥៣,៧ |
| ស្ទឹងត្រែង | ១០០ | ១០,៦ | ១៩,៤ | ១៥,៧ | ១៥,០ | ៣៩,៣ | ៥៣,៩ |
| ស្វាយរៀង | ១០០ | ១២,៣ | ១៤,២ | ១២,៣ | ១៣,២ | ៤៨,០ | ៥៧,៧ |
| តាកែវ | ១០០ | ៧,៥ | ១៤,៧ | ១៧,៨ | ១៣,០ | ៤៧,០ | ៥៧,១ |
| ឧត្តរមានជ័យ | ១០០ | ១១,០ | ៩,២ | ១៣,៤ | ១៨,៥ | ៤៧,៩ | ៥៩,១ |
| កែប | ១០០ | ១៥,០ | ១៨,៥ | ១៥,៧ | ១៦,៨ | ៣៤,០ | ៤៨,៦ |
| ប៉ៃលិន | ១០០ | ១២,០ | ១៨,៤ | ១៧,១ | ១៣,០ | ៣៩,៤ | ៥១,១ |
| ត្បូងឃ្មុំ | ១០០ | ៥,១ | ១៦,៥ | ២៣,៣ | ១១,៨ | ៤៣,៣ | ៥៥,៤ |
| **កម្រិតសិក្សាអប់រំ** | | | | | | | |
| មិនបានចូលរៀន | ១០០ | ១០,០ | ១៥,១ | ១២,៨ | ១៣,៦ | ៤៨,៥ | ៥៨,៧ |
| បឋមសិក្សា | ១០០ | ៨,៤ | ១៥,១ | ១៣,៨ | ១៤,១ | ៤៨,៧ | ៥៩,០ |
| មធ្យមសិក្សា | ១០០ | ១២,៥ | ១៨,០ | ១៧,៥ | ១៤,៩ | ៣៧,១ | ៤៩,៥ |
| ខ្ពស់ជាងមធ្យមសិក្សា | ១០០ | ២២,៧ | ១៥,៤ | ២៤,២ | ១៥,៣ | ២២,៤ | ៤០,៨ |
| **សន្ទស្សន៍បញ្ញាភាគទ្រព្យសម្បត្តិ** | | | | | | | |

| ចរិតលក្ខណៈអង្កេត | គម្លាតកំណើត | | | | | | មេធ្យាន គម្លាត កំណើត |
|---|---|---|---|---|---|---|---|
| | សរុប | <២៤ | ២៤-៣៥ | ៣៦-៤៧ | ៤៧-៥៦ | ៦០+ | |
| ទាបបំផុត | ១០០ | ១១,៥ | ១៧,២ | ១៦,០ | ១៥,៨ | ៣៩,៤ | ៥១,៦ |
| ទាប | ១០០ | ៨,២ | ១៤,៨ | ១៥,៩ | ១៥,៤ | ៤៥,៨ | ៥៦,៨ |
| កណ្ដាល | ១០០ | ៩,៧ | ១៧,៥ | ១៦,៦ | ១២,៥ | ៤៣,៧ | ៥៣,៥ |
| ខ្ពស់ | ១០០ | ១០,៧ | ១៥,៥ | ១៥,១ | ១៣,៦ | ៤៥,១ | ៥៥,៩ |
| ខ្ពស់បំផុត | ១០០ | ១៣,៦ | ១៥,៦ | ១៤,២ | ១៤,១ | ៤២,៦ | ៥៣,៥ |

# ជំពូក ៤

# ផែនការគ្រួសារ

គូស្វាមីភរិយាអាចប្រើវិធីសាស្ត្រពន្យារកំណើតដើម្បីកំណត់ ឬគម្លាតចំនួនកូនដែលចង់បាន។ កម្រិតនៃការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតបច្ចុប្បន្ន គឺជាសូចនាករសំខាន់បំផុតដើម្បីវាស់វែងភាពសម្រេចបាននៃកម្មវិធីផែនការគ្រួសារ។ វិធីសាស្ត្រពន្យារកំណើតនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងការវាស់វែងលទ្ធភាពមានកូនផងដែរ។ ជំពូកនេះបង្ហាញព័ត៌មានស្តីពីការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើត និងអត្រាលទ្ធភាពមានកូនសរុប។ ជំពូកនេះផងដែរក៏ត្រូវបានកំណត់ពីតម្រូវការមិនបានឆ្លើយតបសម្រាប់ផែនការគ្រួសារ និងឥទ្ធិពលលើការទទួលបានសារស្តីពីផែនការគ្រួសារតាមទីកន្លែងរស់នៅ រាជធានី ខេត្ត កម្រិតសិក្សាអប់រំ និងសន្ទស្សន៍បញ្ចភាគទ្រព្យសម្បត្តិជាដើម។

## ៤.១. ការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតបច្ចុប្បន្ន

ជាទូទៅអត្រាប្រេវ៉ាឡង់ការពន្យារកំណើតមាន ៦២% ចំណោមស្ត្រីបច្ចុប្បន្នរៀបការរួចអាយុ ១៥-៤៩ឆ្នាំ។ ៤៥% នៃស្ត្រីបច្ចុប្បន្នរៀបការរួចបានប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតបែបទំនើប ១៧%ប្រើប្រាស់វិធីសាស្ត្របែបបុរាណ។ ២៤% នៃស្ត្រីមិនទាន់រៀបការដែលមានសកម្មភាពរួមភេទបានប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតបែបទំនើបទាំងអស់។ ការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតបែបទំនើបក្នុងចំណោមស្ត្រីបច្ចុប្បន្នរៀបការរួចនៅជនបទ(៤៧%) មានអត្រាខ្ពស់ជាងនៅទីប្រជុំជន (៤១%)។

រូប ៤.១ ភាគរយបច្ចុប្បន្នប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតតាមទីកន្លែងរស់នៅ កម្ពុជាឆ្នាំ ២០២១-២០២២



ស្ត្រីបច្ចុប្បន្នរៀបការរួចប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតណាមួយអត្រាលទ្ធភាពមានកូនខ្ពស់ (៤,៧ ក្នុងចំណោមស្ត្រីម្នាក់) ធៀបនឹងស្ត្រីបច្ចុប្បន្នមិនប្រើប្រាស់វិធីសាស្ត្រពន្យារកំណើត (២,០ ក្នុងចំណោមស្ត្រីម្នាក់)។ ស្ត្រីនៅទីប្រជុំជនដែលមិនប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតអត្រាលទ្ធភាពមានកូន (១,៥ក្នុងចំណោមស្ត្រីម្នាក់) គឺទាបជាងនៅជនបទ (២,៥នាក់ក្នុងចំណោមស្ត្រីម្នាក់)។ មិនមានភាពខុសគ្នារវាងទីប្រជុំជន និងជនបទសម្រាប់ស្ត្រីកំពុងប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតណាមួយវិធីសាស្ត្របែបទំនើប ឬបុរាណ។

## រូប ៤.២ អត្រាលទ្ធភាពមានកូននៃស្ត្រីបច្ចុប្បន្នប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតតាមទីកន្លែងរស់នៅ កម្ពុជា ឆ្នាំ២០២១-២០២២




សមាមាត្រស្ត្រីបច្ចុប្បន្នរៀបការរួចកំពុងប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតណាមួយកើនឡើងតាមការកើនឡើងកម្រិតសិក្សាអប់រំ៥៧,១% ក្នុងចំណោមស្ត្រីមិនបានចូលរៀនទៅ ៦៤,២% សម្រាប់ស្ត្រីបានទទួលខ្ពស់ជាងមធ្យមសិក្សា។ ការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតក៏កើនឡើងតាមបញ្ចភាគទ្រព្យសម្បត្តិផងដែរពី ៥៩,២% ក្នុងចំណោមស្ត្រីមានបញ្ចភាគទ្រព្យសម្បត្តិទាបបំផុត ទៅ ៦៧,៥ភាគរយ នៃស្ត្រីមានបញ្ចភាគទ្រព្យសម្បត្តិខ្ពស់បំផុត។ ទោះយ៉ាងណាក៏ដោយការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតបែបទំនើបបានថយចុះជាមួយការកើនឡើងនៃ កម្រិតសិក្សាអប់រំ និងចំណូល។

ការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតណាមួយក្នុងចំណោមស្ត្រីរៀបការឬរស់នៅជាមួយដៃគូ (នៅក្រោមអាយុ ១៥-៤៩ឆ្នាំ) ដែលមិនបានប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទាបបំផុត គឺមាននៅខេត្តពោធិ៍សាត់(៣២,៥%) ខណៈដែរខេត្តមណ្ឌលគីរីមានខ្ពស់បំផុត (៧០,៤%) មានភាពខុសគ្នាតាមរាជធានី ខេត្តក្នុងការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតបែបបុរាណ និងបែបទំនើប ដែលមាននៅក្នុងតារាង ៤.១.១។

### ផែនទី៤.១ ភាគរយប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតបែបទំនើបតាមរាជធានីខេត្ត កម្ពុជា ឆ្នាំ២០២១-២០២២




ស្ត្រីនៅកម្ពុជាមានកូនច្រើន និងបានប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតខ្ពស់ផងដែរ (៦២% នៃអ្នកប្រើវិធីសាស្ត្រពន្យារកំណើតមានកូន ៤,៧នាក់ ខណៈដែលមានតែ ៣៨% ដែលមិនបានប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតណាមួយមានកូនតែ ២,០នាក់។ មានភាពខុសគ្នាគួរឱ្យកត់សម្គាល់រវាងស្ត្រីដែលប្រើវិធីសាស្ត្រពន្យារកំណើតបែបបុរាណ (១៧% មានកូន៤,៨នាក់) និងវិធីសាស្ត្រទំនើប (៤៥% មានកូន ៤,៦នាក់)។

មានភាពខុសគ្នាក្នុងចំណោមស្ត្រីរៀបការរួចដែលបានប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតណាមួយ រវាងទីប្រជុំជន និងជនបទ (៦៦% មានកូន ៤,៨ ទល់នឹង ៥៩% មានកូន ៤,៦)។

ក្នុងចំណោមស្ត្រីអាយុ១៥-៤៩ឆ្នាំ ដែលមិនបានប្រើវិធីសាស្ត្រពន្យារកំណើតណាមួយមានសមាមាត្រខ្ពស់នៅក្នុងខេត្តពោធិ៍សាត់ (៦៧,៥% មានកូន ២,៥នាក់) ទល់នឹង (៣៣% មានកូន ៥,៤នាក់ ) សម្រាប់ការប្រើប្រាស់វិធី

សាស្ត្រពន្យារកំណើតណាមួយ  ខេត្តកោះកុង (៥៤,៣% មានកូន ២,៤នាក់) ទល់នឹង (៤៦% មានកូន ៤,១នាក់) សម្រាប់ប្រើវិធីសាស្ត្រពន្យារកំណើតណាមួយ និងខេត្តកំពង់ចាម (៥៤% មានកូន ២,៦នាក់) ទល់នឹង (៤៦,៤% មានកូន ៥,០នាក់) សម្រាប់ការប្រើប្រាស់វិធីពន្យារកំណើតណាមួយ ខណៈដែលខេត្តមណ្ឌលគិរីមានអត្រាទាប (៣០% មានកូន ២,៥នាក់) ទល់នឹង (៧០% មានកូន ៤,៤នាក់) សម្រាប់ការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតណាមួយ ខេត្តកណ្តាល (៣១% មានកូន ១,៨នាក់) ទល់នឹង (៦៩% មានកូន ៥,២នាក់) សម្រាប់ការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតណាមួយ និងខេត្តព្រះសីហនុ (៣២% មានកូន១,៨ ទល់នឹង ៦៨% មានកូន ៤,៣នាក់) សម្រាប់ការប្រើវិធីសាស្ត្រពន្យារកំណើតណាមួយ។

### តារាង ៤.១.១ លទ្ធភាពមានកូនសរុបតាមការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតបច្ចុប្បន្នក្នុងចំណោមស្ត្រីអាយុ ១៥-៤៩ឆ្នាំ តាមចរិតលក្ខណៈអង្កេត កម្ពុជាឆ្នាំ ២០២១-២០២២

| ចរិតលក្ខណៈអង្កេត | បច្ចុប្បន្នប្រើប្រាស់វិធីសាស្ត្រពន្យារកំណើត | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | មិនប្រើ | | វិធីសាស្ត្រណាមួយ | | បុរាណ | | ទំនើប | |
| | សរុប | ភាគរយ | លទ្ធភាពមានកូនស្ត្រីម្នាក់ | ភាគរយ | លទ្ធភាពមានកូនស្ត្រីម្នាក់ | ភាគរយ | លទ្ធភាពមានកូនស្ត្រីម្នាក់ | ភាគរយ | លទ្ធភាពមានកូនសរុប |
| **តំបន់** | | | | | | | | | |
| ទីប្រជុំជន | ២,៤ | ៣៤,១ | ១,៥ | ៦៥,៩ | ៤,៨ | ២៤,៤ | ៤,៨ | ៤១,៤ | ៤,៨ |
| ជនបទ | ៣,០ | ៤០,៧ | ២,៥ | ៥៩,៣ | ៤,៦ | ១២,៤ | ៤,៨ | ៤៦,៩ | ៤,៦ |
| **រាជធានី ខេត្ត** | | | | | | | | | |
| បន្ទាយមានជ័យ | ២,៦ | ៣៧,៨ | ២,០ | ៦២,២ | ៤,៤ | ៦,០ | * | ៥៦,២ | ៤,៤ |
| បាត់ដំបង | ២,៩ | ៣៤,៥ | ២,២ | ៦៥,៥ | ៤,៧ | ១៤,៤ | ៤,១ | ៥១,១ | ៤,៩ |
| កំពង់ចាម | ៣,០ | ៥៣,៦ | ២,៦ | ៤៦,៤ | ៥,០ | ៧,៥ | ៣,៩ | ៣៨,៩ | ៤,៩ |
| កំពង់ឆ្នាំង | ២,៨ | ៣៨,១ | ២,២ | ៦១,៩ | ៥,១ | ១៨,២ | ៥,៦ | ៤៣,៧ | ៤,៦ |
| កំពង់ស្ពឺ | ២,៥ | ៣៨,២ | ១,៧ | ៦១,៨ | ៤,២ | ១៦,៦ | ៤,១ | ៤៥,៣ | ៤,៤ |
| កំពង់ធំ | ៣,២ | ៤០,២ | ២,៣ | ៥៩,៨ | ៥,៣ | ១៣,២ | ៤,១ | ៤៦,៦ | ៥,៤ |
| កំពត | ២,៥ | ៣៣,៧ | ២,០ | ៦៦,៣ | ៣,៩ | ១៥,៤ | ៤,៣ | ៥០,៩ | ៣,៩ |
| កណ្ដាល | ២,៩ | ៣០,៧ | ១,៨ | ៦៩,៣ | ៥,២ | ២៥,៣ | ៥,៦ | ៤៤,០ | ៤,៧ |
| កោះកុង | ២,៩ | ៥៤,៣ | ២,៤ | ៤៥,៧ | ៤,១ | ៦,៣ | ១,៣ | ៣៩,៤ | ៤,៤ |
| ក្រចេះ | ៣,៣ | ៤៣,៣ | ២,៨ | ៥៦,៧ | ៤,៧ | ១៦,២ | ៤,៤ | ៤០,៥ | ៤,៨ |
| មណ្ឌលគីរី | ៣,០ | ២៩,៦ | ២,៥ | ៧០,៤ | ៤,៤ | ១៥,៤ | ៤,៤ | ៥៥,០ | ៤,១ |
| ភ្នំពេញ | ២,៣ | ៣២,០ | ១,១ | ៦៨,០ | ៥,០ | ៣១,៨ | ៤,៨ | ៣៦,៣ | ៥,០ |

| ចរិតលក្ខណៈអង្កេត | បច្ចុប្បន្នប្រើប្រាស់វិធីសាស្រ្តពន្យារកំណើត | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | មិនប្រើ | | វិធីសាស្រ្តណាមួយ | | បុរាណ | | ទំនើប | |
| | សរុប | ភាគរយ | លទ្ធភាពមានកូនសរុប | ភាគរយ | លទ្ធភាពមានកូនសរុប | ភាគរយ | លទ្ធភាពមានកូនសរុប | ភាគរយ | លទ្ធភាពមានកូនសរុប |
| ព្រះវិហារ | ៣,០ | ៣៣,៧ | ២,៥ | ៦៦,៣ | ៤,៤ | ១៤,៣ | ៣,៥ | ៥២,០ | ៤,៤ |
| ព្រៃវែង | ៣,៣ | ៣៦,៨ | ២,៩ | ៦៣,២ | ៥,០ | ១៤,៦ | ៥,៦ | ៤៨,៧ | ៥,០ |
| ពោធិ៍សាត់ | ២,៩ | ៦៧,៥ | ២,៥ | ៣២,៥ | ៥,៤ | ៧,១ | * | ២៥,៤ | ៤,៩ |
| រតនគីរី | ៣,០ | ៣៦,៤ | ២,៥ | ៦៣,៦ | ៤,២ | ៦,១ | ១,០ | ៥៧,៥ | ៤,៣ |
| សៀមរាប | ២,៦ | ៣៤,៥ | ២,៤ | ៦៥,៥ | ៤,១ | ១៤,៤ | ៦,៩ | ៥១,១ | ៣,៨ |
| ព្រះសីហនុ | ២,៦ | ៣១,៩ | ១,៨ | ៦៨,១ | ៤,៣ | ២៣,១ | ៤,៦ | ៤៥,០ | ៤,១ |
| ស្ទឹងត្រែង | ៣,៤ | ៤៥,៥ | ២,៧ | ៥៤,៥ | ៤,៦ | ១១,៨ | ៤,៥ | ៤២,៦ | ៤,៨ |
| ស្វាយរៀង | ៣,០ | ៤១,៩ | ២,៥ | ៥៨,១ | ៤,៦ | ១៧,១ | ៥,០ | ៤១,០ | ៤,៥ |
| តាកែវ | ២,៧ | ៤០,៦ | ២,០ | ៥៩,៤ | ៤,៦ | ១៤,១ | ៣,១ | ៤៥,៣ | ៥,០ |
| ឧត្តរមានជ័យ | ២,៦ | ៣៣,៨ | ២,២ | ៦៦,២ | ៣,២ | ១១,៨ | ២,៨ | ៥៤,៥ | ៣,៣ |
| កែប | ២,០ | ៣៨,៩ | ២,០ | ៦១,១ | ៤,០ | ១២,០ | ៣,៤ | ៤៩,០ | ២,០ |
| ប៉ៃលិន | ២,៩ | ៣៦,១ | ២,១ | ៦៣,៩ | ៤,២ | ១៧,៧ | ៤,៧ | ៤៦,២ | ៣,៨ |
| ត្បូងឃ្មុំ | ២,៩ | ៤០,៧ | ២,៣ | ៥៩,៣ | ៤,៥ | ១៨,១ | ៤,៨ | ៤១,២ | ៤,៥ |
| **កម្រិតសិក្សាអប់រំ** | | | | | | | | | |
| មិនបានចូលរៀន | ៣,៤ | ៤២,៩ | ២,៩ | ៥៧,១ | ៤,២ | ១០,៣ | ៣,០ | ៤៦,៨ | ៤,១ |
| បឋមសិក្សា | ៣,១ | ៣៧,៤ | ២,៤ | ៦២,៦ | ៤,៦ | ១៦,២ | ៥,០ | ៤៦,៤ | ៤,៥ |
| មធ្យមសិក្សា | ២,៦ | ៣៧,៣ | ១,៩ | ៦២,៧ | ៤,៧ | ១៩,៦ | ៤,៤ | ៤៣,១ | ៤,៨ |
| ខ្ពស់ជាងមធ្យមសិក្សា | ២,៤ | ៣៥,៨ | ១,៣ | ៦៤,២ | ៤,២ | ២៨,៤ | ៥,៤ | ៣៥,៨ | ៣,៣ |
| **សន្ទស្សន៍បញ្ជាភាគទ្រព្យសម្បត្តិ** | | | | | | | | | |
| ទាបបំផុត | ៣,៥ | ៤០,៨ | ២,៩ | ៥៩,២ | ៥,០ | ១០,២ | ៥,៤ | ៤៩,១ | ៤,៩ |
| ទាប | ៣,១ | ៤០,៤ | ២,៧ | ៥៩,៦ | ៤,៦ | ១៣,៨ | ៤,១ | ៤៥,៨ | ៤,៧ |
| កណ្តាល | ២,៧ | ៤០,២ | ២,០ | ៥៩,៨ | ៤,៥ | ១៦,២ | ៥,០ | ៤៣,៦ | ៤,៣ |
| ខ្ពស់ | ២,៦ | ៣៧,៤ | ១,៨ | ៦២,៦ | ៤,៧ | ១៩,៣ | ៥,១ | ៤៣,៣ | ៤,៤ |
| ខ្ពស់បំផុត | ២,២ | ៣២,៥ | ១,២ | ៦៧,៥ | ៤,៧ | ២៥,១ | ៤,៤ | ៤២,៤ | ៤,៩ |
| **សរុប** | ២,៧ | ៣៨,១ | ២,០ | ៦១,៩ | ៤,៧ | ១៧,២ | ៤,៨ | ៤៤,៧ | ៤,៦ |

*កំណត់សម្គាល់: សញ្ញាផ្កាយបង្ហាញថាតួលេខមួយគឺផ្អែកលើករណីដែលមិនប្រើមេគុណតិចជាង ២៥ និងត្រូវបានលុបចោល ។*

## ៤.២. ទំហំគ្រួសារចង់បាន

អ្នកផ្តល់ចម្លើយដែលមិនទាន់មានកូនត្រូវបានសួរថា ″ ប្រសិនបើអ្នកអាចជ្រើសរើសចំនួនកូនឱ្យពិតប្រាកដក្នុងជីវិតរបស់អ្នកតើចង់បានចំនួនប៉ុន្មាននាក់ដែរ?" អ្នកផ្តល់ចម្លើយដែលមានកូនរួចហើយត្រូវបានគេសួរថាៈ "ប្រសិនបើអ្នកអាចត្រឡប់ទៅក្រោយនៅពេលមិនទាន់មានកូន ហើយអាចជ្រើសរើសចំនួនកូនបានពេញមួយជីវិត តើចង់បានប៉ុន្មាននាក់ដែរ? ″

ជាមធ្យមស្ត្រីចង់បានកូនជាមធ្យម(២,៨នាក់)។ ជាការពិតផងដែរក្នុងចំណោមស្ត្រីបច្ចុប្បន្នរៀបការរួច ធៀបនឹងស្ត្រីមិនទាន់រៀបការមានកូន( ៣,០នាក់ និង ៣,២នាក់ រៀងគ្នា)។ ស្ត្រីមិនចង់មានកូនសោះប៉ុន្តែជាក់ស្តែងមានកូន ២,៥នាក់។ ដោយឡែកស្ត្រីដែលចង់បានកូនពី៣ទៅ៤នាក់ ជាក់ស្តែងមានកូន៣នាក់។ ចំណែកឯស្ត្រីដែលចង់បានកូនចាប់ពី៥នាក់ឡើងទៅ ជាក់ស្តែងមានកូន៣,៥នាក់។ ការចង់បានចំនួនកូនរបស់ស្ត្រីនៅទីប្រជុំជនមាន តិចជាងជាងស្ត្រីនៅជនបទ។ ស្ត្រីនៅទីប្រជុំជនដែលមិនចង់បានកូន ជាក់ស្តែងគាត់មានកូន ១,៤ នាក់បើធៀបនឹង ២,៤ នាក់នៅជនបទ។ ស្ត្រីនៅទីប្រជុំជន ដែលចង់បាន៣ទៅ៤នាក់ ជាក់ស្តែងមានកូន ២,៧ នាក់ ធៀបនឹង ៣,២នាក់នៅជនបទ។ ចំណែកឯស្ត្រីដែលចង់មានកូន ៥នាក់ឬច្រើនជាង នៅទីប្រជុំជន ជាក់ស្តែងមានកូន ៣,៤នាក់ ធៀបនឹង ៣,៦នាក់នៅជនបទ។

### រូប ៤.៣ អត្រាលទ្ធភាពមានកុនសរុប នៃទំហំគ្រួសារចង់បាន តាមទីកន្លែងរស់នៅ កម្ពុជា ឆ្នាំ ២០២១-២០២២



តារាង ៤.២.១ បង្ហាញអត្រាលទ្ធភាពមានកូនសរុប (TFR) តាមការចង់បានចំនួនកូន ដោយផ្អែកលើចំនួនកូនដែលនៅរស់រាន។ ក្នុងចំណោមស្ត្រីអាយុ ១៥-៤៩ឆ្នាំ មិនចង់បានកូនដែលមានកម្រិតសិក្សាអប់រំខ្ពស់ជាងមធ្យមសិក្សា ជាមធ្យមអត្រាលទ្ធភាពមានកូនសរុប (TFR) បច្ចុប្បន្នរបស់គាត់មាន ១,៣នាក់ ខណៈដែលស្ត្រីមិនបានចូលរៀន មិនចង់មានកូន អត្រាលទ្ធភាពមានកូនសរុប (TFR) បច្ចុប្បន្នគាត់មាន កូន ២,៧នាក់។

ចំណោមស្ត្រីរៀបការរួចមានបញ្ចាភាគទ្រព្យសម្បត្តិទាបបំផុតមិនចង់បានកូន បច្ចុប្បន្នមានកូនមធ្យម២,៥នាក់ ធៀបនឹង១,៤នាក់ ក្នុងចំណោមស្ត្រីមានបញ្ចាភាគទ្រព្យសម្បត្តិខ្ពស់បំផុត។ ស្ត្រីមានបញ្ចាភាគទ្រព្យសម្បត្តិទាបបំផុតដែលចង់បានកូនប្រាំនាក់ ឬច្រើនជាងបច្ចុប្បន្នអត្រាលទ្ធភាពមានកូនសរុបរបស់គាត់គឺ ៣,៩ ធៀបនឹង៤,១ ក្នុងចំណោមស្ត្រីមានបញ្ចាភាគទ្រព្យសម្បត្តិខ្ពស់បំផុត (តារាង ៤.២.១)។

### តារាង ៤.២.១ អត្រាលទ្ធភាពមានកូនសរុប តាមចំនួនកូនចង់បានក្នុងចំណោមស្ត្រីអាយុ ១៥-៤៩ឆ្នាំ តាមចរិតលក្ខណៈអង្កេត កម្ពុជា ឆ្នាំ២០២១-២០២២

| ចរិតលក្ខណៈអង្កេត | លទ្ធភាពមានកូនសរុប តាមចំនួនកូនចង់បាន | | | | |
|---|---|---|---|---|---|
| | សរុប | ០ | ១-២ | ៣-៤ | ៥+ |
| **តំបន់** | | | | | |
| ទីប្រជុំជន | ២,៤ | ១,៤ | ២,២ | ២,៧ | ៣,៤ |
| ជនបទ | ៣,០ | ២,៤ | ២,៧ | ៣,២ | ៣,៦ |
| **រាជធានី ខេត្ត** | | | | | |
| បន្ទាយមានជ័យ | ២,៦ | ២,៦ | ២,២ | ២,៨ | ៣,២ |
| បាត់ដំបង | ២,៩ | ៣,២ | ២,៣ | ៣,០ | ៣,៥ |
| កំពង់ចាម | ៣,០ | ០,០ | ២,២ | ៣,៨ | ៣,២ |
| កំពង់ឆ្នាំង | ២,៨ | * | ២,៤ | ២,៨ | ៤,៦ |
| កំពង់ស្ពឺ | ២,៥ | ០,៧ | ២,៥ | ២,២ | ២,៨ |
| កំពង់ធំ | ៣,២ | ៣,៦ | ២,៨ | ៣,៤ | ៣,៣ |
| កំពត | ២,៥ | ១,៦ | ២,០ | ២,៨ | ៣,៩ |
| កណ្ដាល | ២,៩ | ០,៧ | ២,៦ | ៣,៣ | ៣,៩ |
| កោះកុង | ២,៩ | ០,០ | ២,៥ | ៣,៤ | ៣,៨ |
| ក្រចេះ | ៣,៣ | ១,៧ | ២,៩ | ៣,៩ | ៣,១ |
| មណ្ឌលគិរី | ៣,០ | * | ២,៣ | ៣,៥ | ២,៤ |
| ភ្នំពេញ | ២,៣ | ១,២ | ២,១ | ២,៦ | ៥,៤ |
| ព្រះវិហារ | ៣,០ | * | ២,៧ | ៣,១ | ៣,៨ |
| ព្រៃវែង | ៣,៣ | ០,០ | ៣,០ | ៣,៦ | ៥,៤ |

| ចរិតលក្ខណៈអង្កេត | លទ្ធភាពមានកូនសរុប តាមចំនួនកូនចង់បាន | | | | |
|---|---|---|---|---|---|
| | សរុប | ០ | ១-២ | ៣-៤ | ៥+ |
| ពោធិ៍សាត់ | ២,៩ | ០,៩ | ២,៤ | ២,៨ | ៤,៦ |
| រតនគិរី | ៣,០ | * | ១,៩ | ៣,១ | ៣,៦ |
| សៀមរាប | ២,៦ | ១,០ | ២,៧ | ២,៨ | ២,១ |
| ព្រះសីហនុ | ២,៦ | * | ២,១ | ២,៧ | ៣,៣ |
| ស្ទឹងត្រែង | ៣,៤ | ០,០ | ៤,៤ | ៣,២ | ៤,២ |
| ស្វាយរៀង | ៣,០ | ០,០ | ៣,០ | ៣,២ | * |
| តាកែវ | ២,៧ | ១,៧ | ២,៤ | ៣,០ | * |
| ឧត្តរមានជ័យ | ២,៦ | ៣,២ | ២,៤ | ៣,២ | * |
| កែប | ២,០ | ០,០ | ២,៣ | ២,៥ | ០,០ |
| ប៉ៃលិន | ២,៩ | * | ២,៦ | ៣,០ | ៣,០ |
| ត្បូងឃ្មុំ | ២,៩ | * | ២,៨ | ២,៨ | ៥,៣ |
| **សាសនា** | | | | | |
| ព្រះពុទ្ធ | ២,៧ | ១,៩ | ២,៥ | ៣,០ | ៣,៥ |
| ម៉ូស្លីម | ៣,៥ | ១,០ | ១,២ | ៤,៣ | ៤,៥ |
| គ្រិស្តសាសនា | ៤,៤ | * | * | ២,៩ | ៦,២ |
| គ្មានសាសនា | ១,៧ | * | * | * | ០,០ |
| សាសនាផ្សេងទៀត | * | * | * | * | * |
| **កម្រិតសិក្សាអប់រំ** | | | | | |
| មិនបានចូលរៀន | ៣,៤ | ២,៧ | ២,៨ | ៣,៨ | ៣,៣ |
| បឋមសិក្សា | ៣,១ | ២,០ | ២,៨ | ៣,៥ | ៣,៧ |
| មធ្យមសិក្សា | ២,៦ | ២,៣ | ២,៤ | ២,៨ | ៣,៥ |
| ខ្ពស់ជាងមធ្យមសិក្សា | ២,៤ | ១,៣ | ២,៣ | ២,៦ | * |
| **សន្ទស្សន៍បញ្ចភាគទ្រព្យ** | | | | | |
| ទាបបំផុត | ៣,៥ | ២,៥ | ២,៩ | ៣,៧ | ៣,៩ |
| ទាប | ៣,១ | ២,៥ | ៣,០ | ៣,២ | ៣,០ |
| កណ្តាល | ២,៧ | ១,៦ | ២,៥ | ២,៩ | ២,៩ |
| ខ្ពស់ | ២,៦ | ១,៦ | ២,៤ | ២,៨ | ៤,៤ |
| ខ្ពស់បំផុត | ២,២ | ១,៤ | ២,០ | ២,៥ | ៤,១ |
| **សរុប** | ២,៧ | ២,០ | ២,៥ | ៣,០ | ៣,៥ |

## ៤.៣. តម្រូវការសម្រាប់ផែនការគ្រួសារ

សមាមាត្រស្ត្រីដែល (១) មិនមានផ្ទៃពោះ និងមិនមានរដូវក្រោយសម្រាលហើយត្រូវបានគេចាត់ទុកថាបានផល ហើយចង់ពន្យារកំណើតកូនបន្ទាប់របស់គាត់សម្រាលរយៈពេល ២ឆ្នាំ ឬលើសពីនេះ ឬបញ្ឈប់ការមានកូនទាំងស្រុង ប៉ុន្តែមិនបានប្រើវិធីពន្យារកំណើត (2) ខកខាន ឬមិនចង់មានផ្ទៃពោះបច្ចុប្បន្ន ឬ (3)ការមិនមាន រដូវក្រោយសម្រាល និងការសម្រាលចុងក្រោយរបស់ពួកគេក្នុងរយៈពេល ២ ឆ្នាំចុងក្រោយនេះគឺខកខាន ឬមិនចង់បានកូនទៀត។

តារាង ៤.៣.១ បង្ហាញព័ត៌មានអំពីតម្រូវការសម្រាប់ការធ្វើផែនការគ្រួសារក្នុងចំណោមស្ត្រីរៀបការរួច និងស្ត្រីមិនទាន់រៀបការមានសកម្មភាពផ្លូវភេទតាមចរិតលក្ខណៈអង្កេត។ ស្ទើរតែ២ភាគ៣នៃស្ត្រីបច្ចុប្បន្នរៀបការរួចអាយុ ១៥-៤៩ឆ្នាំ មានតម្រូវការសម្រាប់ការធ្វើផែនការគ្រួសារ ១២ ភាគរយ មានតម្រូវការមិនឆ្លើយតប និង ៦២ភាគរយ មានតម្រូវការឆ្លើយតបសម្រាប់ផែនការគ្រួសារ។ តម្រូវការមិនបានឆ្លើយតបសម្រាប់ការកំណត់គម្លាតកូនបានធ្លាក់ចុះតាមក្រុមអាយុ ពី១៤% ក្នុងចំណោមស្ត្រីបច្ចុប្បន្នរៀបការរួចអាយុ ១៥-១៩ មកត្រឹម ១% ក្នុងចំណោមស្ត្រីអាយុ ៤៥-៤៩ឆ្នាំ។ ផ្ទុយទៅវិញតម្រូវការមិនឆ្លើយតបសម្រាប់ការកំណត់ចំនួនកូនជាទូទៅកើនឡើងតាមការកើនឡើងអាយុដែរ ។

តម្រូវការសរុបសម្រាប់ការធ្វើផែនការគ្រួសារក្នុងចំណោមស្ត្រីបច្ចុប្បន្នរៀបការរួចនៅទីប្រជុំជន (៧៦%)មានអត្រាខ្ពស់ជាងស្ត្រីនៅតាមជនបទ(៧២%)។ និងតម្រូវការមិនឆ្លើយតបសម្រាប់ផែនការគ្រួសារ នៅជនបទមាន (១៣%) ខ្ពស់ជាងនៅទីប្រជុំជន (១០%)។

រូប ៤.៤ ភាគរយនៃតម្រូវការសម្រាប់ផែនការគ្រួសារតាមទីកន្លែងរស់នៅ កម្ពុជា ឆ្នាំ ២០២១-២០២២



តម្រូវការមិនឆ្លើយតបសម្រាប់ផែនការគ្រួសារមានភាពខុសគ្នាតាមរាជ ធានី ខេត្ត។ ខេត្តពោធិ៍សាត់មានភាគរយខ្ពស់បំផុត ៣១% ក្នុងចំណោមស្ត្រីបច្ចុប្បន្នរៀបការ និងទាបបំផុត ៦% នៅខេត្តកំពត។

### ផែនទី៤.២ ភាគរយនៃតម្រូវការមិនឆ្លើយតបសម្រាប់ផែនការគ្រួសារតាមរាជធានី ខេត្ត កម្ពុជា ឆ្នាំ២០២១- ២០២២




តម្រូវការមិនឆ្លើយតបសម្រាប់ផែនការគ្រួសារក្នុងចំណោមស្ត្រីបច្ចុប្បន្នរៀបការរួច មិនបានចូលរៀនមានអត្រា(១៤%) ខ្ពស់ជាងក្នុងចំណោមស្ត្រីបច្ចុប្បន្នរៀបការរួចមានកម្រិតសិក្សាអប់រំខ្ពស់ជាមធ្យមសិក្សា(១០%) ។ ទម្រង់នេះកើតមានដូចគ្នាសម្រាប់តម្រូវការគ្រួសារមិនឆ្លើយតបលើបញ្ចភាគទ្រព្យសម្បត្តិ។

សម្រាប់ស្ត្រីមានតម្រូវការសម្រាប់ផែនការគ្រួសារ អត្រាលទ្ធភាពមានកូនសរុប (TFR) ហាក់បីដូចមានខ្ពស់ (៣,៨ នាក់សម្រាប់ស្ត្រីម្នាក់) បើធៀបនឹងស្ត្រីដែលមិនតម្រូវការផែនការគ្រួសារ (០,៩នាក់សម្រាប់ស្ត្រីម្នាក់)។ ទិន្នន័យបានបង្ហាញថា ស្ត្រីដែលមានតម្រូវការមិនឆ្លើយតបសម្រាប់ផែនការគ្រួសារមានកូនតិចជាង ស្ត្រីដែលមានតម្រូវការឆ្លើយតបសម្រាប់ផែនការគ្រួសារ (កូន២,៩នាក់សម្រាប់ស្ត្រីម្នាក់ ទល់នឹង៤,១នាក់សម្រាប់ស្ត្រីម្នាក់តាមលំដាប់រៀង)។

រូប ៤.៥ ភាគរយតម្រូវការសម្រាប់ផែនការគ្រួសារតាមកម្រិតសិក្សាអប់រំ កម្ពុជា ឆ្នាំ២០២១-២០២២




រូប ៤.៥ ភាគរយតម្រូវការសម្រាប់ផែនការគ្រួសារតាមបញ្ចភាគទ្រព្យសម្បត្តិ កម្ពុជា ឆ្នាំ២០២១-២០២២



## តារាង ៤.៣.១ អត្រាលទ្ធភាពមានកូនសរុបតាមតម្រូវការសម្រាប់ផែនការគ្រួសារក្នុងចំណោមស្ត្រីអាយុ ១៥-៤៩ ឆ្នាំ តាមចរិតលក្ខណៈអង្កេត កម្ពុជាឆ្នាំ២០២១-២០២២

| ចរិតលក្ខណៈអង្កេត | តម្រូវការសរុប | | គ្មានតម្រូវការ | | តម្រូវការមិនឆ្លើយតប | | តម្រូវការឆ្លើយតប | |
|---|---|---|---|---|---|---|---|---|
| | ភាគរយ | លទ្ធភាពមានកូនសរុប | ភាគរយ | លទ្ធភាពមានកូនសរុប | ភាគរយ | លទ្ធភាពមានកូនសរុប | ភាគរយ | លទ្ធភាពមានកូនសរុប |
| **តំបន់** | | | | | | | | |
| ទីប្រជុំជន | ៧៥,៧ | ៣,៩ | ២៤,៣ | ០,៦ | ៩,៧ | ២,៦ | ៦៦,០ | ៤,៣ |
| ជនបទ | ៧២,៤ | ៣,៧ | ២៧,៦ | ១,០ | ១២,៩ | ៣,០ | ៥៩,៥ | ៤,០ |
| **រាជធានី ខេត្ត** | | | | | | | | |
| បន្ទាយមានជ័យ | ៧៦,៩ | ៣,០ | ២៣,១ | ០,៧ | ១៤,៥ | ១,៧ | ៦២,៤ | ៣,៥ |
| បាត់ដំបង | ៧៧,៥ | ៣,២ | ២២,៥ | ០,៤ | ១១,៩ | ១,២ | ៦៥,៥ | ៣,៨ |
| កំពង់ចាម | ៦២,៣ | ៤,២ | ៣៧,៧ | ០,៨ | ១៦,០ | ៤,១ | ៤៦,៣ | ៤,៣ |
| កំពង់ឆ្នាំង | ៧៣,៤ | ៤,៤ | ២៦,៦ | ០,៩ | ១១,២ | ៤,០ | ៦២,២ | ៤,៨ |
| កំពង់ស្ពឺ | ៧១,៥ | ៣,៩ | ២៨,៥ | ០,៧ | ៩,៣ | ៣,៦ | ៦២,១ | ៤,០ |
| កំពង់ធំ | ៧៣,០ | ៣,៩ | ២៧,០ | ១,៣ | ១៣,០ | ១,៩ | ៦០,០ | ៤,២ |
| កំពត | ៧១,៩ | ៣,៦ | ២៨,១ | ១,៦ | ៥,៥ | ២,៦ | ៦៦,៤ | ៣,៨ |
| កណ្ដាល | ៧៧,៩ | ៤,៤ | ២២,១ | ១,០ | ៨,៤ | ២,៣ | ៦៩,៥ | ៤,៧ |
| កោះកុង | ៦១,២ | ៤,៤ | ៣៨,៨ | ១,៦ | ១៦,០ | ៤,៤ | ៤៥,១ | ៤,៣ |
| ក្រចេះ | ៦៩,៦ | ៤,១ | ៣០,៤ | ១,១ | ១២,២ | ២,៣ | ៥៧,៤ | ៤,៤ |
| មណ្ឌលគីរី | ៧៨,៨ | ៤,៣ | ២១,២ | ១,២ | ៨,១ | ៤,០ | ៧០,៧ | ៤,៥ |
| ភ្នំពេញ | ៧៦,៦ | ៣,៧ | ២៣,៤ | ០,៥ | ៨,៥ | ២,២ | ៦៨,១ | ៤,៣ |
| ព្រះវិហារ | ៧៣,២ | ៣,៧ | ២៦,៨ | ១,៦ | ៦,៦ | ១,៤ | ៦៦,៥ | ៤,០ |
| ព្រៃវែង | ៧៦,៦ | ៣,៨ | ២៣,៤ | ០,៧ | ១៣,៩ | ២,១ | ៦២,៧ | ៤,៣ |
| ពោធិ៍សាត់ | ៦៣,៣ | ៣,៨ | ៣៦,៧ | ១,២ | ៣០,៧ | ៣,១ | ៣២,៦ | ៤,៩ |
| រតនគីរី | ៧៥,៦ | ៣,៧ | ២៤,៤ | ១,៥ | ១២,១ | ៤,២ | ៦៣,៥ | ៣,៧ |
| សៀមរាប | ៧៨,៣ | ៣,៧ | ២១,៧ | ០,៩ | ១២,៤ | ៤,១ | ៦៥,៩ | ៣,៧ |
| ព្រះសីហនុ | ៧៨,៥ | ៣,៩ | ២១,៥ | ០,៦ | ១០,០ | ៤,១ | ៦៨,៥ | ៣,៨ |
| ស្ទឹងត្រែង | ៧២,១ | ៤,៥ | ២៧,៩ | ១,២ | ១៧,១ | ៥,០ | ៥៥,០ | ៤,៣ |
| ស្វាយរៀង | ៦៨,៩ | ៤,០ | ៣១,១ | ១,០ | ១០,៦ | ៣,០ | ៥៨,៣ | ៤,២ |
| តាកែវ | ៧០,៣ | ៣,៧ | ២៩,៧ | ០,៩ | ១០,៥ | ២,៩ | ៥៩,៨ | ៤,១ |
| ឧត្ដរមានជ័យ | ៧៨,៦ | ២,៨ | ២១,៤ | ០,៩ | ១២,១ | ២,៣ | ៦៦,៥ | ៣,០ |

| ចរិតលក្ខណៈអង្កេត | តម្រូវការសរុប | | គ្មានតម្រូវការ | | តម្រូវការមិនឆ្លើយតប | | តម្រូវការឆ្លើយតប | |
|---|---|---|---|---|---|---|---|---|
| | ភាគរយ | លទ្ធភាពមានកូនសរុប | ភាគរយ | លទ្ធភាពមានកូនសរុប | ភាគរយ | លទ្ធភាពមានកូនសរុប | ភាគរយ | លទ្ធភាពមានកូនសរុប |
| កែប | ៧៤,៦ | ៣,៥ | ២៥,៤ | ០,៨ | ១៤,៣ | ៣,៧ | ៦០,៣ | ៣,៨ |
| ប៉ៃលិន | ៧៨,១ | ៣,៤ | ២១,៩ | ០,៦ | ១៤,៤ | ២,៨ | ៦៣,៧ | ៣,៦ |
| ត្បូងឃ្មុំ | ៧២,៦ | ៣,៧ | ២៧,៤ | ០,៦ | ១៣,៣ | ៣,០ | ៥៩,៣ | ៤,០ |
| **កម្រិតសិក្សាអប់រំ** | | | | | | | | |
| មិនបានចូលរៀន | ៧១,៣ | ៣,៣ | ២៨,៧ | ១,៣ | ១៤,៣ | ២,៨ | ៥៧,០ | ៣,៥ |
| បឋមសិក្សា | ៧៤,២ | ៣,៩ | ២៥,៨ | ១,០ | ១១,៤ | ៣,១ | ៦២,៨ | ៤,១ |
| មធ្យមសិក្សា | ៧៤,២ | ៣,៧ | ២៥,៨ | ០,៨ | ១១,៣ | ២,៥ | ៦២,៩ | ៤,១ |
| ខ្ពស់ជាងមធ្យមសិក្សា | ៧៣,១ | ៣,៥ | ២៦,៩ | ០,២ | ៩,៥ | ៣,១ | ៦៣,៦ | ៣,៦ |
| **សន្ទស្សន៍បញ្ជាភាគទ្រព្យសម្បត្តិ** | | | | | | | | |
| ទាបបំផុត | ៧៣,០ | ៤,២ | ២៧,០ | ១,២ | ១៣,៤ | ៣,៧ | ៥៩,៦ | ៤,៣ |
| ទាប | ៧៣,០ | ៣,៥ | ២៧,០ | ១,១ | ១៣,៥ | ២,៤ | ៥៩,៦ | ៣,៨ |
| កណ្ដាល | ៧២,៧ | ៣,៧ | ២៧,៣ | ០,៧ | ១២,៦ | ២,៩ | ៦០,១ | ៤,១ |
| ខ្ពស់ | ៧២,៨ | ៣,៦ | ២៧,២ | ០,៨ | ១០,០ | ២,៦ | ៦២,៨ | ៤,០ |
| ខ្ពស់បំផុត | ៧៦,៧ | ៤,០ | ២៣,៣ | ០,៦ | ៩,៤ | ២,៧ | ៦៧,៣ | ៤,៤ |
| **សរុប** | ៧៣,៧ | ៣,៨ | ២៦,៣ | ០,៩ | ១១,៦ | ២,៩ | ៦២,១ | ៤,១ |

*កំណត់សម្គាល់: សញ្ញាផ្កាយបង្ហាញថាតួលេខមួយគឺផ្អែកលើករណីដែលមិនប្រើមេគុណតិចជាង ២៥ និងត្រូវបានលុបចោល ។*

# ជំពូកទី៥

# ការថែទាំសុខភាពមាតា និងទារក

ការថែទាំសុខភាពអំឡុងពេលមានផ្ទៃពោះពេលសម្រាល និងក្រោយពេលសម្រាលមានសារៈសំខាន់សម្រាប់ការរស់រានមានជីវិត និងសុខុមាលភាពទាំងម្តាយ និងទារក។ ការថែទាំសុខភាពមុនពេលសម្រាល (ANC) អាចកាត់បន្ថយហានិភ័យបញ្ហាសុខភាពសម្រាប់ម្តាយ និងទារកតាមរយៈការតាមដានការពពោះ និងការពិនិត្យមើលផលវិបាក។ ការសម្រាលនៅតាមមូលដ្ឋានសេវាសុខាភិបាលដោយការយកចិត្តទុដាក់ពីគ្រូពេទ្យជំនាញ និងលក្ខខណ្ឌ អនាម័យកាត់បន្ថយហានិភ័យនៃផលវិបាក និងការឆ្លងមេរោគអំឡុងពេលពិនិត្យ និងសម្រាលកូន។

ជំពូកនេះបង្ហាញព័ត៌មានស្តីអំពីអ្នកផ្តល់សេវាការថែទាំសុខភាពមុនពេលសម្រាល (ANC) ចំនួន និងពេលវេលាទៅរកការថែទាំសុខភាពមុនពេលសម្រាល (ANC) និងសមាសជាតុផ្សេងៗនៃការថែទាំសុខភាព។ ជំពូកនេះបានបង្ហាញព័ត៌មានអំពីការសម្រាល និងទីកន្លែងសម្រាល ជំនួយអំឡុងពេលសម្រាល និងការសម្រាលកូនដោយ វះកាត់ ចំណាយលើការសម្រាល និងការថែទាំងសុខភាពក្រោយពេលសម្រាលទាំងម្តាយ និងទារក។

## ៥.១. ការថែទាំសុខភាពមុនពេលសម្រាល

ស្ទើរតែគ្រប់ស្ត្រីអាយុ ១៥-៤៩ឆ្នាំ (៩៩%) មានកូនកើតរស់ក្នុងរយៈពេល២ឆ្នាំមុនអង្កេត បានទទួលការថែទាំសុខភាពមុនពេលសម្រាល(ANC) ពីមន្ត្រីដែលជំនាញវិជ្ជាជីវៈសុខាភិបាលយ៉ាងហោចណាស់ម្តងសម្រាប់កូនចុងក្រោយរបស់គាត់។ ស្ត្រីភាគច្រើន(៨៤%) បានទទួលការថែទាំសុខភាពមុនពេលសម្រាល(ANC) ពីគិលានុបដ្ឋាយិកា ឬឆ្មបខណៈដែល ១២% បានទទួលការថែទាំសុខភាពមុនពេលសម្រាល(ANC)ពីវេជ្ជបណ្ឌិត និង២% ពីជំនួយការឆ្មប។ ស្ត្រីនៅទីប្រជុំជន (២២%) បានរាយការណ៍ថាបានទទួល (ANC) ពីវេជ្ជបណ្ឌិតខ្ពស់ជាងនៅជនបទ (៧%)។ ផ្ទុយទៅវិញ ស្ត្រីនៅជនបទច្រើន (៨៩%) បានទទួល (ANC) ពីគិលានុបដ្ឋាយិកា និងឆ្មបមានខ្ពស់ជាងទីប្រជុំជន (៧៦%)។

តារាង ៥.១.១ បានបង្ហាញការថែទាំសុខភាពមុនពេលសម្រាល (ANC) សម្រាប់ស្ត្រីអាយុ ១៥-៤៩ឆ្នាំ ទាំងធ្លាប់មានកូន និងមានកូននៅរស់រាន មានភាគរយខុសគ្នាគួរឱ្យកត់សម្គាល់ (៨៦,៥%) បានទទួលការថែទាំសុខភាពមុនពេលសម្រាល (ANC)ពេញលេញ ខណៈដែលមិនបានទទួលការថែទាំសុខភាពមុនពេលសម្រាល(ANC)គឺមានត្រឹមតែ ១,៣%ប៉ុណ្ណោះ។ ការមិនបានទទួលការថែទាំសុខភាពមុនពេលសម្រាល (ANC) ហាក់ដូចនៅទីប្រជុំជនមានខ្ពស់ជាងជនបទ (១,៥% និង ០,៩% ) តាមលំដាប់រៀង។

ភាគរយខ្ពស់បំផុតនៃស្ត្រីដែលបានទទួលការថែទាំសុខភាពមុនពេលសម្រាល(ANC)ពេញលេញត្រូវបានរកឃើញមាននៅខេត្តបាត់ដំបង (៩៤,០%) និងទាបបំផុតនៅខេត្តរតនគីរី ( ៥៦,១%) ។

ភាគរយស្ត្រីអាយុ១៥-៤៩ឆ្នាំ មិនបានទទួលការថែទាំសុខភាពមុនពេលសម្រាល(ANC)បានធ្លាក់ចុះជាមួយការកើនកម្រិតសិក្សាអប់រំ ដោយចាប់ពី ៤,៤% ក្នុងចំណោមស្ត្រីមិនបានចូលរៀន មកត្រឹម ០,៣% ក្នុងចំណោមស្ត្រីបានទទួលកម្រិតសិក្សាអប់រំខ្ពស់ជាងមធ្យមសិក្សា ខណៈដែលមាននិន្នាការផ្ទុយនេះកើតមានឡើងក្នុងចំណោមស្ត្រីបានទទួល ការថែទាំសុខភាពមុនពេលសម្រាល(ANC) ច្រើនជាងបួនដង។ ការថែទាំសុខភាពមុនពេលសម្រាល (ANC) បានកើនឡើងតាមកម្រិតសិក្សាអប់រំពី ៧៣,៦% ក្នុងចំណោមស្ត្រីមិនបានចូលរៀន ទៅ៩៧,៥%ក្នុងចំណោមស្ត្រីទទួលបានកម្រិតសិក្សាខ្ពស់ជាងមធ្យមសិក្សា។

មាននិន្នាការដូចខាងលើផងដែរ ភាគរយស្ត្រីដែលមានបញ្ចភាគទ្រព្យសម្បត្តិខ្ពស់បំផុតមិនបានទទួលការថែទាំសុខភាពមុនពេលសម្រាល (ANC) មានភាគរយទាបជាងស្ត្រីដែលមានបញ្ចភាគទ្រព្យសម្បត្តិទាបបំផុត (០,១% និង ២,៥%)។ ការទទួលបានការថែទាំសុខភាពមុនពេលសម្រាល (ANC) ច្រើនជាងបួនដងក្នុងចំណោមស្ត្រីមានបញ្ចភាគទ្រព្យសម្បត្តទាបបំផុតមាន(៧៥,៦%) ទាបជាងស្ត្រីមានបញ្ចភាគទ្រព្យសម្បត្តិខ្ពស់បំផុត(៩៥,៨%)។

